Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

# បំពេញបំណងប្រាថ្នា

## បំណិនសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណើននៅកម្ពុជា

67349



# បំពេញបំណងប្រាថ្នា

## បំណិនសម្រាប់អនុវត្ត
## យុទ្ធសាស្ត្រកំណើននៅកម្ពុជា

THE WORLD BANK

©រក្សាសិទ្ធិដោយធនាគារពិភពលោក ឆ្នាំ២០១២

ធនាគារពិភពលោក
១១៣ មហាវិថីព្រះនរោត្តម
រាជធានីភ្នំពេញ
ទូរស័ព្ទលេខ : +៨៥៥ (០)២៣ ២១៧ ៣០៤
គេហទំព័រ : www.worldbank.org/kh

ឯកសារបច្ចេកទេសត្រូវបានបោះពុម្ពផ្សាយ ដើម្បីផ្តល់ព័ត៌មានពីលទ្ធផលការងាររបស់ធនាគារពិភពលោកទៅកាន់សហគមន៍អភិវឌ្ឍន៍ដោយមានការពន្យារពេលតិចតួចបំផុត ។ ហេតុនេះ សំណៅឯកសារដើមជាប្រភេទអត្ថបទមិនទាន់បានរៀបចំឱ្យស្របទៅតាមនីតិវិធីសមស្របនៃអត្ថបទ ដែលបានកែសម្រួលជាផ្លូវការនៅឡើយទេ ។ ប្រភពមួយចំនួនដែលដកស្រង់នៅក្នុងឯកសារនេះ អាចជាឯកសារក្រៅផ្លូវការដែលមិនទាន់មាន ។

លទ្ធផលរកឃើញ ការបកស្រាយ និងការសន្និដ្ឋាន ដែលបង្ហាញនៅក្នុងឯកសារនេះ គឺជាគំនិតរបស់អ្នកនិពន្ធ និងមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ធនាគារអន្តរជាតិ សម្រាប់ការស្ថាបនា និងការអភិវឌ្ឍ/ធនាគារពិភពលោក និងអង្គភាពពាក់ព័ន្ធរបស់ធនាគារ ឬជាគំនិតរបស់ប្រធានប្រតិបត្តិនៃធនាគារពិភពលោក ឬរដ្ឋាភិបាលដែលខ្លួនតំណាងឡើយ ។

ធនាគារពិភពលោកមិនធានាពីភាពត្រឹមត្រូវនៃទិន្នន័យដែលមានបញ្ចូលក្នុងឯកសារនេះទេ ។ ព្រំដែនពណ៌ ការប្រើប្រាស់ឈ្មោះ និងព័ត៌មានផ្សេងៗ បង្ហាញនៅលើផែនទីនៅក្នុងឯកសារនេះ មិនបង្ហាញពីការវិនិច្ឆ័យលើផ្នែកណាមួយរបស់ធនាគារពិភពលោកពាក់ព័ន្ធនឹងស្ថានភាពស្របច្បាប់របស់ដែនដីណាមួយ ឬការអនុម័ត ឬទទួលយកព្រំដែនទាំងនេះទេ ។

---

## សិទ្ធិ និងការអនុញ្ញាត

ឯកសារនៅក្នុងសៀវភៅបោះពុម្ពផ្សាយនេះត្រូវបានរក្សាសិទ្ធិ ។ ការថតចម្លង និង/ឬការផ្សព្វផ្សាយផ្នែកណាមួយ ឬទាំងស្រុងនៃឯកសារនេះ ដោយគ្មានការអនុញ្ញាត គឺជាការបំពានទៅលើច្បាប់ជាធរមាន ។ ធនាគារអន្តរជាតិសម្រាប់ការស្ថាបនា និងការអភិវឌ្ឍ/ធនាគារពិភពលោក លើកទឹកចិត្តឱ្យមានការផ្សព្វផ្សាយពីការងាររបស់ខ្លួន ហើយជាធម្មតាផ្តល់ការអនុញ្ញាតឱ្យធ្វើការបោះពុម្ពផ្សាយឡើងវិញនូវផ្នែកនានានៃឯកសារនេះភ្លាមៗ ។

សម្រាប់ការអនុញ្ញាតឱ្យធ្វើការថតចម្លង ឬបោះពុម្ពផ្សាយឡើងវិញនូវផ្នែកណាមួយនៃឯកសារនេះ សូមផ្ញើសំណើអមជាមួយព័ត៌មានលម្អិតទៅកាន់មជ្ឈមណ្ឌល រក្សាសិទ្ធិថតចម្លង ដែលមានអាសយដ្ឋាន ២២២ Rosewood Drive/ Danvers/MA ០១៩២៣ សហរដ្ឋអាមេរិក ទូរស័ព្ទលេខ ៩៧៨-៧៥០-៨៤០០ ទូរសារលេខ ៩៧៨-៧៥០-៤៤៧០ គេហទំព័រ www.copyright.com.

រាល់ចម្ងល់ទាំងឡាយទាក់ទងនឹងសិទ្ធិ និងអាជ្ញាប័ណ្ណ រួមទាំងសិទ្ធិបុត្រសម្ព័ន្ធ គួរផ្ញើទៅកាន់ការិយាល័យបោះពុម្ពផ្សាយធនាគារពិភពលោក ១៨១៨ H Street NW ទីក្រុងវ៉ាស៊ីនតោន DC ២០៤៣៣ សហរដ្ឋអាមេរិក លេខទូរសារ ២០២-៥២២-២៤២២ សារអេឡិចត្រូនិក

pubrights@worldbank.org ។

Report number: 67349-KH

គម្របសៀវភៅ
ទីតាំង : សាកលវិទ្យាល័យកសិកម្មនៅរាជធានីភ្នំពេញ
រូបថតដោយ : Dylan Walker

# អារម្ភកថា

បំណិនកម្លាំងពលកម្ម  មានឥទ្ធិពលទៅលើការរីកចម្រើនរបស់ប្រទេសក្នុងការអភិវឌ្ឍសេដ្ឋកិច្ច  ការកាត់បន្ថយភាពក្រីក្រ និងការបង្កើតការងារ ។ ការវិនិយោគក្នុងផ្នែកបំណិនកម្លាំងពលកម្ម បានចូលរួមចំណែកបង្កើនឱ្យមានផលិតភាពខ្ពស់  និងអាចលើកកម្ពស់ការប្រកួតប្រជែង  និងបង្កើនឱកាសការងារនិងការលូតលាស់កាន់តែប្រសើរឡើងថែមទៀត ។ បណ្តាប្រទេសសមាជិកអាស៊ាន រួមមាន ប្រទេសកម្ពុជាបានទទួលស្គាល់ពីសារៈសំខាន់នៃបំណិនសម្រាប់ភាពចម្រុងចម្រើន និងព្យាយាមលើកកម្ពស់ការអភិវឌ្ឍបំណិន និងលំហូរដោយសេរីនៃពលកម្មប្រកបដោយជំនាញដែលជាផ្នែកមួយនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន ។

របៀបវារៈនៃការអភិវឌ្ឍបំណិន មានសារៈសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជា ។ ដោយសារតែប្រជាជនវ័យក្មេងមានចំនួនច្រើន ប្រទេសកម្ពុជានឹងអាចមើល ឃើញពីកំណើនសេដ្ឋកិច្ច បម្រែបម្រួលបច្ចេកវិទ្យា និងការងាររបស់ខ្លួននាពេលអនាគត ដែលផ្អែកលើសមត្ថភាពក្នុងការទទួលបានបំណិនរបស់យុវជនសម័យថ្មី ។ ហេតុដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ពីសារៈសំខាន់នៃបំណិន ទុកជាផ្នែកមួយនៃយុទ្ធសាស្រ្តចតុកោណរបស់ប្រទេសកម្ពុជាដើម្បីភាពរីកចម្រើនការងារសមធម៌ និងប្រសិទ្ធភាព ។

ក្នុងបរិបទនេះ  ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC)  បានស្នើឱ្យធនាគារពិភពលោកចូលរួម  និងធ្វើការងារ រួមគ្នាលើការវិភាគមួយស្តីពីអតុល្យភាពបំណិនដែលកើតមានឡើងចំពោះសេដ្ឋកិច្ចប្រទេសកម្ពុជា ឬសគល់នៃបញ្ហាទាំងនោះ និងវិធានការឆ្លើយតបដែលអាចធ្វើទៅបានផងដែរ ។ លទ្ធផលជាផ្លែផ្កាដែលទទួលបានពីកិច្ចសហការ និងការចែករំលែកចំណេះដឹងនោះ គឺជារបាយការណ៍បំណិនសម្រាប់បំពេញបំណងប្រាថ្នាប្រទេសកម្ពុជា : ការអនុវត្តយុទ្ធសាស្រ្តកំណើនរបស់ប្រទេសកម្ពុជាបន្ទាប់ពីមានវិបត្តិ ។

លទ្ធផលរកឃើញដំបូងនៃរបាយការណ៍នេះ និងផែនការសកម្មភាពអភិវឌ្ឍបំណិនដែលបានលើកឡើង ត្រូវបានលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំតុមូលមួយ ដែលមានការចូលរួមពីតំណាងមកពីបណ្តាក្រសួងនានា និយោជកក្នុងវិស័យឯកជន  និងភាគីពាក់ព័ន្ធដទៃទៀតដែលបានប្រារព្ធធ្វើឡើងនៅទីក្រុងភ្នំពេញនាថ្ងៃទី៣១ ខែមីនា  ឆ្នាំ២០១១។  កិច្ចពិភាក្សានេះ  បានគូសបញ្ជាក់ពីសារៈសំខាន់នៃការជ្រើសរើសយុទ្ធវិធីវដ្តជីវិតចំពោះការអភិវឌ្ឍបំណិន ការទទួលស្គាល់ថាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់បំណិននានា ត្រូវបានបង្កើតឡើងនៅក្នុងការអប់រំកុមារតូច  និងជាផ្នែកនៃការអប់រំកម្រិតមូលដ្ឋាន ។  លើសពីនេះទៀតតំណាងក្នុងវិស័យឯកជន  បានលើកឡើងពីភាពចាំបាច់ក្នុងការផ្តល់បំណិនដែលមានក្នុងប្រព័ន្ធអប់រំ  និងបណ្តុះបណ្តាលរបស់ប្រទេសកម្ពុជាឱ្យស្របទៅនឹងតម្រូវការក្នុងទីផ្សារការងារ ។

របាយការណ៍នេះ ផ្ដល់ជាទស្សនៈដ៏មានតម្លៃសម្រាប់ប្រទេសកម្ពុជា ដើម្បីចាត់វិធានការដែលអាចធ្វើទៅបានក្នុងការអភិវឌ្ឍបំណិនផ្សេងៗសម្រាប់បំពេញបំណងប្រាថ្នាប្រទេសកម្ពុជា។ របាយការណ៍នេះ ក៏បានគូសព្រាងពីវិធានការជាក់លាក់មួយចំនួនក្នុងការសម្រួលដល់លទ្ធភាពទទួលបានព័ត៌មានក្នុងទីផ្សារ ការងារ ពង្រីកអន្តរាគមន៍ផ្ដោតលើគ្រួសារ ដើម្បីលើកកម្ពស់អត្រាគង់វង្សក្នុងការសិក្សា និងពង្រឹងកម្មវិធីឱកាសលើកទីពីរ ក៏ដូចជា ការអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈផងដែរ។ ដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់ពេលអនាគត របាយការណ៍នេះបានលើកឡើងពីវិធីដ៏ល្អបំផុត ដើម្បីបង្កើនហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍការអប់រំកុមារតូច ពង្រឹងស្ថាប័ន និងជំរុញឱ្យមានការលើកទឹកចិត្តចំពោះស្ថាប័នដែលមានលទ្ធផលល្អប្រសើរក្នុងចំណោមស្ថាប័នបណ្ដុះបណ្ដាលបំណិន រួមមាន គ្រឹះស្ថានឧត្ដមសិក្សាជាដើម។

ការវិភាគរបាយការណ៍នេះ បង្ហាញពីការចូលរួមសហការដ៏មានអត្ថប្រយោជន៍ចំពោះយុទ្ធសាស្ត្រកំណើន និងរបៀបវារៈនៃការអភិវឌ្ឍមនុស្សរបស់ប្រទេសកម្ពុជា ហើយយើងខ្ញុំសង្ឃឹមថា របាយការណ៍នេះនឹងមានសារប្រយោជន៍សម្រាប់លោកអ្នក។

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះ រៀបចំឡើងដោយក្រុមការងារនៃធនាគារពិភពលោក ដែលដឹកនាំដោយលោកស្រី Hana Brixi ក្រោមកិច្ចសហការយ៉ាងស្អិតរមួតជាមួយនឹងជំនាញការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ។ លោក Arvil Van Adams, លោកស្រី Sandra D'Amico (សាជីវកម្មធនធានមនុស្សកម្ពុជា) និងលោក Alexander Krauss បានចូលរួមក្នុងការសិក្សាមូលដ្ឋាន ។

ក្រុមការងារនេះ បានធ្វើការផ្លាស់ប្តូរយោបល់ និងទទួលបានអនុសាសន៍ដ៏មានតម្លៃពីសំណាក់មន្ត្រីរដ្ឋាភិបាល មកពីក្រសួង និងទីភ្នាក់ងាររដ្ឋាភិបាលផ្សេងៗ រួមមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) និងស្ថាប័នរដ្ឋាភិបាល និងស្ថាប័នដៃគូនានា ដូចជា AusAid ជាដើម ។ មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ និងជំនាញការជាច្រើនបានផ្តល់មតិ និងសំណើសំខាន់ៗមួយចំនួន ក្នុងអំឡុងកិច្ចប្រជុំតុមូលស្តីពីបំណិននៅទីក្រុងភ្នំពេញ នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១។

ក្រុមការងារយើងខ្ញុំ សូមថ្លែងអំណរគុណចំពោះការណែនាំដែលមិនអាចកាត់ថ្លៃបានពីសំណាក់ : ឯកឧត្តម ហង្ស ជួនណារ៉ុន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានអចិន្ត្រៃយ៍នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឯកឧត្តម ពេជ សោភ័ន រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងឯកឧត្តម ប៉ុក ប៉ាន់ រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណជាពិសេសចំពោះមន្ត្រីជាន់ខ្ពស់មួយចំនួន សម្រាប់ការចូលរួមចំណែកបច្ចេកទេសដល់ការវិភាគនេះ រួមមាន ឯកឧត្តម សុខ ចិន្តា អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឯកឧត្តម ម៉ី កល្យាណ ទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម ឡៅ ហ៊ីម អគ្គនាយក នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឯកឧត្តម ហេង សួ អគ្គនាយកនៃ អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តម ហុង ជួន ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ ឯកឧត្តម ម៉ក់ ង៉យ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំយុវជន និងកីឡា លោកបណ្ឌិត ជិន ហៀងថាវិរិទ្ធិ នាយកវិទ្យាស្ថានបច្ចេកទេសកម្ពុជា ឯកឧត្តម រស់ សីលវ៉ា អគ្គលេខាធិការរងនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឯកឧត្តម ផាន់ ផល្លា អគ្គលេខាធិការរងនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឯកឧត្តម ជា វុទ្ធី អគ្គលេខាធិការរងទទួលបន្ទុកតំបន់សេដ្ឋកិច្ចពិសេសនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឯកឧត្តម សាន វឌ្ឍនា អគ្គលេខាធិការរងនៃ CARD-SPCU លោក ទេព អឿន អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក អ៊ុង លុយណា ប្រធានផ្នែកស្រាវជ្រាវ និងវិភាគគោលនយោបាយសង្គមនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ លោក សួន សុផល អនុប្រធានទទួលបន្ទុកតំបន់សេដ្ឋកិច្ចពិសេសនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លោក ហៃ សុវុទ្ធា អនុប្រធានផ្នែកគោលនយោបាយសង្គមនៃឧត្តមក្រុមប្រឹក្សា សេដ្ឋកិច្ចជាតិ លោក ឡៃ សុខឃាង អ្នកស្រាវជ្រាវនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងលោក សូ ច័ន្ទត្រីស្នា បុគ្គលិក CARD-SPCU ។

ក្រុមការងារយើងខ្ញុំ សូមថ្លែងអំណរគុណចំពោះការចូលរួមពីសំណាក់ដៃគូមិនមែនរដ្ឋាភិបាល ដែលបានផ្តល់ជាទស្សនៈ និងព័ត៌មានដ៏មានសារប្រយោជន៍ រួមមាន : អ្នកស្រី លីលី ស៊ីសម្បត្តិ FO/IFC G-PSF (វេទិការដ្ឋាភិបាល- វិស័យឯកជន) លោក Pierre Tami (ស្ថាបនិកអង្គការ Hagar អន្តរជាតិ) អ្នកស្រី Nicky Enriquez (ប្រធានគ្រប់គ្រងធនធានមនុស្សមកពីក្រុមហ៊ុន Mobitel) លោក Si Len (ប្រធានគ្រប់គ្រងការបណ្តុះបណ្តាល CAMFEBA) លោក Ken Loo (នាយក GMAC) លោក យុគ សុធី (នាយក NTTI) លោក ជា ម៉ារ៉ុង (អ្នកស្រាវជ្រាវជាន់ខ្ពស់ BDLINK Cambodia Co., Ltd) លោក ហែម តុលា (អ្នកប្រឹក្សាប្រចាំ BDLINK Cambodia Co., Ltd) លោក ពៅ សំ (នាយកប្រតិបត្តិរោងចក្រផ្គត់ផ្គង់អាហារសមុទ្រ Nautisco) លោក គួច គីម (CSDEC) អ្នកស្រី ហាស់ ឪណា (សុខ សុខខា) លោក ចារ្យ ខេមរិន (NTTI) លោកបណ្ឌិត តាន់ មុនីវណ្ណ (អនុប្រធានក្រុមហ៊ុន ម៉ុងឬទ្ធីគ្រុប) អ្នកស្រី ហៃ ស៊ីថៃត (Loran Imp. Ezp.com., Ltd)។

សហសេវិកនៃធនាគារពិភពលោកជាច្រើន រួមមាន លោក Mathew Verghis, លោក Stephane Guimbert, លោក Carlos Sobrado, អ្នកស្រី Omporn Regel, លោក Timothy A. Johnson, លោក Christian Bodewig, លោក Jamele Rigolini, លោក បេង ស៊ីមេត្ស លោក Tsuyoshi Fukao, លោក Julian Clarke, លោក Harold H. Alderman, អ្នកស្រី Mariana Infante Villarroel, និង លោក ប៉េង វ៉ាន់នី ដែលបានចូលរួមជាមតិយោបល់ និងសំណើផ្សេងៗដ៏មានសារប្រយោជន៍។ យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់អ្នកស្រី Mariana Infante Villarroel, លោក ប៉េង វ៉ាន់នី និងអ្នកស្រី ជៀប វ៉ារ៉ាន់ ដែលបានជួយសម្រួលដល់ការបង្កើតបោះពុម្ព និងដំណើរការបកប្រែរបាយការណ៍នេះ។ ក្រុមការងារបកប្រែនៃក្រុមហ៊ុន ណូទីខ្មែរ ដែលបានបកប្រែរបាយការណ៍នេះទៅជាភាសាខ្មែរ។

ជាចុងក្រោយ ក្រុមការងារយើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក Qimiao Fan (ប្រធានគ្រប់គ្រងការិយាល័យធនាគារពិភពលោកប្រចាំកម្ពុជា) ចំពោះការបានផ្តល់ជាគោលការណ៍ណែនាំយុទ្ធសាស្ត្រ អ្នកស្រី Annette Dixon (នាយិកាធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា-ឡាវ-ម៉ាឡេស៊ី-ថៃ និងជាតំណាងរបស់ធនាគារពិភពលោកប្រចាំប្រទេសភូមា) ចំពោះការណែនាំដែលមិនអាចកាត់ថ្លៃបាន អ្នកស្រី Xiaoqing Yu (នាយិកាផ្នែកអភិវឌ្ឍមនុស្ស-គាំពារសង្គម) លោក Eduardo Velez (អតីតប្រធានគ្រប់គ្រងផ្នែកអប់រំ) និងលោក Luis Benveniste (ប្រធានគ្រប់គ្រងផ្នែកអប់រំបច្ចុប្បន្ន) ចំពោះការបានផ្តល់ជាគោលការណ៍ណែនាំយុទ្ធសាស្ត្រ។

# មាតិកា


**សេចក្តីសង្ខេប** ១

**១. យុទ្ធសាស្ត្រកំណើនរបស់ប្រទេសកម្ពុជា ទាមទារឱ្យមានបំណិនល្អប្រសើរជាងមុន** ៦

**២. តើភាពមិនសមស្របនៃបំណិន និងបុព្វហេតុនៃភាពមិនសមស្របមានលក្ខណៈដូចម្តេច?** ១២

*២.១ តើនិយោជកប្រឈមនឹងការខ្វះខាត និងភាពមិនសមស្របនៃបំណិនអ្វីខ្លះ?* ១២

*២.២ តើភាពខ្វះខាតក្នុងការផ្តល់បំណិនស្ថិតនៅត្រង់ណា?* ១៦

*២.៣ តើការខ្វះខាត និងភាពមិនសមស្របនៃបំណិនក្នុងប្រទេសកម្ពុជា បណ្តាលមកពីមូលហេតុអ្វីខ្លះ?* ២៥

**៣. សកម្មភាព និងយុទ្ធសាស្ត្រសម្រាប់បំណិន ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា** ៣២

*៣.១ ការបង្កើតផែនការសកម្មភាពបំណិន* ៣៣

*៣.២ ការអនុវត្តផែនការសកម្មភាព និងការពិចារណាលើយុទ្ធសាស្ត្រឱ្យបានទូលំទូលាយ* ៤២

**ឯកសារយោង** ៤៤

# អក្សរកាត់

| | |
|---|---|
| AusAid | ទីភ្នាក់ងារអូស្ត្រាលី សំរាប់ការអភិវឌ្ឍន៍អន្តរជាតិ |
| CAMFEBA | សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា |
| CARD | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៏វិស័យកសិកម្ម និងជនបទ |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា |
| CSES | ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច កម្ពុជា |
| D&D | វិមជ្ឈការ និងវិសហមជ្ឈការ |
| ECD | ការអភិវឌ្ឍកុមារតូច |
| EMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ |
| GDP | ផលិតផលសរុបក្នុងស្រុក |
| GMAC | សមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| IT | បច្ចេកវិទ្យាព័ត៌មាន |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| NEA | ទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| NTB | គណៈកម្មាធិការជាតិបណ្តុះបណ្តាល |
| NTTI | វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស |
| RGC | រដ្ឋាភិបាលកម្ពុជា |
| SEZ | តំបន់សេដ្ឋកិច្ចពិសេស |
| SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| SPCU | អង្គភាពសម្របសម្រួលគាំពារសង្គម |
| STEP | បំណិនដើម្បីទទួលបានការងារ និងផលិតភាព |
| TVET | អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| UNESCO | អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ |

# សេចក្តីសង្ខេប

រដ្ឋាភិបាលបានព្រមព្រៀងកំណត់យកបំណិនជាផ្នែកមួយ នៃយុទ្ធសាស្ត្រចតុកោណរបស់ប្រទេសកម្ពុជា ដើម្បីភាពរីកចម្រើន ការងារ សមធម៌ និងប្រសិទ្ធភាព។ ជាច្រើនទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានលើកកម្ពស់បំណិនកម្លាំងពលកម្មរបស់ខ្លួន ដែលកម្លាំងពលកម្មនេះមានការរីកចម្រើនយឺតជាងគេបើប្រៀបធៀបជាមួយប្រទេសដទៃទៀតក្នុងតំបន់អាស៊ីបូព៌ា។ ទោះបីជាក្រុមហ៊ុនមួយចំនួនក្នុងប្រទេសកម្ពុជាយល់ឃើញថា បំណិនមិនមែនជាឧបសគ្គចម្បងក្នុងអាជីវកម្មរបស់ខ្លួនក៏ដោយ ក៏បញ្ហាខ្វះខាតបំណិនអាចមានឥទ្ធិពលអវិជ្ជមានដល់ដំណើរការលើកកម្ពស់វិស័យឧស្សាហកម្ម កសិកម្ម និងពិពិធកម្មសេដ្ឋកិច្ច។ ការអង្កេតបរិយាកាសវិនិយោគឆ្នាំ២០០៧ បានបង្ហាញឱ្យឃើញថា ក្រុមហ៊ុនដែលរាយការណ៍ថា បំណិនជាឧបសគ្គចម្បងរាំងស្ទះដល់ការរីកចម្រើនមានកំណើនពី ៦,៥% ដល់ ១៥,៥% នៅឆ្នាំ២០០៣។ លើសពីនេះក្រុមហ៊ុនបរទេសនៅប្រទេសកម្ពុជា ចំនួន ២២% បានចាត់ទុកបំណិនជាឧបសគ្គ "ធ្ងន់ធ្ងរ ឬធ្ងន់ធ្ងរបំផុត" ដល់ការធ្វើអាជីវកម្មរបស់ខ្លួន។ ក្នុងពេលធ្វើការវិនិយោគផ្ទាល់ពីបរទេសមានទំនាក់ទំនងវិជ្ជមានជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាទំនើប និងកម្លាំងពលកម្មដែលមានជំនាញនោះការវិនិយោគផ្ទាល់ពីបរទេសថ្មីត្រូវការចំណាយសម្រាប់ឱកាសការងារ។ លើសពីនេះ ដោយសារប្រជាជន ៥៦%មានអាយុក្រោម ២៥ ឆ្នាំក្នុងឆ្នាំ២០០៨ ទើបសមត្ថភាពរបស់យុវជនបច្ចុប្បន្នក្នុងការទទួលបានបំណិននឹងជួយលើកកម្ពស់លទ្ធផលសេដ្ឋកិច្ច និងឱកាសរីកចម្រើនរបស់ប្រទេសកម្ពុជានាពេលអនាគត។

និយោជកចង្អុលបង្ហាញពីអតុល្យភាពជារចនាសម្ព័ន្ធក្នុងការផ្តល់បំណិន រួមទាំងកង្វះខាតសិស្សបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈប្រៀបធៀបជាមួយនឹងសិស្សបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សា។ ក្នុងការអង្កេតថ្មីមួយលើនិយោជក ៧៨ នាក់ របស់ HRINC (ឆ្នាំ២០១១) និយោជក ៧៣% បានរាយការណ៍ថាសិស្សបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សាមិនទាន់មានបំណិនឆ្លើយតបនឹងការងារ (ចំណែកនិយោជក ១២% ទៀត បាននិយាយថា ចំនួនសិស្សបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សាមិនទាន់មានគ្រប់គ្រាន់) និយោជក ៦២% បានកត់សម្គាល់ឃើញថា សិស្សបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈមិនមានបំណិនឆ្លើយតបនឹងការងារនោះទេ (ចំណែកនិយោជក ៣៨% ទៀត បានលើកឡើងថា សិស្សបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួនតិចតួចបំផុត)។ លើសពីនេះ និយោជក ៣១% បានកត់សម្គាល់ឃើញថា ការបណ្តុះបណ្តាល ឬការលើកកម្ពស់កម្លាំងពលកម្មបច្ចុប្បន្ន គឺជាការលំបាកដែលការងារនេះអាចបណ្តាលមកពីគុណភាពទាបនៃកម្មវិធីបណ្តុះបណ្តាល និងភាពទន់ខ្សោយនៃមូលដ្ឋានបំណិនសម្រាប់ការបណ្តុះបណ្តាលបន្ថែម។

---

១ កំណត់សម្គាល់នេះ រៀបចំឡើង បន្ទាប់ពីរបាយការណ៍របស់ធនាគារពិភពលោក ឆ្នាំ២០១០ ស្តីពី**ការផ្តល់បំណិនសម្រាប់សមធម៌ និងភាពរីកចម្រើន** និងបន្ថែមពីលើកំណត់សម្គាល់ឆ្នាំ២០១០ របស់ធនាគារពិភពលោកស្តីពី **ការអនុវត្តយុទ្ធសាស្ត្រកំណើនរបស់ប្រទេសកម្ពុជាក្រោយពេលមានវិបត្តិ**។ កំណត់សម្គាល់នេះ ផ្អែកលើកិច្ចពិភាក្សាក្នុងបេសកកម្មគាំពារសង្គមរបស់ធនាគារពិភពលោក កាលពីខែវិច្ឆិកា ឆ្នាំ២០១០ និងផ្អែកលើការជជែកពិភាក្សាគោលនយោបាយនៅវេទិកាសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១១។កំណត់សម្គាល់នេះ មានគោលបំណងគាំទ្ររដ្ឋាភិបាលក្នុងការកំណត់សកម្មភាព ដើម្បីដោះស្រាយឧបសគ្គជាកាតព្វកិច្ច និងការព្រាងយុទ្ធសាស្ត្របំណិនរបស់ប្រទេសកម្ពុជា សម្រាប់ពេលអនាគត។ សូមធ្វើការណែនាំដោយសួរជាសំនួរ និងផ្តល់យោបល់ទៅ Hana Brixi ដែលជាប្រធានក្រុមសម្រាប់កម្មវិធីគាំពារសង្គមរបស់ធនាគារពិភពលោកក្នុងប្រទេស។ កម្ពុជា (hbrixi@worldbank.org)។

និយោជកយល់ឃើញថា ថ្នាក់គ្រប់គ្រងជាន់ខ្ពស់មានការខ្វះខាតបំណិនធ្ងន់ធ្ងរ ហើយនិយោជិតវិញ មានការខ្វះខាតបំណិនជីវិតដែលជាបំណិនសំខាន់បំផុតសម្រាប់ការងារ ។ ក្នុងការអង្កេតឆ្នាំ២០១១ របស់ HRINC និយោជកលើសពី ៧០% បានរាយការណ៍ពីការខ្វះខាតជាចម្បងនូវបំណិនគ្រប់គ្រងក្នុងនោះនិយោជក ៣៦% រាយការណ៍ពីការខ្វះខាតបំណិនគ្រប់គ្រងថ្នាក់កណ្តាល និងបំណិនផ្នែកអភិបាលកិច្ច ហើយនិយោជក ៣៤% រាយការណ៍ពីការខ្វះខាតបំណិនបុគ្គលិកជំនាញ ។ ក្នុងចំណោមបំណិនជីវិតដែលមានភាពលំបាកក្នុងការស្វែងរកនិយោជកបានកំណត់ពីបំណិនជីវិតមួយចំនួនដែលក្នុងនោះ មាននិយោជក ៥២% បានកំណត់ពីឥរិយាបថការងាររបស់និយោជិតមិនមានជំនាញនិយោជក ៤៥% បានលើកឡើងពីបំណិនក្នុងការសម្រេចចិត្តរបស់និយោជិតមានជំនាញមិនច្បាស់លាស់ និងនិយោជក ៦៤% បានលើកឡើងពីបំណិនវិភាគរបស់និយោជិតជំនាញ ។ បន្ថែមពីនេះទៀត និយោជកមានការត្អូញត្អែរពីការលំបាកក្នុងការស្វែងរកនិយោជិតដែលមានបំណិនវិជ្ជាជីវៈច្បាស់លាស់ និងមានបំណិនមូលដ្ឋាន ដូចជា អក្ខរកម្ម និងការគណនាលេខនព្វន្ត ។

ដើម្បីដោះស្រាយបញ្ហាខ្វះខាតបំណិន និយោជកជាច្រើនផ្តល់ការបណ្តុះបណ្តាលផ្លូវការ ប៉ុន្តែគេមានការលំបាកក្នុងការស្វែងរកស្ថាប័នបណ្តុះបណ្តាល ដែលមានគុណភាព ។ ការអង្កេតធ្វើឡើងសម្រាប់ឯកសារគោលនយោបាយនេះ បានបង្ហាញឱ្យឃើញថា និយោជក ៥៥% ផ្តល់ការបណ្តុះបណ្តាលដល់និយោជិតរបស់ខ្លួន យ៉ាងហោចណាស់ពាក់កណ្តាលនៃនិយោជិតទាំងអស់ ចំណែកនិយោជកជាច្រើនទៀតផ្តល់ការបណ្តុះបណ្តាលដល់កម្លាំងពលកម្មរបស់ខ្លួនតែមួយចំនួនតូចប៉ុណ្ណោះ (ការអង្កេតរបស់ HRINC ឆ្នាំ២០១១) ។ ការអង្កេតនេះក៏បង្ហាញដែរថា និយោជកចំនួន ៦៤% ជួបប្រទះនឹងឧបសគ្គធ្ងន់ធ្ងរក្នុងការស្វែងរកស្ថាប័នបណ្តុះបណ្តាលដែលមានគុណភាព ។ ដើម្បីដោះស្រាយបញ្ហានេះ និយោជកទាមទារព័ត៌មានបន្ថែម រួមទាំងព័ត៌មាន ស្តីពីស្ថាប័នបណ្តុះបណ្តាលការងារគុណភាពរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ លទ្ធភាពផ្តល់បំណិនជាក់លាក់ និងគុណភាពសាកលវិទ្យាល័យ ព្រមទាំងមានបំណងបង្កើតទំនាក់ទំនងជាមួយសាកលវិទ្យាល័យទៀតផង ។

ប្រទេសកម្ពុជាប្រឈមនឹងឧបសគ្គចម្បងក្នុងការផ្តល់បំណិននៅដំណាក់កាលដំបូងនៃវដ្តជីវិត ដែលចាប់ផ្តើមពីការអភិវឌ្ឍកុមារតូច ។ ភស្តុតាងពីការអង្កេតបង្ហាញថា កម្មវិធីអភិវឌ្ឍន៏កុមារតូចដែលមានប្រសិទ្ធភាពផ្តល់អត្ថប្រយោជន៏ជាច្រើន ផ្ទុយមកវិញ ពិការភាពនៅវ័យក្មេង គឺមានការលំបាក និងត្រូវចំណាយថវិកាច្រើនក្នុងការព្យាបាល ។ ទោះជាយ៉ាងនេះក្តី នៅប្រទេសកម្ពុជាបញ្ហាការខ្វះអាហារូបត្ថម្ភធ្ងន់ធ្ងរនៅតែរាលដាលនិងជះឥទ្ធិពលអវិជ្ជមានលើការអភិវឌ្ឍបញ្ញាស្មារតីរបស់កុមារនិងសក្តានុពលបំណិននាពេលអនាគត ។ កង្វះអាហារនៅក្នុងគ្រួសារធ្វើឱ្យអត្រាសិក្សា និងបញ្ចប់ការសិក្សាមានកម្រិតទាប ។

ការអប់រំបឋមសិក្សាបង្ហាញពីភាពខ្សោយក្នុងការបញ្ចប់ការសិក្សា និងការសិក្សាទូទៅ ។ គោលនយោបាយរដ្ឋាភិបាលបានបង្កើនអត្រាចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សារហូតដល់ ៩៥% ក្នុងឆ្នាំ២០០៩/២០១០ នៅទូទាំងទីក្រុង និងតំបន់ជនបទ ។ ទោះបីជាយ៉ាងណា សិស្សបោះបង់ការសិក្សានៅបឋមសិក្សាមានកម្រិតខ្ពស់ដែលក្នុងនោះអត្រាត្រួតថ្នាក់មាន ១១% និងអត្រាបោះបង់ការសិក្សាមាន ៤៩% ។ មូលហេតុសម្រាប់ការមិនចូលរៀន និងការបោះបង់ចោលការសិក្សា គឺមានទំនាក់ទំនងចម្បងទៅនឹងស្ថានភាពគ្រួសាររួមមាន ភាពក្រីក្រការធ្វើការងារផ្ទះ និងការរកប្រាក់ចំណូល (ជាមូលហេតុចម្បងដែលកុមារអាយុ ៦ ឆ្នាំដល់ ១១ ឆ្នាំ ចំនួន ១៣% មិនបានចូលរៀន) ព្រមទាំងការគិតថា កុមារនៅវ័យក្មេងនៅឡើយ ទោះបីជាគ្រប់អាយុផ្លូវការចូលរៀនក៏ដោយ (៥៤%) ឬមិនចង់ចូលរៀន (១៧%) ។ មូលហេតុនៃការមិនចូលរៀន

ឬគិតថាអាយុក្មេងពេកមិនអាចចូលរៀននោះ ឆ្លុះបញ្ចាំងពីបញ្ហាចំពោះកុមារតូច រួមទាំងការអភិវឌ្ឍឃើតយាវ និងខ្សោយបញ្ញាដោយសារតែការខ្វះខាតអាហារូបត្ថម្ភ ឬកាត់បន្ថយសកម្មភាពខួរក្បាល ដោយសារខ្វះការបណ្តុះបណ្តាលស្មារតីគ្រប់គ្រាន់នៅដំណាក់កាលដំបូងនៃជីវិត ។ លើសពីនេះ វិញ្ញាសាប្រឡងវាយតម្លៃសិស្សថ្នាក់ជាតិលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ទី៣ ទី៦ និងទី៩ បង្ហាញថា លទ្ធផលសិក្សាមូលដ្ឋានរបស់សិស្សនៅមានកម្រិតទាបនៅឡើយ ទោះបីមានការលើកកម្ពស់ក៏ដោយ ។ វត្តមាន និងលក្ខណៈសម្បត្តិរបស់គ្រូបង្រៀន គឺជាឧបសគ្គចម្បងមួយ ។

វត្តមានសិក្សានៅកម្រិតមធ្យមសិក្សា និងការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) នៅមានកម្រិតទាប និងប្រឈមនឹងការមិនឱ្យតម្លៃលើការសិក្សា ។ អត្រាចុះឈ្មោះចូលរៀនមានកម្រិតទាបនៅឡើយ ដែលមានប្រហែល ៣២% នៅកម្រិតមធ្យមសិក្សាបឋមភូមិ ១២% នៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងតិចជាង ៦% សម្រាប់ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (EMIS ឆ្នាំ២០១០ និង CSES ឆ្នាំ២០០៩) សិស្សតិចជាង ពាក់កណ្តាលបញ្ចប់ការអប់រំមធ្យមសិក្សារបស់ខ្លួន ។ មូលហេតុសម្រាប់ការមិនចូលរៀន និងការបោះបង់ចោលការសិក្សា គឺបញ្ហាផ្នែកហិរញ្ញវត្ថុ ដោយសិស្ស ៥២% មិនបានចូលរៀនមធ្យមសិក្សាបឋមភូមិ និងសិស្ស ២ ភាគ ៣ មិនបានចូលរៀនមធ្យមសិក្សាទុតិយភូមិ គឺជាសិស្សស្ថិតក្នុងភាពក្រីក្រដែលត្រូវស្វែងរកប្រាក់ចំណូល និងធ្វើការងារផ្ទះ (CSES ឆ្នាំ២០០៩) ។ ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) បានទទួលស្គាល់ និងចាប់ផ្តើមផ្តល់ជំនួយហិរញ្ញវត្ថុដល់គ្រួសារសម្រាប់ឱ្យកូនបន្តការសិក្សា ។ ម្យ៉ាងទៀត ទោះបីជាមានតម្រូវការគំនិតផ្តួចផ្តើមបន្ទាន់ក៏ដោយ ក៏ការចំណាយតិចសម្រាប់វិស័យអប់រំនៅតែជាបញ្ហារាំងស្ទះដល់គំនិតផ្តួចផ្តើមនេះដដែល ។ លើសពីនេះទស្សនៈគ្រួសារដែលគិតថា ការឱ្យកូនៗបន្តការសិក្សានឹងធ្វើឱ្យបាត់បង់ហិរញ្ញវត្ថុភ្លាមៗនោះកើតឡើងដោយការមិនឱ្យតម្លៃលើសិក្សា ដោយសារមិនទទួលបានព័ត៌មានអំពីចំណូលហិរញ្ញវត្ថុដែលកូនអាចរកបាន ប្រសិនបើកូនអាចបន្តការសិក្សាដល់កម្រិតមធ្យមសិក្សា និងការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។ ឧទាហរណ៍ ចំណូលហិរញ្ញវត្ថុនឹងកើន ៦០% សម្រាប់សិស្សបន្តការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាប្រៀបធៀបទៅនឹងការអប់រំបឋមសិក្សា និងចំណូលកើន ១១២% សម្រាប់សិស្សបន្តការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសក្រោយបញ្ចប់មធ្យមសិក្សា ប្រៀបធៀបទៅនឹងការអប់រំមធ្យមសិក្សាបឋមភូមិ ប៉ុន្តែសិស្សដែលមានចំណាប់អារម្មណ៍ចុះឈ្មោះចូលរៀនវគ្គអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានត្រឹមតែ ១៧% ប៉ុណ្ណោះ ។ ជាលទ្ធផល វត្តមានសិក្សាទាបនៅកម្រិតមធ្យមសិក្សាអំពាវនាវឱ្យមានកម្មវិធីសម្រាប់ឱកាសលើកទី២ និងការបណ្តុះបណ្តាលក្រៅប្រព័ន្ធ ។

ជាចុងក្រោយ ក្នុងការបង្កើតបំណិនកម្រិតខ្ពស់ ប្រទេសកម្ពុជាប្រឈមនឹងការសិក្សាមុខវិជ្ជាដែលមិនទាក់ទងនឹងទីផ្សារការងារ ដែលនេះជាបញ្ហាចម្បងខ្លាំងជាងបញ្ហាអត្រាចុះឈ្មោះចូលរៀនថ្នាក់ឧត្តមសិក្សា ដែលមានកម្រិតទាបទៅទៀត ។គ្រឹះស្ថានឧត្តមសិក្សារបស់ប្រទេសកម្ពុជាផ្តល់ជំនាញដល់សិស្សបញ្ចប់ការសិក្សារួមមាន ជំនាញគណនេយ្យ ហិរញ្ញវត្ថុ និងគ្រប់គ្រង (សិស្សថ្នាក់បរិញ្ញាបត្រចំនួនពាក់កណ្តាលចុះឈ្មោះចូលរៀនមុខវិជ្ជាទាំងនេះនៅឆ្នាំសិក្សា២០០៩/២០១០) ប្រៀបធៀបទៅនឹងមុខវិជ្ជាវិស្វកម្មស៊ីវិល (១,៥% ក្នុងចំណោមសិស្សចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រ) និងមុខវិជ្ជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (០,១% ក្នុងចំណោមសិស្សចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រ) ។ ទោះបីជាវិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទក្រៅពីផ្នែកកសិកម្ម ជាវិស័យសំខាន់សម្រាប់លើកកម្ពស់ក៏ដោយក៏មានសិស្សត្រឹមតែ ២,៣% ប៉ុណ្ណោះដែលសិក្សាមុខវិជ្ជាទាក់ទងនឹងចំណេះដឹងក្នុងវិស័យទាំងនេះ ។ ទាក់ទិននឹងការបកស្រាយបញ្ហានេះ ការអង្កេត

លើយុវជននាពេលថ្មីៗនេះបង្ហាញថា សិស្សមិនមានការយល់ដឹងច្បាស់ពីបំណិនដែលជាតម្រូវការរបស់និយោជកទេ និងមានឧបសគ្គក្នុងការទទួលព័ត៌មានដែលអាចទុកចិត្តបានស្តីពីការសិក្សា និងឱកាសទទួលបានការងារ ។

ជារួម បុព្វហេតុនៃការខ្វះខាត និងភាពមិនសមស្របនៃបំណិនរបស់ប្រទេសកម្ពុជា បង្ហាញឱ្យឃើញនៅផ្នែកព័ត៌មាន និងការសម្របសម្រួល ព្រមទាំងការផ្តល់ហិរញ្ញប្បទាន វិសាលភាព និងគុណភាពនៃវិស័យអប់រំ ។ និយោជកមានការខ្វះខាតមធ្យោបាយក្នុងការបង្ហាញពីតម្រូវការរបស់ខ្លួនលើបំណិនជាក់លាក់ និងឥទ្ធិពលលើគោលនយោបាយអភិវឌ្ឍន៍បំណិន ។ ការពង្រឹងក្រុមគណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB) ដើម្បីផ្តល់លទ្ធភាពដល់ក្រុមហ៊ុន បញ្ជូនតម្រូវការរបស់ខ្លួនទៅរដ្ឋាភិបាល និងការបណ្តុះបណ្តាលដល់

ផែនការសកម្មភាពអភិវឌ្ឍន៍បំណិន : សកម្មភាពអនុវត្តភ្លាមៗ និងការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ពេលអនាគត

| គោលបំណង | សកម្មភាពអនុវត្តបន្ទាន់ | ការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ពេលអនាគត |
|---|---|---|
| ១. ការទទួលបានព័ត៌មាន | • លើកកម្ពស់សមត្ថភាពក្នុងការប្រឹក្សាការងារ និងសេវាស្វែងរកការងារ<br>• ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដើម្បីបង្ហាញ ពីឱកាសសិក្សា និងការងារ និងការលើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | • លើកកម្ពស់សមត្ថភាពរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងភាពជាដៃគូជាមួយវិស័យឯកជន |
| ២. វិសាលភាព "ភាពចន្លោះនៅកម្រិតកណ្តាល" | • បញ្ច្រាបកម្មវិធីអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដែលមានគុណភាពល្អ | • ពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល ក្នុងកំណែទម្រង់ក្នុងកំណែទម្រង់ការអប់រំ និងបណ្តុះបណ្តាលនិយោជក<br>• ពិចារណាលើមធ្យោបាយជំរុញឱ្យនិយោជកចំណាយលើការបណ្តុះបណ្តាលកម្លាំងពលកម្មរបស់ខ្លួន |
| ៣. គុណភាព និងភាពពាក់ព័ន្ធនឹងទីផ្សារ | • ចាប់ផ្តើមបង្កើនចំនួនស្ថាប័ន បណ្តុះបណ្តាលបំណិន រួមមាន មជ្ឈមណ្ឌលបណ្តុះបណ្តាលក្រៅប្រព័ន្ធ ដោយការសហការជាមួយឧស្សាហកម្មក្នុងស្រុក | • កំណែទម្រង់កម្មវិធីសិក្សាមធ្យមសិក្សា ដើម្បីលើកកម្ពស់ការបង្រៀនវិទ្យាសាស្ត្រ គណិតវិទ្យា វិស្វកម្ម និងមុខវិជ្ជាបច្ចេកទេសផ្សេងទៀត ភាពជាសហគ្រិន និងបំណិនជីវិត<br>• ពង្រឹងការទទួលខុសត្រូវរបស់សហគមន៍ និងសាលារៀន ដែលជាផ្នែកមួយនៃដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ |
| ៤. ប្រសិទ្ធភាពហិរញ្ញប្បទាន | • ពង្រីកវិធីសាស្ត្រផ្តល់ហិរញ្ញប្បទានតម្រង់ទិសគ្រួសារ ដើម្បីអត្រាគង់វង្សនៃការសិក្សា | • បង្កើនការចំណាយលើបទអន្តរាគមន៍ ដែលមានការចំណាយតិចតួចនៅដំណាក់កាលដំបូងនៃវដ្តជីវិត<br>• ស្វែងរកវិធីសាស្ត្រហិរញ្ញប្បទាននានា ដើម្បីជំរុញឱ្យមានការលើកទឹកចិត្ត ចំពោះស្ថាប័នដែលមានលទ្ធផលបណ្តុះបណ្តាលល្អក្នុងចំណោមស្ថាប័នបណ្តុះបណ្តាលបំណិន រួមទាំងគ្រឹះស្ថានឧត្តមសិក្សា ។ |

សហគមន៏ អាចមានតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងព័ត៌មាន។ ចំណែកផ្នែកផ្គត់ផ្គង់វិញមានបុព្វហេតុនៃបញ្ហាមួយចំនួន ដូចជា បញ្ហាប្រឈមក្នុងការគ្រប់គ្រងធនធានតាមរបៀបមួយដែលលើកទឹកចិត្តដល់អ្នកបំពេញការងារល្អ និងមានការទទួលខុសត្រូវលើលទ្ធផល បញ្ហាប្រឈមក្នុងការបង្រៀនបំណិនជីវិត និងជំនាញបច្ចេកទេស និងភ្ជាប់ទំនាក់ទំនងរវាងសាលារៀន និងឧស្សាហកម្មឱ្យកាន់តែជិតស្និទ្ធដើម្បីលើកកម្ពស់គុណភាព និងទំនាក់ទំនងតម្រូវការទីផ្សារ។ លើសពីនេះ បុព្វហេតុទាំងនេះរាប់បញ្ចូលទាំងបញ្ហាប្រឈមក្នុងការបន្តផ្តល់ជំនួយដល់គ្រួសារ ដើម្បីរៀបចំឱ្យកុមារបានចូលរៀន។ ចុងក្រោយទីផ្សារបំណិនទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីស្ថាប័នទីផ្សារដែលមិនមានគុណភាព (ដូចជា យន្តការសម្របសម្រួលសេវាស្វែងរកការងារការធានាគុណភាព ការផ្តល់អាជ្ញាប័ណ្ណ បទប្បញ្ញត្តិ និងការទទួលស្គាល់គុណភាពអប់រំ) ដើម្បីភ្ជាប់ទំនាក់ទំនងរវាងតម្រូវការ និងការផ្តល់បំណិន។ ស្ថាប័នទីផ្សារមិនអាចរួមបញ្ចូលក្នុងវិស័យឯកជនបានទេ ដោយសារតែលក្ខណៈផលប្រយោជន៏សាធារណៈទាំងនោះ។

ការបំពេញគំនិតផ្តួចផ្តើមផ្នែកគោលនយោបាយកំពុងដំណើរការ ដូចនេះ ផែនការសកម្មភាពបំណិនរបស់ប្រទេសកម្ពុជា ចាំបាច់ត្រូវដោះស្រាយឧបសគ្គចម្បងសម្រាប់បំណិន ដើម្បីឈានទៅសម្រេចបំណងប្រាថ្នារបស់ខ្លួន។ ដោយសកម្មភាពនេះជាសកម្មភាពអាទិភាពបន្ទាន់ រដ្ឋាភិបាលអាចសម្របសម្រួលលទ្ធភាពទទួលបានព័ត៌មានក្នុងទីផ្សារបំណិន ពង្រីកអន្តរាគមន៏តម្រង់ទិសគ្រួសារ ដើម្បីលើកកម្ពស់អត្រាគង់វង្សនៃការសិក្សានិងពង្រឹងឱកាសសិក្សាលើកទី២ ព្រមទាំងការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ដើម្បីរៀបចំមូលដ្ឋានគ្រឹះសម្រាប់ពេលអនាគត រដ្ឋាភិបាលគួរពង្រីកហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍកុមារតូច ពង្រឹងការអភិវឌ្ឍស្ថាប័ន និងជំរុញឱ្យមានការលើកទឹកចិត្តចំពោះស្ថាប័នបណ្តុះបណ្តាលដែលមានគុណភាពល្អ រួមមាន គ្រឹះស្ថានឧត្តមសិក្សាជាដើម។ តារាងខាងក្រោមនេះ សង្ខេបពីសកម្មភាពដែលបានលើកឡើងសម្រាប់ធ្វើការពិចារណា។

# ១

# យុទ្ធសាស្ត្រកំណើនរបស់ប្រទេសកម្ពុជា ទាមទារឱ្យមានបំណិនល្អប្រសើរជាងមុន

ប្រទេសកម្ពុជាបានចាប់ផ្តើមបង្កើតមូលដ្ឋានគ្រឹះសម្រាប់ពិពិធកម្មសេដ្ឋកិច្ច និងសេដ្ឋកិច្ចផលិតកម្ម ។ ក្រោយពីកើតមានវិបត្តិ រដ្ឋាភិបាលមិនត្រឹមតែចាប់យកឱកាសរយៈពេលខ្លីសម្រាប់ការស្តារសេដ្ឋកិច្ចឡើងវិញនោះទេ ថែមទាំងដំណើរការយុទ្ធសាស្ត្រកំណើនរបស់ប្រទេសកម្ពុជាទៅដល់ដំណាក់កាលបន្ទាប់ដូចជាការឆ្ពោះទៅរកៈ ក) ការធ្វើពិពិធកម្មសេដ្ឋកិច្ច ផ្អែកលើឧត្តមភាពប្រៀបធៀបដែលមានស្រាប់ និង ខ) ធ្វើបច្ចុប្បន្នភាពទាយជ្ជទានដើម្បីបង្កើនឧត្តមភាពប្រៀបធៀបក្រៅពីការបញ្ចូលគោគទ្រព្យដី ស្ថានភាពយុទ្ធសាស្ត្រភូមិសាស្ត្រ និងកម្លាំងពលកម្មដែលមានតម្លៃទាប ។

ឧបសគ្គបំណិនដែលមានស្រាប់របស់ប្រទេសកម្ពុជា និងភាពលម្អៀងទៅរកឧស្សាហកម្មអតិពលកម្មដែលមានបំណិនទាបប៉ះពាល់ដល់យុទ្ធសាស្ត្រកំណើនរបស់ប្រទេស ។ ប្រាក់បៀវត្សរ៍ និងថ្លៃដើមពលកម្មទាប ដោយសារតែការផ្គត់ផ្គង់កម្លាំងពលកម្មដែលគ្មានជំនាញយ៉ាងច្រើននោះ ជះឥទ្ធិពលលើឧស្សាហកម្មជាច្រើនប្រភេទក្នុងប្រទេសកម្ពុជា ។ ផលិតកម្មអតិពលកម្ម ដែលមានបំណិនទាបត្រូវបានពង្រីកដោយការនាំចេញផលិតផលសម្លៀកបំពាក់តាមរដូវកាលមានចំនួន ៨៨% នៃការនាំចេញរបស់ប្រទេស ។ ក្នុងរយៈពេលដ៏ខ្លីប្រទេសកម្ពុជាមានការរំពឹងទុកថានឹងបន្តទាក់ទាញឧស្សាហកម្មអតិពលកម្មមានបំណិនទាប ដែលអាចប្រកួតប្រជែងក្នុងមូលដ្ឋានថ្លៃដើមពលកម្មទាប ។ ដោយសារប្រទេសកម្ពុជាមានមូលដ្ឋានធនធានមនុស្សមានកម្រិតទាបនោះ និន្នាការនេះបង្កឱ្យដំណើររបស់ខ្លួនមានភាពយឺតយ៉ាវក្នុងការឆ្លងឱ្យផុតពីកសិកម្មប្រើប្រាស់

---

២ សម្រាប់ការពិភាក្សា សូមមើលឯកសាររបស់ធនាគារពិភពលោក (ឆ្នាំ២០១០ A) យុទ្ធសាស្ត្រចតុកោណរបស់ប្រទេសកម្ពុជា ដើម្បីភាពរីកចម្រើនការងារ សមធម៌ និងប្រសិទ្ធភាព ផ្តោតលើវិស័យមួយចំនួន ដូចជា : កសិកម្ម ប្រព័ន្ធទឹក និងធារាសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ អគ្គិសនី ការអភិវឌ្ឍធនធានមនុស្ស ឧស្សាហកម្មអតិពលកម្ម និងឧស្សាហកម្មផលិតអាហារសម្រាប់នាំចេញ ទេសចរណ៍ ប្រេង ឧស្ម័នធម្មជាតិ និងរ៉ែផ្សេងៗទៀត បច្ចេកវិទ្យាព័ត៌មាន/គមនាគមន៍ និងជំនួញ ។

៣ រដ្ឋាភិបាលបានកំណត់វិស័យអាទិភាពចំនួន១៩ ដែលចាត់ទុកជាផ្នែកនៃយុទ្ធសាស្ត្រសមាហរណកម្មជំនួញរបស់ខ្លួន : ស្រាបៀរ គ្រាប់ស្វាយចន្ទី ដំឡូងឈើ ពោត ជលផល ស្បែកជើង កាត់ដេរ ការចិញ្ចឹមសត្វ អង្ករ កៅស៊ូ សូត្រ សណ្តែកសៀង ផ្លែឈើ និងបន្លែ ផលិតផលឈើ សមាគមបាត្តកម្មធុនស្រាល ទេសចរណ៍ សេវាពលកម្ម (រួមទាំងការសាងសង់) សេវាទាក់ទងនឹងការដឹកជញ្ជូន ដំណើរការអាជីវកម្ម/សេវាតាមប្រព័ន្ធអ៊ីនធើណេត ។

៤ បញ្ហាប្រឈមផ្នែកសម្របសម្រួល និងព័ត៌មាន ស្ថិតក្នុងឧបសគ្គបីសំខាន់ៗ ទន្ទឹមនឹងបញ្ហាប្រឈមនៃធនបម្រុង និងតម្លៃអគ្គិសនី និងភស្តុភារ ដែលរារាំងភាពរីកចម្រើនរបស់ប្រទេសកម្ពុជា (ធនាគារពិភពលោក ឆ្នាំ២០១០ A) ។ បញ្ហាប្រឈមផ្នែកធនបម្រុងសំដៅលើប្រព័ន្ធអន់ខ្សោយរបស់ប្រទេសកម្ពុជា ក្នុងការដោះស្រាយជម្លោះ និងការប្រឆាំងអំពើពុករលួយ ។ តម្លៃអគ្គិសនីខ្ពស់ និងថ្លៃដើម និងភស្តុភារ ដែលមិនអាចទុកចិត្តបាន (រួមទាំងជំនួញ) រារាំងសហគ្រិនពីការចូលរួមក្នុងគម្រោងដែលអាចដំណើរការបាន ។

បច្ចេកទេសអន់ថយ ធុរកិច្ចកសិកម្ម ហត្ថកម្មធុនស្រាល និងទេសចរណ៍ ដើម្បីឆ្ពោះទៅរកការប្រើប្រាស់បច្ចេកវិទ្យាកាន់តែទំនើប ។ ជាលទ្ធផល ភាពយឺតយ៉ាវនេះធ្វើឱ្យប៉ះពាល់ដល់ទឹកចិត្តរបស់និយោជិត/ស្ថាប័នផ្តល់ការងារក្នុងការចំណាយថវិកាលើការបណ្តុះបណ្តាលបំណិន ។

ការលើកកម្ពស់ និងការធ្វើពិពិធកម្មរចនាសម្ព័ន្ធឧស្សាហកម្មជួបប្រទះនឹងបញ្ហាប្រឈមជាច្រើននៅផ្នែកសម្របសម្រួល និងព័ត៌មាន ។ ជាពិសេស ការបរាជ័យពីការទទួលព័ត៌មាន និងការសម្របសម្រួលទីផ្សាររារាំងសហគ្រិនភាព និងការបង្កើតអាជីវកម្មថ្មី ដែលនេះនឹងអាចជួយបង្កើតការងារក្នុងវិស័យថ្មីទាក់ទងនឹងវិស័យសេដ្ឋកិច្ច ។ ការអង្កេតអំពីការធ្វើអាជីវកម្មដោយធនាគារពិភពលោកបង្ហាញថា ចំណាត់ថ្នាក់ប្រទេសកម្ពុជាស្ថិតក្នុងលេខរៀងទី ១៤៧ ក្នុងចំណោមប្រទេសចំនួន ១៨៣ នៅឆ្នាំ២០១០ ដោយបានលើកឡើងថា

ផែនការសកម្មភាពអភិវឌ្ឍន៍បំណិន : សកម្មភាពអនុវត្តភ្លាមៗ និងការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ពេលអនាគត

| | ការផ្តល់បំណិន | តម្រូវការបំណិន | |
|---|---|---|---|
| | ភាគរយនៃនិយោជិតមិនមានជំនាញដែលរាយការណ៍ដោយក្រុមហ៊ុន (%)៩ | ក្រុមហ៊ុនផ្តល់ការបណ្តុះបណ្តាលផ្លូវការដល់និយោជិត (%) | ក្រុមហ៊ុនរាយការណ៍ថាបំណិនកម្លាំងពលកម្មគឺជាឧបសគ្គចម្បង (%) |
| កម្ពុជា | ២៥,៧ | ៤៨,៣ | ១៥,៥ |
| ឥណ្ឌា | ៣៦,៣ | ១៥.៩ | ១៤,៥ |
| ឥណ្ឌូនេស៊ី | ២០,៤ | ៤,៧ | ៤,៥ |
| សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ | .. | ១១,១ | ១៨,៧ |
| ម៉ាឡេស៊ី | ៦៥,០ | ៥០,១ | ២០,២ |
| នេប៉ាល់ | ៣៥,៨ | ៨,៨ | ៥,៩ |
| ប៉ាគីស្ថាន | ១៩,១ | ៦,៧ | ៨,១ |
| ថៃ | ៨៣.៥ | ៧៥.៣ | ៣៨,៨ |
| វៀតណាម | ២០,៨ | ៤៣.៥ | ៨,៩ |
| ភាគរយមធ្យមសម្រាប់ប្រទេសដែលបានជ្រើសរើស | ៣៨,៣ | ២៩.៤ | ១៥,០ |
| ភាគរយមធ្យមពិភពលោក | ៣៣,៧ | ៣៤.១ | ២៦,១ |

**ប្រភព :** ការអង្កេតសហគ្រាសរបស់ធនាគារពិភពលោក ឆ្នាំ២០០៦ ដល់ឆ្នាំ២០០៩ ។ សម្រាប់វិធីសាស្ត្រក្នុងការគណនា សូមមើលធនាគារពិភពលោក ឆ្នាំ២០១១ ។
**កំណត់សម្គាល់ :** *សម្រាប់ប្រទេសមួយចំនួនទិន្នន័យការអង្កេត ឆ្នាំ២០០៦ ដល់ឆ្នាំ២០០៧ ផ្តោតលើភាគរយនិយោជិតដែលមិនមានជំនាញក្នុងវិស័យឧស្សាហកម្មតែប៉ុណ្ណោះ ។

៥ វិសមភាពប្រាក់ចំណូលក្នុងប្រទេសកម្ពុជាមានកម្រិតខ្ពស់ទៅតាមស្តង់ដាតំបន់ ដោយមានមេគុណ អិនិ ឈានដល់ ៤៥% ។ សម្រាប់ទិន្នន័យ សូមមើលទិន្នន័យមូលដ្ឋានតាមដានភាពក្រីក្រនៅតំបន់អាស៊ីបូព៌ា ។

៦ ស្រដៀងនឹងទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិផងដែរ (ឆ្នាំ២០១០) ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (ឆ្នាំ២០១១) បង្ហាញពីការធ្លាក់ចុះនៃអត្រាផ្តល់កំណើតសរុបពី ៤,០ ក្នុងឆ្នាំ២០០០ ដល់ ៣,០ ក្នុងឆ្នាំ២០១០ ។

ការបង្កើតអាជីវកម្មនៅប្រទេសកម្ពុជាត្រូវការការចំណាយច្រើន។ ការអង្កេតបរិយាកាសវិនិយោគបានកំណត់ថា អភិបាលកិច្ច គោលនយោបាយ បទប្បញ្ញត្តិ និងរដ្ឋបាល អមជាមួយអត្រាពន្ធ និងការប្រើប្រាស់អគ្គិសនី គឺជាឧបសគ្គចម្បងសម្រាប់ការអភិវឌ្ឍ។

ក្នុងទីផ្សារការងារ បញ្ហាប្រឈមផ្នែកព័ត៌មាន និងការសម្របសម្រួលចាត់ទុកជាបញ្ហាកង្វះខាតបំណិនរាំរៃ និងបំណិនលើសលុប។ សាលាមជ្ឈមណ្ឌលបណ្ដុះបណ្ដាលសិស្ស និងកម្មសិក្សាការី ហាក់បីដូចជាជាប់ក្នុងគំរូវិនិយោគដែលបន្តធ្វើឱ្យមានអតុល្យភាពបំណិន។ ខណៈពេលសេដ្ឋកិច្ចផ្ដោតការយកចិត្តទុកដាក់លើ

## រូបភាពទី១ : មុខរបរផ្នែកតាមការអប់រំក្នុងចំណោមអ្នកដែលមានអាយុចន្លោះចាប់ពី ២០ ដល់ ២៩ ឆ្នាំ ឆ្នាំ២០០៩




**ប្រភព :** ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២០០៩

## រូបភាពទី ២ : ការចុះឈ្មោះចូលរៀនមធ្យមសិក្សា និងកសិកម្ម គឺជាផ្នែកមួយនៃផលិតផលក្នុងស្រុកសរុប




**ប្រភព :** សូចនាករអភិវឌ្ឍន៍ពិភពលោក ឆ្នាំ២០១០

ផលិតកម្មដែលមានបំណិនទាប តម្រូវការបំណិនកម្រិតខ្ពស់ក្នុងវិស័យ និងការងារដែលបានជ្រើសរើស មិនអាចឈានទៅសម្រេចបានស្របពេលជាមួយគ្នានោះដែរ ។ ការខ្វះខាតព័ត៌មាន និងការសម្របសម្រួលទីផ្សារជាផ្នែកនៃបញ្ហាជារចនាសម្ព័ន្ធ ។

ជាពិសេសជាងនេះទៅទៀត បញ្ហាប្រឈមក្នុងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា រួមមាន ភាពក្រីក្រ និងកំណើនវិសមភាព ។ គ្រួសារច្រើនជាង ២ ភាគ ៣ ក្នុងបញ្ចភាគគ្រួសារមានចំណូលទាបបំផុតដែលមានជីវភាពពឹងផ្អែកលើកសិកម្ម និងវិសមភាពនៅតាមតំបន់ជនបទ គឺជាកត្តាចម្បងនៃកំណើនវិសមភាពក្នុងប្រទេសកម្ពុជា ។ ការវិភាគបង្ហាញថា ការកាត់បន្ថយភាពក្រីក្រ និងការផ្លាស់ប្តូរនិន្នាការនៃកំណើនវិសមភាព អាចនាំឱ្យមានការលើកកម្ពស់វិស័យកសិកម្ម និងបញ្ចេញកម្លាំងពលកម្មឱ្យបន្តការងារផ្សេងៗទៀតក្រៅពីវិស័យកសិកម្ម ។ ការធ្វើការងារផ្សេងៗទៀត ទាមទារឱ្យមានទីផ្សារ ការងារវិជ្ជាជីវៈ សហគ្រិនភាព និងមានលទ្ធភាពទទួលបានសេវាសាធារណៈមូលដ្ឋានប្រកបដោយសមធម៌ ដូចជា សេវាអប់រំ និងសេវាថែទាំសុខភាព ។ តម្រូវការទីផ្សារទាំងនេះក៏អាចគាំទ្រការរីកចម្រើននាពេលអនាគតរបស់ប្រទេសផងដែរ ។

ការជួបប្រទះនឹងបញ្ហាប្រឈមទាំងនេះ និងការអភិវឌ្ឍបំណិនមូលដ្ឋានឱ្យបានគ្រប់គ្រាន់មានសារៈសំខាន់ក្នុងការទទួលស្គាល់ពីសក្តានុពលរបស់យុវជនជាច្រើនរបស់ប្រទេសកម្ពុជាក្នុងការចូលរួមក្នុងកម្លាំងពលកម្ម ។ ប្រជាជនគ្រប់អាយុធ្វើការបានកើនឡើងពី ៥៤% ក្នុងឆ្នាំ១៩៩៨ រហូតដល់ ៦២% ក្នុងឆ្នាំ២០០៨ កត្តានេះបានកើតឡើង ដោយសារតែកំណើនចំនួនយុវជន (វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០១០) ។ ទោះបីជាប្រទេសកម្ពុជាកំពុងតែឆ្ពោះទៅរកការបញ្ចប់អន្តរកាលប្រជាសាស្ត្រ និងអត្រាផ្តល់កំណើតមានការធ្លាក់ចុះពី ៥,៣ ក្នុងឆ្នាំ១៩៩៨ ដល់ ៣,១ ក្នុងឆ្នាំ២០០៨ ក៏ដោយ (ដូច្នេះភាគរយនៃចំនួនកុមារមានការធ្លាក់ចុះក្នុងទសវត្សរ៍កន្លងមក) ក៏មានការរំពឹងថា នឹងមានការហូរចូលនូវកម្លាំងពលកម្មជាច្រើនជាបន្តបន្ទាប់ ។ បំណិននឹងកំណត់ពីសមត្ថភាពរបស់យុវជនក្នុងការចូលរួមក្នុងការងារផលិតកម្ម ឬសហគ្រិនភាព ។

បំណិននឹងមានឥទ្ធិពលលើឱកាសការងារនាពេលអនាគតរបស់ប្រទេសកម្ពុជា ។ ដោយប្រជាជន ៥៦% មានអាយុក្រោម ២៥ ឆ្នាំ ក្នុងឆ្នាំ២០០៨ នោះសមត្ថភាពរបស់យុវជនបច្ចុប្បន្នក្នុងការទទួលបានបំណិននឹងមានឥទ្ធិពលលើលទ្ធផលសេដ្ឋកិច្ច និងឱកាសរីកចម្រើនរបស់ប្រទេសកម្ពុជានាពេលអនាគត ។ ជាពិសេស ការប្រើប្រាស់បច្ចេកវិទ្យា និងការអភិវឌ្ឍបំណិនក្នុងជីវិតការងារអាចកំណត់បានតាមរយៈមូលដ្ឋានបំណិនដែលបានអភិវឌ្ឍនៅដំណាក់កាលដំបូងនៃជីវិត ។ ការអប់រំមានកម្រិតក្នុងចំណោមយុវជនដែលចូលរួមក្នុងកម្លាំងពលកម្មរបស់ប្រទេសកម្ពុជា រារាំងវិសាលភាពក្នុងការបង្កើតការងារដែលអាចទទួលយកបានព្រមទាំងការលើកកម្ពស់ឧស្សាហកម្ម និងការផ្លាស់ប្តូរបច្ចេកវិទ្យានាពេលអនាគត ។

ទោះបីជាបំណិនមិនមែនជាឧបសគ្គចម្បងរារាំងដល់ភាពរីកចម្រើនរបស់ប្រទេសកម្ពុជា ក្នុងបរិយាកាសបច្ចុប្បន្នក៏ដោយ ប៉ុន្តែបំណិននេះនឹងមានឥទ្ធិពលលើលទ្ធផលសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានាពេលអនាគត ។ ការវាយតម្លៃបរិយាកាសវិនិយោគនៅឆ្នាំ២០០៩ បានបង្ហាញថា ក្រុមហ៊ុនក្នុងប្រទេសកម្ពុជាបានចាត់

៧ សម្រាប់ការវិភាគ សូមមើល Di Gropello និង Sakellariou (ឆ្នាំ២០១០) ។ ប្រទេសដែលបានធ្វើការអង្កេត រួមមាន ប្រទេសកម្ពុជា ចិន ឥណ្ឌូនេស៊ី ម៉ុងហ្គោលី ហ្វីលីពីន ថៃ និងវៀតណាម ។ ការសិក្សាកំណត់និយោជិតដែលមានជំនាញថាជានិយោជិត ដែលមានការអប់រំមធ្យមសិក្សាទុតិយភូមិ និងការអប់រំខ្ពស់ជាងនេះ ។

ចំណាត់ថ្នាក់បំណិនថាជាឧបសគ្គសំខាន់បំផុតលំដាប់លេខ ៩ ក្នុងចំណោមឧបសគ្គទាំង ១៨ ដែលរារាំងការរីកចម្រើន (ធនាគារពិភពលោកឆ្នាំ២០០៩)។ ទោះបីជាយ៉ាងនេះក្តី ភាគរយនៃក្រុមហ៊ុនដែលរាយការណ៍ថា បំណិនជាឧបសគ្គចម្បងរារាំងការរីកចម្រើននៅក្នុងការអង្កេតនេះ បានកើនឡើងពី ៦,៥% ដល់ ១៥,៥% ក្នុងការអង្កេតស្រដៀងគ្នានៅឆ្នាំ២០០៣។ ក្រុមហ៊ុនបានបង្ហាញការយកចិត្តទុកដាក់លើបំណិន ហើយមានក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនពីរផ្តល់ការបណ្តុះបណ្តាលដល់និយោជិតរបស់ខ្លួន (តារាងទី ១)។ តាមរយៈបទពិសោធន៏បង្ហាញថា ការអប់រំមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយការងារផ្សេងៗក្រៅពីការងារកសិកម្ម (រូបភាពទី ១) និងការអប់រំកម្រិតមធ្យមសិក្សាផ្តល់គុណតម្លៃកាន់តែខ្ពស់បន្ថែមលើផលិតផលកសិកម្ម (រូបភាពទី ២) ដូច្នេះ ប្រសិនបើមិនមានការអភិវឌ្ឍទាន់ពេលវេលាទេ ការខ្វះខាតបំណិនមូលដ្ឋាននឹងរារាំងសមត្ថភាពរបស់ប្រទេសកម្ពុជាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន និងក្លាយជាប្រទេសដែលមានប្រាក់ចំណូលកណ្តាលនាពេលអនាគត ។ជាច្រើនទសវត្សរ៏កន្លងមកនេះ ប្រទេសកម្ពុជាបានលើកកម្ពស់បំណិនកម្លាំងពលកម្មរបស់ខ្លួនដែលកម្លាំងពលកម្មនេះមានការរីកចម្រើនយឺតជាងគេបើប្រៀបធៀបជាមួយប្រទេសដទៃទៀតក្នុងតំបន់អាស៊ីបូព៌ា។ ជាក់ស្តែង ប្រទេសកម្ពុជា និងម៉ុងហ្គោលី ជាប្រទេសចំនួនពីរគត់ ដែលបានធ្វើការអង្កេតក្នុងតំបន់ បង្ហាញឱ្យឃើញពីភាគរយនៃការឈប់ទ្រឹងរបស់និយោជិតជំនាញក្នុងចំណោមនិយោជិតដែលមានប្រាក់ចំណូល (តាមរយៈកំណើនភាគរយនៃនិយោជិតមានការអប់រំកម្រិតឧត្តមសិក្សាអាចកាត់បន្ថយផលប៉ះពាល់ ដោយសារការធ្លាក់ចុះភាគរយនៃនិយោជិតមានការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិនៅប្រទេសកម្ពុជា)។ នៅចន្លោះឆ្នាំ១៩៩៧ និងឆ្នាំ២០០៧ បុព្វលាភប្រាក់ឈ្នួលមានតុល្យភាព ដោយមិនរាប់បញ្ចូលប្រាក់ចំណូលសម្រាប់និយោជិតដែលបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សា ហើយតុល្យភាពនេះជាប្រភពនៃការមិនផ្លាស់ប្តូរបំណិន។ បុព្វលាភប្រាក់ឈ្នួលឧស្សាហកម្មក្នុងអំឡុងឆ្នាំនេះមានចំនួនលើសពីបុព្វលាភប្រាក់ឈ្នួលបំណិនដោយលើកឡើងថា បុព្វលាភឧស្សាហកម្មជាកត្តាជំរុញដ៏សំខាន់នៃភាពខុសគ្នារវាងប្រាក់ឈ្នួលក្នុងវិស័យសេដ្ឋកិច្ច។ ផ្ទុយទៅវិញ របាយបុព្វលាភឧស្សាហកម្មកាន់តែខ្ពស់បង្ហាញថា មានការបែងចែកទីផ្សារការងារកាន់តែច្រើននៅប្រទេសកម្ពុជាជាងប្រទេសផ្សេងៗទៀតដែលបានធ្វើការអង្កេតនៅក្នុងតំបន់ (Di Gropello និង Sakellariou ឆ្នាំ២០១០)។

ការខ្វះខាតបំណិនរាំរ៉ែដះឥទ្ធិពលអវិជ្ជមានលើការវិនិយោគផ្ទាល់របស់បរទេស និងការនាំទៅរកភាពរីកចម្រើននៃបច្ចេកវិទ្យា។ ក្នុងការអង្កេតបរិយាកាសវិនិយោគឆ្នាំ២០០៧ បង្ហាញថាក្រុមហ៊ុនបរទេសនៅប្រទេសកម្ពុជាចំនួន ២២% (ប្រៀបធៀបនឹងចំនួនមធ្យម ១៥,៥% នៃក្រុមហ៊ុនទាំងអស់) បានបញ្ជាក់ថា បំណិន គឺជាឧបសគ្គ "ធ្ងន់ធ្ងរ ឬធ្ងន់ធ្ងរបំផុត" ក្នុងការធ្វើអាជីវកម្មរបស់ពួកគេ។ ក្នុងការវិនិយោគផ្ទាល់ពីបរទេសមានទំនាក់ទំនងវិជ្ជមានជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាទំនើប និងកម្លាំងពលកម្មដែលមានជំនាញនោះ ការវិនិយោគផ្ទាល់ពីបរទេសថ្មីត្រូវការចំណាយសម្រាប់ឱកាសការងារ។ លើសពីនេះទិន្នន័យទទួលបានពីប្រទេសកម្ពុជា និងប្រទេសដទៃទៀតនៅតំបន់អាស៊ីបូព៌ាបង្ហាញថា ក្រុមហ៊ុនដែលអ្នកគ្រប់គ្រងមានការអប់រំខ្ពស់ (តំណាងអ្នកគ្រប់គ្រងដែលមានការអប់រំខ្ពស់ជាងមធ្យមសិក្សា) មានទំនោរជ្រើសរើសបុគ្គលិកដែលមានការអប់រំខ្ពស់ផងដែរ (Almeida ឆ្នាំ២០០៩)។

ប្រទេសកម្ពុជាមានការរំពឹងទុកថា នឹងឈានទៅដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍនៅពេលដែលឧត្តមភាពប្រៀបធៀបនៃថ្លៃដើមកម្លាំងពលកម្មទាបរបស់ខ្លួនត្រូវបានប្រើប្រាស់អស់ ហើយប្រាក់ឈ្នួលចាប់ផ្តើមកើនឡើង។ គំរូបែបនេះ កើតមាននៅគ្រប់ទីផ្សារសេដ្ឋកិច្ច ដែលមានស្ថានភាពប្រាក់ចំណូលខ្ពស់ និងសេដ្ឋកិច្ចដែលទាមទារចំណេះដឹងខ្ពស់។ ប្រសិនបើទីផ្សារការងារដំណើរការប្រកបដោយប្រសិទ្ធភាពនោះ

នឹងបង្ហាញឱ្យឃើញពីអន្តរកាលនេះ តាមរយៈការតម្លើងប្រាក់ឈ្នួលរបស់និយោជិតដែលមានបំណិនទាប នៅពេលលែងមាននិយោជិតបែបនេះ ហើយការបង្កើនប្រាក់ឈ្នួលនេះ ក្រុមហ៊ុននឹងផ្តល់ការវិនិយោគជាទុនបន្ថែម និងបង្កើនតម្រូវការនិយោជិតដែលមានជំនាញ។ ការបង្កើនទុននាំមកនូវបច្ចេកវិទ្យាថ្មីដែលនាំឱ្យមានការផ្លាស់ប្តូរបច្ចេកទេសដែលមានភាពលម្អៀងលើជំនាញ។ នៅពេលនោះ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានឹងផ្លាស់ប្តូរពីការប្រកួតប្រជែងលើមូលដ្ឋាននៃប្រាក់ឈ្នួលទាបទៅជាការប្រកួតប្រជែងលើមូលដ្ឋាននៃផលិតភាពខ្ពស់។ គំរូនេះបានកើតឡើងជាបន្តបន្ទាប់នៅប្រទេសកូរ៉េ តៃវ៉ាន់ និងហុងកុង ហើយបច្ចុប្បន្ននេះ គេឃើញមានគំរូបែបនេះនៅខេត្តក្វាងតុង និងខេត្តដទៃទៀតនៅតាមតំបន់ឆ្នេរខាងកើតរបស់ប្រទេសចិន។

ការរង់ចាំរហូតសម្រេចបានចំណុចអន្តរកាលនេះ ដើម្បីអនុវត្តសកម្មភាពលើរបៀបវារៈបំណិន បណ្តាលឱ្យមានភាពយឺតយ៉ាវក្នុងការបង្កើតគោលនយោបាយស្ថាប័ន និងការអភិវឌ្ឍសមត្ថភាពដែលជាតម្រូវការសម្រាប់សេដ្ឋកិច្ចសម័យទំនើប។ ការបង្កើតគោលនយោបាយ ស្ថាប័ន និងការអភិវឌ្ឍសមត្ថភាព ដើម្បីសម្របសម្រួលការអភិវឌ្ឍបំណិន ទាមទារឱ្យមានពេលវេលាគ្រប់គ្រាន់។ នៅឆ្នាំ១៩៨០ ប្រទេសកូរ៉េបានចាប់ផ្តើមកសាងសមត្ថភាព នៃប្រព័ន្ធអប់រំកម្រិតឧត្តមសិក្សាត្រៀមទុកជាមុនសម្រាប់តម្រូវការជាក់ស្តែងរបស់សិស្សបញ្ចប់ការសិក្សាកម្រិតឧត្តម។ ដោយពិចារណាលើតម្រូវការពេលវេលា ទោះបីជាបំណិនមិនមែនជាចំណុចសំខាន់ក្នុងរបៀបវារៈ នៃបរិយាកាសវិនិយោគបច្ចុប្បន្នរបស់ប្រទេសកម្ពុជាក៏ដោយ ក៏រដ្ឋាភិបាលនៅតែនូវបន្តអនុវត្តរបៀបវារៈស្តីពីបំណិន ដើម្បីបង្កើតមូលដ្ឋានគ្រឹះសម្រាប់សេដ្ឋកិច្ចពិពិធកម្ម និងសេដ្ឋកិច្ចផលិតកម្ម។

បំណិនកម្លាំងពលកម្ម នឹងសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ ការលើកកម្ពស់បំណិនកម្លាំងពលកម្មនឹងជំរុញឱ្យមានការធ្វើពិពិធកម្មសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម និងភាពរីកចម្រើននៃឧត្តមភាពប្រៀបធៀបរបស់ប្រទេសកម្ពុជាក្នុងរយៈពេលយូរ។ ការរីកចម្រើនទាំងនេះនឹងជួយសម្រួលដល់ការលើកកម្ពស់ខ្សែសង្វាក់តម្លៃរបស់ក្រុមហ៊ុនកម្ពុជា និងបង្កើនសហគ្រិនភាព ព្រមទាំងការបង្កើតសហគ្រាសធុនតូច និងមធ្យមដោយគាំទ្រឱ្យមានការបង្កើតការងារ។ បំណិនក៏អាចជួយលើកកម្ពស់វិស័យកសិកម្ម និងបង្កើនតម្លៃបន្ថែមនៅតាមនៅកន្លែងផលិត និងទីផ្សារលក់ផលិតផល តាមរយៈការគ្រប់គ្រងដី និងធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងតាមរយៈការផ្លាស់ប្តូរកម្លាំងពលកម្មពីវិស័យកសិកម្មទៅឧស្សាហកម្ម និងសេវាកម្មដែលនាំមកនូវប្រាក់ចំណូលខ្ពស់។ លើសពីនេះ បំណិននឹងជួយរដ្ឋាភិបាលក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងសម្របសម្រួលភាពរីកចម្រើន និងផ្តល់មូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់សេវាសង្គម និងរដ្ឋបាលសាធារណៈ ដែលមានប្រសិទ្ធភាពក្នុងបរិយាកាសវិមជ្ឈការក្នុងប្រទេសកម្ពុជា។

# ២

# តើភាពមិនសមស្របនៃបំណិន និងបុព្វហេតុនៃភាពមិនសមស្រប មានលក្ខណៈដូចម្ដេច?

ដើម្បីវិភាគពីភស្តុតាងដែលមានស្ដីពីការខ្វះខាត និងភាពមិនសមស្របនៃបំណិនក្នុងប្រទេសកម្ពុជា ផ្នែកនេះបង្ហាញឱ្យឃើញពីស្ថានភាពកើតចេញពីការរំពឹងទុករបស់និយោជក និងស្ថាប័នបណ្ដុះបណ្ដាលជំនាញជាពិសេស មិនត្រឹមតែផ្ដោតទៅលើប្រព័ន្ធអប់រំតែមួយនោះទេ។ ផ្នែកនេះបង្ហាញពីអតុល្យភាពបំណិនសំខាន់ៗជាច្រើន ដែលនឹងប៉ះពាល់ដល់វិស័យសេដ្ឋកិច្ចនាពេលខាងមុខ។ ជាចុងក្រោយ ផ្នែកនេះក៏បង្ហាញពីបុព្វហេតុចម្បងនៃការខ្វះខាត និងភាពមិនស្របដែលទាក់ទងនឹងការបរាជ័យទីផ្សារ និងចង្អុលបង្ហាញពីសកម្មភាពសំខាន់ៗដើម្បីដោះស្រាយបញ្ហានេះ។

## ២.១ តើនិយោជកប្រឈមនឹងការខ្វះខាត និងភាពមិនសមស្របនៃបំណិនអ្វីខ្លះ?

### ប្រអប់ទី១ : តើ "បំណិនជីវិត" គឺជាអ្វី?

ជាទូទៅ បំណិន "ជីវិត" សំដៅលើសមត្ថភាព និងឥរិយាបថបុគ្គល ដែលផ្ដល់លទ្ធភាពដល់បុគ្គលក្នុងការដោះស្រាយតម្រូវការ និងបញ្ហាប្រឈមនានាក្នុងជីវភាពប្រចាំថ្ងៃប្រកបដោយប្រសិទ្ធភាព។ ឧ. ការដោះស្រាយបញ្ហាគំនិតច្នៃប្រឌិត ការប្រាស្រ័យទាក់ទង និងការធ្វើការងារជាក្រុម។

យោងតាមរបាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ២០០៧ (ធនាគារពិភពលោក ឆ្នាំ២០០៦) បំណិនជីវិតអាចបែងចែកជាពីរក្រុម : ក) បំណិននៃការគិតមានដូចជាការត្រិះរិះពិចារណា និងការគិតប្រកបដោយការច្នៃប្រឌិត និង ខ) បំណិនខាងអាកប្បកិរិយា រួមមាន ភាពឧស្សាហ៍ព្យាយាម ភាពម្ចាស់ការលើខ្លួនឯង ការធ្វើការងារជាក្រុម និងសមត្ថភាពសម្រុះសម្រួលជម្លោះ និងការគ្រប់គ្រងហានិភ័យ។

ទោះបីជាការខ្វះខាតបំណិន មិនមែនជាឧបសគ្គធ្ងន់ធ្ងរប៉ះពាល់ដល់លទ្ធផលនៃភាពរីកចម្រើនក៏ដោយ ក៏ការខ្វះខាតបំណិន នៅតែកើនឡើងជាបន្តបន្ទាប់នៅតាមវិស័យជាក់លាក់។ និយោជកបានចង្អុលបង្ហាញពីអតុល្យភាពជារចនាសម្ព័ន្ធក្នុងការផ្ដល់បំណិន រួមទាំងបញ្ហាពាក់ព័ន្ធ នឹងការខ្វះខាតសិស្សបញ្ចប់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ប្រៀបធៀបទៅនឹងសិស្សបញ្ចប់ការសិក្សាកម្រិតឧត្ដមសិក្សា និងការខ្វះខាតយ៉ាងខ្លាំងនូវសិស្សបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រ "ដោយមានបំណិនត្រឹមត្រូវ"។ នៅឆ្នាំ២០០៨ ការអង្កេតនិយោជកចំនួន ២២០ នាក់ របស់ CAMFEBA (ឆ្នាំ២០០៨) បង្ហាញថាមាននិយោជកចំនួន ១៣% ប៉ុណ្ណោះ ដែលឯកភាពថាបណ្ដាសិស្សបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រ មានបំណិនត្រឹមត្រូវ "ទាំងស្រុង ឬស្ទើរតែទាំងស្រុង" សម្រាប់ទីផ្សារការងារ ចំណែកនិយោជក ១១% បានឱ្យដឹងថា យុវជនមិនមានបំណិនត្រឹមត្រូវឆ្លើយតបនឹងការងារនោះទេ។ ក្នុងការអង្កេតលើវិស័យ ដែលមានការរីកចម្រើនខ្លាំងចំនួន ៣ ក្រៅពីវិស័យកសិកម្ម (ដូចជា វិស័យ

បំណិនជីវិតខាងអាកប្បកិរិយាមួយចំនួនទៀត ដូចជា ការគោរពពេលវេលា និងការធ្វើការងារជាក្រុម អាចរៀនបាននៅពេលបំពេញការងារ ។ ផ្ទុយទៅវិញ ភាពជាម្ចាស់ការលើខ្លួនឯង គឺចាំបាច់ត្រូវតែមានតាំងពីកុមារភាពមកម្ល៉េះ ។ បំណិន នៃការគិតអាចរៀនបានក្នុងស្ថាប័នអប់រំ ដូចជា សាលារៀន និងមជ្ឈមណ្ឌលបណ្ដុះបណ្ដាល ។

អក្សរសាស្ត្រនាពេលបច្ចុប្បន្ននេះ កំណត់ពីសារៈសំខាន់នៃបំណិនជីវិត ទាំងក្នុងដំណើរការនៃការអភិវឌ្ឍមូលធន មនុស្ស និងជាកត្តាកំណត់លទ្ធផលនៃការសិក្សានិងការងារ ។

ជាទូទៅ បំណិន "ជីវិត" បំពេញបន្ថែមលើជំនាញ "បច្ចេកទេស" ដែលជាសមត្ថភាពផ្នែកបច្ចេកទេសទាក់ទងនឹងការងារនិងសកម្មភាព ។ ឧទាហរណ៍ជំនាញបច្ចេកទេសរួមមានដំណើរការគ្រឿងម៉ាស៊ីន និងអក្ខរកម្មកុំព្យូទ័រ ។ ជំនាញទាំងនេះមានភាពងាយស្រួលក្នុងការអង្កេត និងកំណត់បរិមាណ និងអាចបង្រៀនបាននៅតាមសាលារៀន ឬកន្លែងធ្វើការ ។

កាត់ដេរ ទេសចរណ៍ និងសំណង់) មានក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនចំនួន ៥ បានរាយការណ៍ថា សិស្សបញ្ចប់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ (មានន័យថា ជាសិស្សទទួលបានការបណ្ដុះបណ្ដាលសម្រាប់ការងារជាក់លាក់) មានបំណិនសំខាន់ៗក្នុងការអនុវត្តការងាររបស់ខ្លួន (HRINC ឆ្នាំ២០១០) ។

ការអង្កេតផ្សេងទៀតបង្ហាញពីភាពមិនសមស្របនៃបំណិន ។ ក្នុងការអង្កេតថ្មីមួយលើនិយោជក ៧៨ នាក់របស់ HRINC (ឆ្នាំ២០១១) និយោជក ៧៣% បានរាយការណ៍ថា សិស្សបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សា ពុំមានបំណិនត្រឹមត្រូវនោះទេ (ទន្ទឹមនឹងនោះ និយោជក ១២% និយាយថា ចំនួនសិស្សបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សា មិនទាន់មានចំនួនគ្រប់គ្រាន់នៅឡើយ) ។ និយោជក ៦២% បានកត់សម្គាល់ឃើញថា សិស្សបញ្ចប់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ មិនមានបំណិនត្រឹមត្រូវឆ្លើយតបនឹងការងារនោះទេ (ចំណែកនិយោជក ៣៨% បានលើកឡើងថាសិស្សបញ្ចប់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈមានចំនួនតិចតួចណាស់) ។ លើសពីនេះនិយោជក ៣១% កត់សម្គាល់ឃើញថា ការបណ្ដុះបណ្ដាល ឬការលើកកម្ពស់កម្លាំងពលកម្ម គឺជាការលំបាកមួយដែលការងារនេះអាចបណ្ដាលមកពីគុណភាពទាបនៃកម្មវិធីបណ្ដុះបណ្ដាលនិងភាពទន់ខ្សោយនៃមូលដ្ឋានបំណិនសម្រាប់ការបណ្ដុះបណ្ដាលបន្ថែម ការអង្កេតលើក្រុមហ៊ុននាំមុខគេចំនួន ២៤ របស់ HRINC (ឆ្នាំ ២០១០) បានបង្ហាញថា និយោជក ៦៣% យល់ឃើញថា ការស្វែងរកបំណិនសមស្របតាមតម្រូវការទីផ្សារមានការលំបាកជាងមុន ។ ទោះបីជាគ្មានការរារាំងប្រតិបត្តិការការងារនាពេលបច្ចុប្បន្នរបស់ក្រុមហ៊ុនក៏ដោយ ក៏ការខ្វះខាតបំណិនបច្ចេកទេសបង្កភាពស្មុគ្រស្មាញដល់ការប្រើប្រាស់បច្ចេកវិទ្យាថ្មី និងបច្ចេកវិទ្យាផលិតកម្ម ។ ឧទាហរណ៍ រដ្ឋាភិបាលបានទទួលស្គាល់បញ្ហាទាំងនេះក្នុងវេទិកាសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១១ និងរបាយការណ៍ថ្មីៗមួយ ដែលចេញផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ (ឆ្នាំ២០១០) ។

ការអង្កេតរបស់និយោជកមួយចំនួនបង្ហាញថា ប្រទេសកម្ពុជាកំពុងប្រឈមនឹងការខ្វះខាតបំណិនគ្រប់គ្រង ។ តាមរយៈព័ត៌មានបានបង្ហាញថា បំណិនដែលខ្វះខាតបំផុត និងបំណិនដែលនិយោជកយល់ឃើញថាជាឧបសគ្គចម្បងនោះ គឺបំណិនគ្រប់គ្រងជាន់ខ្ពស់ ។ ក្នុងការអង្កេតឆ្នាំ២០១១ របស់ HRINC និយោជកលើសពី

៨ ធនាគារពិភពលោក ឆ្នាំ២០១០ ខ និង HRINC ឆ្នាំ២០១១ ។ ការអង្កេតដោយប្រុងប្រយ័ត្នស្ដីពីនិយោជក និងនិយោជិត ចាំបាច់ត្រូវផ្ដល់ភស្តុតាងដែលអាចទុកចិត្តបានទាក់ទងនឹងវិសាលភាព និងប្រភេទជាក់លាក់នៃការខ្វះខាត និងភាពមិនសមស្របនៃបំណិន ។

៩ នាពេលថ្មីៗនេះ មជ្ឈមណ្ឌលអភិវឌ្ឍន៏បំណិនកម្ពុជា បានកំណត់ពីអាទិភាពលើការបណ្ដុះបណ្ដាលរបស់និយោជកយ៉ាងល្អិតល្អន់ថាជាផ្នែកនៃការសិក្សាមួយដែលត្រូវរក្សាការសម្ងាត់ ដោយលើកឡើងពីចំណុចសំខាន់ៗនៃបំណិនទំនាក់ទំនងរវាងបុគ្គលបំណិនធនធានមនុស្ស និងទំនាក់ទំនងវិជ្ជាជីវៈ បំណិនផ្នែកលក់ និងទីផ្សារ បំណិនធុរកិច្ច និងគិតលេខ និងបំណិនគ្រប់គ្រងហិរញ្ញវត្ថុ ។

៧០% បានរាយការណ៍ពីការខ្វះខាតជាចម្បងនូវបំណិនគ្រប់គ្រងក្នុងនោះនិយោជក ៣៦% រាយការណ៍ពីការខ្វះខាតបំណិនគ្រប់គ្រងថ្នាក់កណ្តាល និងបំណិនផ្នែកអភិបាលកិច្ច ហើយនិយោជក ៣៤% រាយការណ៍ពីការខ្វះខាតបំណិនបុគ្គលិកជំនាញ។ និយោជកចំនួន ៦៤% គិតថាការខ្វះខាតបំណិនគ្រប់គ្រង គឺជាឧបសគ្គចម្បង និយោជកចំនួន ៤៨% គិតថា ការខ្វះខាតបំណិនគ្រប់គ្រងថ្នាក់កណ្តាលជាឧបសគ្គចម្បងដោយឡែកនិយោជកចំនួន ៥០% គិតថា ការខ្វះខាតបំណិនផ្នែកអភិបាលកិច្ច និងបំណិនបុគ្គលិកជំនាញទើបជាឧបសគ្គចម្បង។ ក្នុងស្ថាប័នរដ្ឋបាល និងវិស័យរដ្ឋបាលសាធារណៈក៏ប្រហែលជាខ្វះខាតបំណិនគ្រប់គ្រងផងដែរ ជាពិសេស ក្នុងដំណើរការអនុវត្តប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការដែលទាមទារឱ្យមានបំណិនទូលំទូលាយសម្រាប់វិភាគ និងអនុវត្តគោលនយោបាយក្នុងវិស័យសាធារណៈ។

បន្ទាប់មក និយោជកលើកឡើងពីការកើនឡើងតម្រូវការរបស់និយោជិត ដែលមិនមានការឆ្លើយតបនៅឡើយ រួមមាន បំណិនជីវិត និងបំណិនបច្ចេកទេស។ (សម្រាប់សេចក្តីលម្អិតពីបំណិនជីវិត សូមមើលប្រអប់ទី១។) ក្នុងប្រព័ន្ធអប់រំចាប់ពីថ្នាក់ទាបដល់ថ្នាក់ខ្ពស់ មិនមានការផ្តល់បំណិនជីវិត និងបំណិនបច្ចេកទេសឱ្យបានគ្រប់គ្រាន់ទេ រួមទាំងក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ។ ជាពិសេស និយោជកកំណត់ថាបំណិនជីវិត គឺជាបំណិនសំខាន់បំផុតដែលនិយោជិតភាគច្រើនមានការខ្វះខាត។ ក្នុងការអង្កេតរបស់ CAMFEBA ឆ្នាំ២០០៨ និយោជកចំនួន ៧៦% បានយល់ឃើញថា និយោជិតដែលបានបញ្ចប់ការសិក្សាមិនបានទទួលការបណ្តុះបណ្តាលគ្រប់បំណិននោះទេ ជាពិសេស បំណិនជីវិតក្រៅពីសមត្ថភាពបច្ចេកទេសដែលមានសារៈសំខាន់ក្នុងការអនុវត្តការងារ។ ក្នុងចំណោមបំណិនជីវិត ដែលមានភាពលំបាកក្នុងការស្វែងរកនិយោជកបានកំណត់ពីបំណិនជីវិតមួយចំនួន ដែលក្នុងនោះ មាននិយោជក ៥២% បានកំណត់ពីឥរិយាបថការងាររបស់និយោជិតមិនមានជំនាញនិយោជក ៤៥% បានលើកឡើងពីបំណិនក្នុងការសម្រេចចិត្តរបស់និយោជិតមានជំនាញមិនច្បាស់លាស់ និងនិយោជក ៦៤% បានលើកឡើងពីបំណិនវិភាគរបស់និយោជិតជំនាញ។ និយោជកជាច្រើន ក៏បានត្អូញត្អែរពីភាពខ្វះខាតបំណិនក្នុងភាពជាអ្នកដឹកនាំ (សម្រាប់បុគ្គលិកជាអ្នកគ្រប់គ្រង) បំណិនដោះស្រាយបញ្ហា និងបំណិនក្នុងការប្រាស្រ័យទាក់ទង។ ក្រៅពីនេះ យុវជនក្រៅសាលាប្រឈមនឹងភាពខ្វះខាតដ៏ធ្ងន់ធ្ងរនៃបំណិនជីវិត ហើយមាននិយោជកចំនួន ៨៩% បានបង្ហាញពីភាពលំបាកក្នុងការធ្វើការជាមួយយុវជនក្រៅសាលាដោយសារពួកគេមានអាកប្បកិរិយាមិនសមរម្យ។

បន្ទាប់មក និយោជកលើកឡើងពីភាពលំបាកក្នុងការស្វែងរកនិយោជិតដែលមានបំណិនវិជ្ជាជីវៈ និងការងារជាក់លាក់។ ដូចបានលើកឡើងក្នុងរបាយការណ៍របស់ធនាគារពិភពលោក (ឆ្នាំ២០១០ ខ) បំណិនពាក់ព័ន្ធនឹងភាសាបរទេស ព័ត៌មានវិទ្យា កាត់ដេរ ជាងតប្រព័ន្ធទឹក ជាងឈើ និងជាងដែក គឺសុទ្ធតែជាបំណិនដែលមានតម្រូវការខ្ពស់ ប៉ុន្តែបំណិនទាំងនេះមានភាពលំបាកក្នុងការស្វែងរក។ ក្នុងវិស័យបដិសណ្ឋារកិច្ចនិយោជកលើកឡើងពីភាពលំបាកក្នុងការស្វែងរកមេចុងភៅ អ្នកទទួលភ្ញៀវ និងអ្នកគ្រប់គ្រងផ្នែកអាហារនិងភេសជ្ជៈ។ ក្នុងវិស័យកាត់ដេរ មុខតំណែងផ្នែកលក់ និងកាត់ដេរ គឺជាបំណិនដែលមានភាពលំបាកក្នុងការស្វែងរក។ ចំណែកក្នុងវិស័យសំណង់វិញ មានការលំបាកក្នុងការជ្រើសរើសនិយោជិតជាជាងឈើជាងតប្រព័ន្ធទឹក ជាងដែក និងជាងអគ្គិសនី។

បន្ថែមពីនេះទៀត និយោជកមានការត្អូញត្អែរពីការលំបាកក្នុងការស្វែងរកនិយោជិត ដែលមានបំណិនវិជ្ជាជីវៈច្បាស់លាស់ និងមានបំណិនមូលដ្ឋាន ដូចជា អក្ខរកម្ម និងការគណនាលេខនព្វន្ត។ នេះបង្ហាញឱ្យឃើញពីអត្រាអក្ខរកម្មទាប ដែលមានចំនួន ៧៧,៦% នៃប្រជាជនកម្ពុជាអាយុ ១៥ ឆ្នាំ និងលើសពីនេះ

(អត្រាអក្ខរកម្មមានចំនួន ៨៧,៥% ក្នុងចំណោមប្រជាជនមានអាយុចាប់ពី ១៥-២៤ ឆ្នាំ) ដែលធ្វើឱ្យប្រសិទ្ធភាពនៃការបណ្ដុះបណ្ដាលនៅដំណាក់កាលបន្ទាប់មានការធ្លាក់ចុះ ។

ដើម្បីដោះស្រាយភាពខ្វះខាតបំណិនមួយចំនួន និយោជកជាច្រើនបានចូលរួមផ្ដល់ការបណ្ដុះបណ្ដាលផ្លូវការ ។ CAMFEBA (ឆ្នាំ២០០៨) បានបង្ហាញថា និយោជកខិតខំប្រឹងប្រែងផ្ដល់ការបណ្ដុះបណ្ដាលបំណិនសំខាន់ដូចតទៅ : បំណិនបច្ចេកទេស បំណិនក្នុងការសម្រេចចិត្ត និងដោះស្រាយបញ្ហាបំណិនក្នុងការប្រាស្រ័យទាក់ទងការងារជាក្រុម និងភាពជាអ្នកដឹកនាំបំណិនផ្នែកទីផ្សារ បំណិនផ្នែកលក់ និងបំណិនផ្ដល់សេវា ។ បំណិនទាំងនេះមិនមានបង្រៀនក្នុងសាលារៀន និងមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈទេ ។ ការអង្កេតធ្វើឡើងសម្រាប់ឯកសារគោលនយោបាយនេះ បានបង្ហាញឱ្យឃើញថា និយោជក ៩៥% ផ្ដល់ការបណ្ដុះបណ្ដាលដល់និយោជិតរបស់ខ្លួន យ៉ាងហោចណាស់ពាក់កណ្ដាលនៃនិយោជិតទាំងអស់ ចំណែកនិយោជកជាច្រើនទៀត ផ្ដល់ការបណ្ដុះបណ្ដាលដល់កម្លាំងពលកម្មរបស់ខ្លួនតែមួយចំនួនតូចប៉ុណ្ណោះ (ការអង្កេតរបស់ HRINC ឆ្នាំ២០១១) ។ ដើម្បីផ្ដល់ការបណ្ដុះបណ្ដាលបែបនេះបាន ជាទូទៅ និយោជក ៥៣% ប្រើប្រាស់កម្មវិធីក្នុងក្រុមហ៊ុនរបស់ខ្លួន និយោជក ៤៣% ប្រើប្រាស់ស្ថាប័នបណ្ដុះបណ្ដាលក្នុងស្រុក ហើយមាននិយោជក ២៧% ប្រើប្រាស់ស្ថាប័នបណ្ដុះបណ្ដាលបរទេស ជាពិសេស សម្រាប់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ។ និយោជកមានបំណងផ្ដល់ការបណ្ដុះបណ្ដាលដល់និយោជិតណាដែលមានបំណិនមូលដ្ឋាន ។ ការខ្វះខាតស្ថាប័នបណ្ដុះបណ្ដាលល្អ បង្កជាឧបសគ្គដល់ការផ្ដល់ការបណ្ដុះបណ្ដាលរបស់សហគ្រាស ។ តាមរយៈការអង្កេតរបស់ HRINC ឆ្នាំ២០១១ និយោជកចំនួន ៦៤% បានកំណត់ថា ការខ្វះខាតស្ថាប័នបណ្ដុះបណ្ដាលល្អ គឺជាឧបសគ្គចម្បងតែមួយគត់ក្នុងការផ្ដល់ការបណ្ដុះបណ្ដាលឱ្យបានពេញលេញដល់និយោជិត ។ ឧបសគ្គចម្បងដទៃទៀត រួមមាន ថ្លៃបណ្ដុះបណ្ដាលខ្ពស់ ការមិនមានពេលវេលាគ្រប់គ្រាន់ អត្រាផ្លាស់ប្ដូរបុគ្គលិកខ្ពស់ និងការខ្វះខាតព័ត៌មាន ស្ដីពីឱកាសទទួលបានការបណ្ដុះបណ្ដាល ។ ឧបសគ្គទាំងនេះក្លាយជាបញ្ហាធ្ងន់ធ្ងរចំពោះសហគ្រាសខ្នាតតូច និងមធ្យម បើប្រៀបធៀបនឹងសហគ្រាសខ្នាតធំ ដូចមានបង្ហាញក្នុងការអង្កេតបរិយាកាសវិនិយោគ ។ និន្នាការបែបនេះកើតមានក្នុងប្រទេសជាច្រើនដែលផ្ដោតសំខាន់លើសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។ ដើម្បីដោះស្រាយភាពខ្វះខាតបំណិននិយោជក ទាមទារឱ្យមានការផ្ដល់ ព័ត៌មានបន្ថែម រួមមាន ព័ត៌មានស្ដីពីមជ្ឈមណ្ឌលបណ្ដុះបណ្ដាលការងារ គុណភាពនៃមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ ការមានបំណិនជាក់លាក់ និងគុណភាព សាកលវិទ្យាល័យ ព្រមទាំងមានបំណងបង្កើតទំនាក់ទំនងជាមួយសាកលវិទ្យាល័យ (សូមមើលរូបភាពទី ៣) ។

រូបភាពទី ៣ : ដំណោះស្រាយរបស់និយោជកដែលបានលើកឡើង ដើម្បីដោះស្រាយភាពខ្វះខាតបំណិន




**ប្រភព :** ការអង្កេតរបស់ HRINC កម្ពុជា ខែមីនា ឆ្នាំ២០១១ ។

## ២.២ តើភាពខ្វះខាតក្នុងការផ្តល់បំណិនស្ថិតនៅត្រង់ណា?

ក្របខ័ណ្ឌអភិវឌ្ឍន៍បំណិនក្នុងវដ្តជីវិត ដែលចាប់ផ្តើមពីការអភិវឌ្ឍកុមារតូចរហូតដល់ពេលមានការងារ ជួយបង្កើតឱ្យមានការវិភាគលើបញ្ហា និងគោលនយោបាយអភិវឌ្ឍន៍បំណិន។ ក្របខ័ណ្ឌនេះបែងចែកវដ្តជីវិតរបស់មនុស្សម្នាក់ៗជាច្រើនដំណាក់កាលខុសៗគ្នា ៖ ដោយចាប់ផ្តើមពីដំណាក់កាលមូលដ្ឋានដំបូងនៃការអភិវឌ្ឍកុមារតូច និងការអប់រំមូលដ្ឋានសម្រាប់ជួយឱ្យបុគ្គលម្នាក់ៗទទួលបានបំណិនក្នុងការបំពេញការងារ។ បន្ទាប់មកជាដំណាក់កាលមុនពេលបំពេញការងារ ដែលជាពេលនិយោជិតកំពុងរៀនសូត្រពីបំណិនវិជ្ជាជីវៈ និងបច្ចេកទេស ដើម្បីបំពេញការងារដំបូងរបស់ខ្លួនតាមរយៈការហាត់រៀនធ្វើការ ការរៀននៅតាមសាលារៀន និងមជ្ឈមណ្ឌលបណ្តុះបណ្តាល។ ចុងក្រោយ ជាដំណាក់កាលកសាងសមត្ថភាពឱ្យបានខ្ពស់នៅកន្លែងធ្វើការ និងដំណាក់កាលរៀនសូត្របំណិនថ្មីៗដែលជាពេលនិយោជិតកំពុងបង្កើនសមត្ថភាពបំណិនរបស់ខ្លួន និងរៀនសូត្របំណិនថ្មីៗ ដើម្បីបំពេញការងារក្នុងទីផ្សារការងារដែលមានការផ្លាស់ប្តូរ។ ក្នុងដំណាក់កាលនីមួយៗរួមមាន ប្រតិបត្តិករ គោលនយោបាយ ប្រភពហិរញ្ញប្បទាននិងយន្តការត្រួតពិនិត្យការបំពេញការងារខុសៗគ្នាសម្រាប់ការអភិវឌ្ឍបំណិន។

ប្រទេសកម្ពុជាប្រឈមនឹងឧបសគ្គចម្បងក្នុងការផ្តល់បំណិននៅដំណាក់កាលដំបូងនៃវដ្តជីវិត ដែលចាប់ផ្តើមពីការអភិវឌ្ឍកុមារតូច។ ការបង្កើតមូលដ្ឋាន

### ក) បំណិនសម្រាប់កុមារតូច ៖ បញ្ហាប្រឈមនឹងអាហារូបត្ថម្ភ និងការលើកទឹកចិត្ត

ការយល់ដឹងជាអន្តរជាតិពីសារៈសំខាន់នៃការអភិវឌ្ឍកុមារតូច (ECD) ក្នុងការបង្កើតមូលដ្ឋានសម្រាប់ការរៀនសូត្រពេញមួយជីវិតមានការកើនឡើងជាបន្តបន្ទាប់។ លោក Jame Heckman ជាបេក្ខជនជ័យលាភីពានរង្វាន់ណូបែល និងបេក្ខជនជ័យលាភីពានរង្វាន់ណូបែលដទៃទៀត បានបង្ហាញថា ការអភិវឌ្ឍកុមារតូច គឺជាទម្រង់ចំណាយដែលមានប្រសិទ្ធភាពបំផុតក្នុងការវិនិយោគមូលធនមនុស្ស បើប្រៀបធៀបនឹងការវិនិយោគទៅលើការអប់រំកម្រិតបឋមសិក្សា ឬការអប់រំក្នុងកម្រិតបន្តបន្ទាប់ទៀត។ លទ្ធផលទាំងបីនៃការអភិវឌ្ឍកុមារតូចមានសារៈសំខាន់ចំពោះការអភិវឌ្ឍនាពេលអនាគតក្នុងជីវិត ៖ (១) ការអភិវឌ្ឍរាងកាយ និងសុខុមាលភាព (២) ការអភិវឌ្ឍបញ្ញាស្មារតី (៣) ការអភិវឌ្ឍសង្គម-ចិត្តសាស្ត្រ។ គោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍កុមារតូច អាចមានឥទ្ធិពលផ្ទាល់ទៅលើលទ្ធផលនៃដំណាក់កាលអភិវឌ្ឍន៍ទាំងនេះ និងផ្តល់អត្ថប្រយោជន៍ដល់កុមារ និងសង្គម។

ភស្តុតាងពីការអង្កេតបង្ហាញថា កម្មវិធីអភិវឌ្ឍន៍កុមារតូចដែលមានប្រសិទ្ធភាពផ្តល់អត្ថប្រយោជន៍ជាច្រើន។ ភស្តុតាងបានបង្ហាញថា អន្តរាគមន៍តាមរយៈការផ្តោតការយកចិត្តទុកដាក់លើសុខភាព និងចំណេះដឹងមាតា អាហារូបត្ថម្ភកុមារ និងសកម្មភាពលើកកម្ពស់ការអភិវឌ្ឍបញ្ញាស្មារតី និងសង្គមចិត្តសាស្ត្ររបស់កុមារតូច (ដូចជា ការថែទាំដោយយកចិត្តទុកដាក់ និងការប្រើប្រាស់ភាសាល្អ និងឱកាសទទួលបានការស្វែងយល់) ផ្តល់ផលវិជ្ជមានដល់ការត្រៀមខ្លួនចូលរៀន និងលទ្ធផលសិក្សាក្នុងជីវិតរបស់កុមារដោយបង្កើតបានសង្គមមួយដ៏រឹងមាំ ក៏ដូចជាការទទួលបានអត្ថប្រយោជន៍ផ្ទាល់ខ្លួនពីការវិនិយោគបែបនេះ (ការអង្កេតរបស់ Alderman ឆ្នាំ២០១១ និង Barnett ឆ្នាំ២០០៨)។ ផ្ទុយមកវិញ ភស្តុតាងអន្តរជាតិបង្ហាញថា ពិការភាពនៅវ័យក្មេង គឺមានការលំបាក និងត្រូវចំណាយថវិកាច្រើនក្នុងការព្យាបាល។

១០ ឧទាហរណ៍ សូមមើលការលើកឡើងរបស់ Heckman, Stixrud និង Urzua (ឆ្នាំ២០០៥)។ ជាទូទៅការអភិវឌ្ឍកុមារតូចចាប់ផ្តើមពីពេលដែលកុមារមានអាយុចាប់ពីប្រាំមួយដល់ប្រាំបីឆ្នាំ។

## កង្វះអាហារនៅក្នុងគ្រួសារ ធ្វើឱ្យអត្រាសិក្សា និងបញ្ចប់ការសិក្សាមានកម្រិតទាប

ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១០ បង្ហាញថា ភាគរយនៃកុមារក្រិន សុខភាពខ្សោយ និងខ្វះទម្ងន់នៅពេលមានអាយុ ៥៩ ខែដំបូង នៅតែមានកម្រិតខ្ពស់ ដែលក្នុងនោះ កុមារក្រិនមានចំនួន ៤០% កុមារខ្សោយចំនួន ១១% និងកុមារខ្វះទម្ងន់ចំនួន ២៨% ក្នុងឆ្នាំ២០១០។ ភាគរយទាំងនេះ មានកម្រិតដូចគ្នានឹងការអង្កេតក្នុងឆ្នាំ២០០៥ ប៉ុន្តែសម្រាប់ករណីកុមារក្រិន ដែលបណ្តាលមកពីការខ្វះអាហារូបត្ថម្ភធ្ងន់ធ្ងរនោះ គឺមានកម្រិតខ្ពស់ក្នុងឆ្នាំ២០១០ បើប្រៀបធៀប នឹងឆ្នាំ២០០៥។ ក្នុងពិភពលោក ការខ្វះអាហារូបត្ថម្ភ និងការលើកទឹកចិត្តមិនបានគ្រប់គ្រាន់ បណ្តាលឱ្យមានភាពអន់ថយក្នុងការអភិវឌ្ឍ បញ្ហាការបោះបង់ការសិក្សា បញ្ហាអាកប្បកិរិយា និងជាលទ្ធផល គឺបរាជ័យក្នុងជីវិត។

ការមិនមានអាហារគ្រប់គ្រាន់ក្នុងគ្រួសារ ក៏ជាកត្តារួមផ្សំដែលធ្វើឱ្យអត្រាសិក្សា និងអត្រាបញ្ចប់ការសិក្សាមានកម្រិតទាបផងដែរ (រូបភាពទី ៤)។ យោងតាម ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (CSES) ក្នុងចំណោមកុមារចំនួនប្រាំនាក់ មានកុមារម្នាក់រស់នៅក្នុងគ្រួសារមិនមានអាហារគ្រប់គ្រាន់។ កុមារទាំងនេះមានឱកាសតិចតួចក្នុងការសិក្សា និងបញ្ចប់ការសិក្សា។ ក្នុងចំណោមកុមារមានអាយុចាប់ពី ៦-១៧ ឆ្នាំ កុមារចំនួន ២០% ដែលរស់នៅក្នុងគ្រួសារមិនមានអាហារគ្រប់គ្រាន់ មិនបានចូលរៀន បើប្រៀបធៀបទៅនឹងគ្រួសារមានអាហារគ្រប់គ្រាន់មានតែកុមារចំនួន ៨% ប៉ុណ្ណោះ ហើយភាគរយនេះមានលក្ខណៈស្រដៀងគ្នាទៅនឹងភាគរយយុវជនអាយុចាប់ពី ១៨-២២ ឆ្នាំ ដែលក្នុងនោះ យុវជន ២១% មកពីគ្រួសារមិនមានអាហារគ្រប់គ្រាន់ ហើយ ៨% មកពីគ្រួសារមានអាហារ គ្រប់គ្រាន់។ ក្នុងចំណោមកុមារអាយុចាប់ពី ១៥-១៧ ឆ្នាំ ដែលបានចូលរៀន មានតែកុមាររស់នៅក្នុងគ្រួសារមិនមានអាហារគ្រប់គ្រាន់ចំនួន ៥២% ប៉ុណ្ណោះ ដែលបានចូលរៀននាពេលថ្មីៗនេះ បើប្រៀបធៀបទៅនឹងកុមាររស់នៅក្នុងគ្រួសារមានអាហារគ្រប់គ្រាន់ចំនួន ៦១%។ ទំនាក់ទំនងរវាងអាហារ និងការអប់រំ ក៏មានឥទ្ធិពលនៅគ្រប់ជំនាន់ផងដែរ : ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍អាយុលើសពី ១៥ ឆ្នាំ ដែលរស់នៅក្នុងគ្រួសារមិនមានអាហារគ្រប់គ្រាន់ចំនួន ៥៩% មិន ទទួលបានការអប់រំ។

រូបភាពទី ៤ : ភាគរយកុមារ/យុវជនធ្លាប់បានចូលរៀន រស់នៅក្នុងគ្រួសារមាន និងមិនមានអាហារគ្រប់គ្រាន់ ឆ្នាំ២០០៩




**ប្រភព :** ការគណនាផ្អែកលើទិន្នន័យបានមកពី CSES ឆ្នាំ២០០៩
**កំណត់សម្គាល់ :** គំរូអង្កេត ផ្តោតលើការអង្កេតតាមដានចំនួន ២២.៩១៤ ករណី សម្រាប់អ្នករស់នៅក្នុងគ្រួសារមានអាហារគ្រប់គ្រាន់ និង ៤.៥៧៦ ករណីសម្រាប់អ្នករស់នៅក្នុងគ្រួសារមិនមានអាហារគ្រប់គ្រាន់

ការអប់រំកម្រិតមត្តេយ្យសិក្សា និងកម្មវិធីផ្សព្វផ្សាយតាមសហគមន៍កំពុងមានការកើនឡើង ប៉ុន្តែនៅមានកម្រិតនៅឡើយ។ អត្រាចុះឈ្មោះចូលរៀននៅកម្រិតមត្តេយ្យសិក្សាក្នុងប្រទេសកម្ពុជា បានកើនឡើងស្ទើរតែពីរដងក្នុងទសវត្សរ៍ចុងក្រោយនេះ ដោយមានអត្រាចុះឈ្មោះចូលរៀនសរុបនៅកម្រិតមត្តេយ្យសិក្សារហូតដល់ ១៣%។ ការកើនឡើងនេះ ដោយសារតែមានការចុះឈ្មោះចូលរៀនទាំងនៅគ្រឹះស្ថានអប់រំឯកជន និងសាធារណៈដែលក្នុងនោះ អត្រាចុះឈ្មោះចូលរៀននៅគ្រឹះស្ថានអប់រំឯកជនស្មើនឹង ៣០% នៃការផ្តល់សេវាអប់រំក្នុងឆ្នាំ២០០៨/២០០៩ បើប្រៀបធៀបទៅនឹងឆ្នាំ២០០០/២០០១ មានចំនួន ២០%។ ទោះជាយ៉ាងនេះក្តី អត្រាចុះឈ្មោះចូលរៀនមត្តេយ្យសិក្សានៅតែមានកម្រិតទាប បើប្រៀបធៀបទៅនឹងអន្តរជាតិ។ អត្រាចុះឈ្មោះចូលរៀនសរុបនៅកម្រិតមត្តេយ្យសិក្សាកើនឡើងលើសពី ៤៥% នៅទូទាំងពិភពលោក និងប្រហែល ៤៤% ក្នុងប្រទេសចិន និងឥណ្ឌូនេស៊ី និង ៨៨% ក្នុងប្រទេសថៃ។ ដោយឡែកកម្មវិធីអភិវឌ្ឍន៍ កុមារតូច រួមទាំងកម្មវិធីផ្សព្វផ្សាយតាមសហគមន៍ ដើម្បីលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ និងការអនុវត្តការថែទាំកុមារកំពុងតែសាកល្បងអនុវត្ត និងវាយតម្លៃ។

## ៩) ការអប់រំកម្រិតបឋមសិក្សាៈ អត្រាចុះឈ្មោះចូលរៀនកើនឡើង ប៉ុន្តែអត្រាបញ្ចប់ការសិក្សា និងការសិក្សាធ្លាក់ចុះ

គោលនយោបាយរបស់រដ្ឋាភិបាលក្នុងការសម្រេចបានការផ្តល់ការអប់រំមូលដ្ឋានជាសកលបានទទួលជោគជ័យក្នុងការបង្កើនអត្រាចុះឈ្មោះចូលរៀនពិតជាពិសេសនៅកម្រិតបឋមសិក្សា។ អត្រាចុះឈ្មោះចូលរៀនពិតនៅកម្រិតបឋមសិក្សា កើនឡើងចាប់ពីក្រោម ៨៣% ក្នុងឆ្នាំ២០០០/២០០១ រហូតជិតដល់ ៩៥% ក្នុងឆ្នាំ២០០៩/២០១០។ យោងតាមទិន្នន័យរបស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំអត្រាចុះឈ្មោះចូលរៀនកើនឡើងទាំងក្នុងតំបន់ប្រជុំជន តំបន់ជនបទ និងតំបន់ដាច់ស្រយាល។ ការកើនឡើងនេះ ដោយសារមានការចុះឈ្មោះចូលរៀនយ៉ាងច្រើនក្នុងគ្រឹះស្ថានអប់រំសាធារណៈដែលមានសិស្សបឋមសិក្សារហូតដល់ ៩៩%។

ទោះបីយ៉ាងណា អត្រាសិស្សមិនបានបញ្ចប់ការអប់រំកម្រិតបឋមសិក្សានៅតែជាបញ្ហាប្រឈម។ យោងតាមការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០០៩ កុមារម្នាក់ក្នុងចំណោមកុមារដប់នាក់អាយុចាប់ពី ៦-១៧ ឆ្នាំ មិនដែលបានចូលរៀន។ ក្នុងចំណោមសិស្សអាយុចាប់ពី ១៥-១៩ ឆ្នាំ មានសិស្សចំនួនតែ ៧១%ប៉ុណ្ណោះ បានបញ្ចប់ការអប់រំកម្រិតបឋមសិក្សា (សម្រាប់សិស្សបានបញ្ចប់ការអប់រំកម្រិតបឋមសិក្សាអាយុចាប់ពី ២០-២៤ ឆ្នាំ មានចំនួន ៦៩%)។ ក្នុងចំណោមសិស្សមិនមែនជនជាតិខ្មែរ និងចាមសិស្សអាយុចាប់ពី ១៥-១៩ ឆ្នាំ ចំនួនតិចជាង ២២% និងសិស្សអាយុចាប់ពី ២០-២៤ ឆ្នាំ ចំនួន ១៩% បានបញ្ចប់ការអប់រំកម្រិតបឋមសិក្សា។ អ្វីដែលជាប្រភពនៃក្តីព្រួយបារម្ភនោះ គឺនាពេលថ្មីៗនេះ អត្រាចុះឈ្មោះចូលរៀនរួមនៅកម្រិតបឋមសិក្សាបានកើនឡើង ស្របពេលដែលអត្រាបញ្ចប់ការសិក្សាធ្លាក់ចុះ។ ទិន្នន័យរបស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំបង្ហាញថា អត្រាបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សាកើនឡើងខ្ពស់បំផុតត្រឹម ៩០% ក្នុងឆ្នាំ២០០៥/២០០៦ និងធ្លាក់ចុះត្រឹម ៨៣% ក្នុងឆ្នាំ២០០៩/២០១០។ លើសពីនេះ សិស្សបោះបង់ការសិក្សានៅកម្រិតបឋមសិក្សាមានកម្រិតខ្ពស់ដែលក្នុងនោះ អត្រាត្រួតថ្នាក់មាន ១១% និងអត្រាបោះបង់ការសិក្សាមាន ៨៩%។ ដូច្នេះ អ្វីដែលជាបញ្ហាប្រឈមនាពេលអនាគតមិនត្រឹមតែជាបញ្ហាក្នុងការលើកកម្ពស់អត្រាបញ្ចប់ការសិក្សាសម្រាប់សិស្សដែលកំពុងសិក្សា ប៉ុណ្ណោះទេ តែថែមទាំងជាបញ្ហាក្នុងការបំពេញតម្រូវការបំណិនបន្ថែមរបស់យុវជនដែលមិន បានបញ្ចប់ការអប់រំកម្រិតបឋមសិក្សា។

តារាងទី ២ : ភាគរយកុមារនៅក្រៅសាលា និងមូលហេតុនៃការមិនចូលរៀន ឆ្នាំ២០០៩

| | មត្តេយ្យសិក្សា (៣-៥ឆ្នាំ) | បឋមសិក្សា (៦-១១ឆ្នាំ) | មធ្យមសិក្សាបឋមភូមិ (១២-១៤ឆ្នាំ) | មធ្យមសិក្សាទុតិយភូមិ (១៥-១៧ឆ្នាំ) | សរុប (៦-១៧ឆ្នាំ) |
|---|---|---|---|---|---|
| ភាគរយសិស្សមិនដែលបានចូលរៀន | ៨៤,៣ | ១៤,៧ | ៤,៨ | ៦,២ | ៩,៩ |
| ភាគរយសិស្សដែលបានចូលរៀន ប៉ុន្តែមិនមែនពេលថ្មីៗនេះ | ១,១ | ១,៤ | ១០,៩ | ៤០,៣ | ១៤,៧ |
| មូលហេតុដែលសិស្សមិនចូលរៀន ឬមិនដែលបានចូលរៀន | | | | | |
| មិនមានចំណាប់អារម្មណ៍ក្នុងការសិក្សា | ២,០ | ១៦,៨ | ១៨,៣ | ១២,៤ | ១៤,៨ |
| ការសិក្សាមិនល្អ | ២,១ | ៤,១ | ១៦,១ | ១៧,២ | ១២,៧ |
| មិនមានសាលារៀនសមរម្យ/សាលារៀនស្ថិតនៅឆ្ងាយពីផ្ទះ | ០,៩ | ៦,៧ | ៤,៧ | ៣,០ | ៤,៥ |
| មិនមានគ្រូបង្រៀន/សម្ភារៈសិក្សា | ០,៤ | ២,៤ | ២,០ | ០,៩ | ១,៦ |
| ចំណាយខ្ពស់ក្នុងការសិក្សា | .. | .. | ០,២ | ០,២ | ០,១ |
| ត្រូវចូលរួមចំណែកក្នុងការរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ | ០,១ | ០,៧ | ១៤,៣ | ២៧,៩ | ១៦,៦ |
| ត្រូវជួយធ្វើការងារផ្ទះ | ០,១ | ១,៩ | ១៤,៣ | ១៥,៩ | ១១,០ |
| ក្រីក្រខ្លាំង | ១,០ | ១០,៥ | ២៣,៥ | ១៧,៦ | ១៦,២ |
| នៅក្មេងពេក | ៩៣,១ | ៥៣,៥ | ២,២ | ០,៨ | ១៨,៦ |
| ចំនួនការអង្កេតតាមដាន | ២.៨៣៩ | ១.១៨៦ | ៥៩៥ | ១.៧៩៣ | ៣.៥៧៤ |

**ប្រភព :** ការគណនាផ្អែកតាមទិន្នន័យបានមកពីការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៩។

មូលហេតុសម្រាប់ការមិនចូលរៀន និងការបោះបង់ចោលការសិក្សា គឺមានទំនាក់ទំនងចម្បងទៅនឹងស្ថានភាពគ្រួសារ។ ក្នុងចំណោមកុមារអាយុចាប់ពី ៦-១១ឆ្នាំ ដែលមិនចូលរៀន គឺដោយសារតែបញ្ហាចម្បង : ក) មិនមានសាលារៀន គ្រូបង្រៀន និងសម្ភារៈគ្រប់គ្រាន់ (៩%) ខ) ភាពក្រីក្រ ការធ្វើការងារផ្ទះ និងការរកប្រាក់ចំណូល (១៣%) គ) ព្រមទាំងការគិតថា កុមារនៅវ័យក្មេងនៅឡើយ ទោះបីជាគ្រប់អាយុផ្លូវការចូលរៀនក៏ដោយ (៥៤%) ឬមិនចង់ចូលរៀន (១៧%)។ មូលហេតុនៃការមិនចូលរៀន ឬគិតថាអាយុក្មេងពេក មិនអាចចូលរៀននោះ ឆ្លុះបញ្ចាំងពីបញ្ហាចំពោះកុមារតូចរួមទាំងការអភិវឌ្ឍយឺតយ៉ាវនិងខ្សោយបញ្ញាដោយសារតែការខ្វះខាតអាហារូបត្ថម្ភឬកាត់បន្ថយសកម្មភាពខួរក្បាលដោយសារខ្វះការបណ្តុះបណ្តាលស្មារតីគ្រប់គ្រាន់នៅដំណាក់កាលដំបូងនៃជីវិត។ តារាងទី ២ ពិពណ៌នាពីសេចក្តីលម្អិត ដែលបានមកពីការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៩។

១១ សម្រាប់ទិន្នន័យរបស់ប្រទេសជាច្រើនទៀត សូមមើលសូចនាករអភិវឌ្ឍន៍ពិភពលោក (ឆ្នាំ២០១០)។

១២ អាយុចូលរៀនផ្លូវការរបស់ប្រទេសកម្ពុជានៅកម្រិតបឋមសិក្សា គឺស្របទៅតាមការអនុវត្តរបស់អន្តរជាតិ

១៣ EMIS ឆ្នាំ២០០៩

ជាចុងក្រោយ ក្តីបារម្ភនៅតែមានចំពោះលទ្ធផលនៃការសិក្សា។ លើសពីនេះ វិញ្ញាសាប្រឡងវាយតម្លៃសិស្សថ្នាក់ជាតិលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ទី ៣ ទី ៦ និងទី ៩ បង្ហាញថា លទ្ធផលសិក្សាមូលដ្ឋានរបស់សិស្សនៅមានកម្រិតទាបនៅឡើយ ទោះបីមានការលើកកម្ពស់ក៏ដោយ។ ម្យ៉ាងទៀត កត្តាគ្រូបង្រៀន និងសមត្ថភាពគ្រូបង្រៀននៅតែជាឧបសគ្គ។ ក្នុងការអប់រំកម្រិតបឋមសិក្សា ផលធៀបសិស្សនិងគ្រូ មានអត្រាលើសរហូតដល់ ៤៩% ដែលនេះជាអត្រាខ្ពស់ បើយោងតាមស្តង់ដាអន្តរជាតិ និងលើកម្រិតមធ្យមក្នុងចំណោមប្រទេសមានចំណូលទាបក្នុងតំបន់ (រូបភាពទី ៤)។ ក្នុងទសវត្សរ៍កន្លងមក ភាគរយ គ្រូបង្រៀនដែលមានការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ឬឧត្តមសិក្សា បានកើនឡើងចាប់ពី ២៩% ដល់ ៥០%។ ទោះបីយ៉ាងណា គ្រូបង្រៀនចំនួន ៤៦% ទទួលបានការអប់រំត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិ និង ៤% ទទួលបានការអប់រំត្រឹមកម្រិតបឋមសិក្សា ដែលនេះបង្ហាញឱ្យឃើញពីការខ្វះខាតសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្រៀន (ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ)។

រូបភាពទី ៥ : ផលធៀបសិស្ស និងគ្រូនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាក្នុងតំបន់អាស៊ីបូព៌ា




**ប្រភព :** EdStats (ទិន្នន័យចុងក្រោយបំផុត ក្នុងឆ្នាំ២០០៥-២០០៩)។
**កំណត់សម្គាល់ :** អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក សំដៅលើប្រទេសកំពុងអភិវឌ្ឍន៍ប៉ុណ្ណោះ។

## គ) ការអភិវឌ្ឍបំណិនសំខាន់ៗក្នុងការអប់រំកម្រិតមធ្យមសិក្សា និងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស (TVET): អត្រាសិក្សា និងការយល់ដឹងពីអត្ថប្រយោជន៍នៃការសិក្សានៅមានកម្រិតទាប

តាមរយៈការប្រៀបធៀបទៅនឹងការអប់រំកម្រិតបឋមសិក្សា ការចុះឈ្មោះចូលរៀននៅកម្រិតមធ្យមសិក្សាកើនឡើងយឺតចាប់ពីឆ្នាំ២០០៧ និងនៅតែមានកម្រិតទាបក្នុងពេលបច្ចុប្បន្ន។ យោងតាមទិន្នន័យរបស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ អត្រាចុះឈ្មោះចូលរៀនពិតនៅកម្រិតធម្យមសិក្សាបឋមភូមិមានអត្រាប្រហែល ៣២% ក្នុងឆ្នាំ២០០៩/២០១០ ដោយមានអត្រាចុះឈ្មោះចូលរៀនខុសគ្នារវាងតំបន់ប្រជុំជន (៤៨%) និងតំបន់ជនបទ (២៩%) និងតំបន់ដាច់ស្រយាល (១១%)។ អត្រានេះមានកម្រិតទាប បើប្រៀបធៀបទៅនឹងអត្រាចុះឈ្មោះចូលរៀនជាអន្តរជាតិ (រូបភាពទី ៥)។ តាមការប៉ាន់ស្មានអត្រាចុះឈ្មោះចូលរៀនពិតនៅកម្រិតមធ្យមសិក្សាទុតិយភូមិមានអត្រាប្រហែល ១២%។ ក្នុងចំណោមសិស្សអាយុចាប់ពី ២០-២៤ឆ្នាំ សិស្សតិចជាង ៦% ចូលរួមការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសក្រៅពីនេះមានសិស្សចំនួនតែមួយភាគបីប៉ុណ្ណោះ ចូលរួមក្នុងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសបន្ទាប់ពីបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សា (ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៩)។

រូបភាពទី ៦ : អត្រាចុះឈ្មោះចូលរៀនពិតនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាក្នុងតំបន់អាស៊ីបូព៌ា




**ប្រភព :** EdStats (ទិន្នន័យចុងក្រោយបំផុតក្នុងឆ្នាំ ២០០៥-២០០៩)។
**កំណត់សម្គាល់ :** តួលេខរបស់ EdStats សម្រាប់ប្រទេសកម្ពុជាខុសគ្នាពីតួលេខរបស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ

អត្រាបញ្ចប់ការសិក្សាទាប និងជម្រើសតិចតួចក្នុងការអប់រំកម្រិតមធ្យមសិក្សានៅតែជាបញ្ហាប្រឈមចម្បង។ អត្រាបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិមានអត្រាប្រហែល ៤៩% ក្នុងឆ្នាំ២០០៧-២០១០។ ក្នុងឆ្នាំ ២០០៩ កុមារអាយុចាប់ពី ១៥-១៩ឆ្នាំ ចំនួនតែ ២៩% និងយុវជនអាយុចាប់ពី ២០-២៤ ឆ្នាំ ចំនួន ៣៦% ប៉ុណ្ណោះបានបញ្ចប់ការសិក្សារយៈពេល ៩ ឆ្នាំ ឬច្រើនជាងនេះ យុវជនអាយុចាប់ពី ២០-២៤ ឆ្នាំ ចំនួនតែ ១៧% បានបញ្ចប់ការសិក្សារយៈពេល១២ ឆ្នាំ ឬច្រើនជាងនេះ និងចំនួនតិចជាង ២% បានទទួលវិញ្ញាបនបត្រអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស (ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច កម្ពុជា ឆ្នាំ២០០៩)។ ផ្ទុយទៅវិញ បច្ចុប្បន្ន ក្រុមអាយុដែលមានសិទ្ធិទទួលបានការអប់រំចំនួន ៩៩% ក្នុងប្រទេសចិនទទួលបានការអប់រំមូលដ្ឋានដែលមានរយៈពេល ៩ ឆ្នាំ។ អត្រាចុះឈ្មោះចូលរៀនក្នុងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសនៅកម្រិតមធ្យមសិក្សាក្នុងប្រទេសកម្ពុជា មានអត្រាទាបបំផុតក្នុងតំបន់អាស៊ីដែលបង្ហាញឱ្យឃើញថា ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស មិនមែនជាជម្រើសសមស្រប ឬជាជម្រើសដែលទាក់ទាញចំណាប់អារម្មណ៍សិស្សនោះទេ។ អត្រាទាបនៃការបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សា និងជាពិសេសអត្រាបញ្ចប់ការសិក្សាក្នុងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសនៅតែជាឧបសគ្គក្នុងបង្កើននិយោជិតជំនាញក្នុងប្រទេសកម្ពុជា។ ទាក់ទិននឹងបញ្ហានេះ បទពិសោធន៍ជាអន្តរជាតិលើកឡើងថា ការផ្តល់ឱ្យមានការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស ដែលជាជម្រើសសម្រាប់សិស្សមធ្យមសិក្សាអាចជួយបង្កើនអត្រាគង់វង្ស និងអត្រាបញ្ចប់ការសិក្សា និងនាំឱ្យមានការប្រកួតប្រជែងសេដ្ឋកិច្ច។

មូលហេតុសម្រាប់ការមិនចូលរៀន និងការបោះបង់ចោលការសិក្សា គឺបញ្ហាផ្នែកហិរញ្ញវត្ថុ។ ដូចមានបង្ហាញក្នុងតារាងទី ២ សិស្សចំនួន ៥២% ដែលមិនចូលរៀនមធ្យមសិក្សាបឋមភូមិ គឺដោយសារភាពក្រីក្រភាពចាំបាច់ក្នុងការរកប្រាក់ចំណូល និងការជួយធ្វើការងារផ្ទះដែលជាមូលហេតុចម្បង។ តាមរបាយការណ៍បង្ហាញថា សិស្សចំនួនពីរភាគបីដែលស្ថិតក្នុងក្រុមអាយុខាងលើ មិនបានចូលរៀនមធ្យមសិក្សាទុតិយភូមិ ដោយសារតែមូលហេតុទាំងនេះ (ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៩)។ ក្រសួងអប់រំ យុវជន និងកីឡា (អ.វ.យ.ក) បានត្រៀមរួចជាស្រេចក្នុងការដោះស្រាយបញ្ហាហិរញ្ញវត្ថុនេះតាមរយៈការផ្តល់កម្មវិធីអាហារូបករណ៍ និងផ្តល់ជំនួយហិរញ្ញវត្ថុដល់គ្រួសារសម្រាប់ឱ្យកូនបន្តការសិក្សា។ នៅទូទាំងពិភពលោក កម្មវិធីបែបនេះបានជួយជំរុញឱ្យសិស្សត្រឡប់ចូលរៀនវិញ ដោយគេឃើញមានការកើនឡើងនៃអត្រាចុះឈ្មោះចូលរៀន (Filmer និង Schady ឆ្នាំ២០០៩)។ ម្យ៉ាងទៀត ទោះបីជាមានតម្រូវការគំនិតផ្តួចផ្តើមបន្ទាន់ក៏ដោយ ក៏ការចំណាយតិចសម្រាប់វិស័យអប់រំនៅតែជាបញ្ហារាំងស្ទះដល់គំនិតផ្តួចផ្តើមនេះដដែល ដែលមានអត្រា ១,៦% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០០៧ បើប្រៀប

១៤ ឧទាហរណ៍ សូមមើល Bishop និង Mane (ឆ្នាំ២០០៥) និង OECD (ឆ្នាំ២០១០)

ធៀបនឹង ប្រទេសជិតខាង ដូចជា ប្រទេសបង់ក្លាដេស (២,៤%) ឥណ្ឌា (៣,២%) ឥណ្ឌូនេស៊ី (៣,៥%) សាធារណរដ្ឋ ប្រជាធិបតេយ្យប្រជាមានិតឡាវ (២,៣%) ម៉ាឡេស៊ី (៤,៥%) វៀតណាម (៥,៣%) និងប្រទេសថៃ (៤,៩%) (សូចនាករអភិវឌ្ឍន៍ពិភពលោក ឆ្នាំ២០១០)។ ស្រដៀងគ្នានេះដែរលទ្ធភាពរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈក្នុងការសម្របសម្រួលដល់ការបង្កើនការអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងបច្ចេកទេសផ្លូវការនៅមានកម្រិត។

ទស្សនៈគ្រួសារដែលគិតថា ការឱ្យកូនៗបន្តការសិក្សានឹងធ្វើឱ្យបាត់បង់ហិរញ្ញវត្ថុភ្លាមៗនោះកើតឡើងដោយការមិនឱ្យតម្លៃលើការសិក្សា។ ព័ត៌មានអំពីចំណូលហិរញ្ញវត្ថុដែលកូនអាចរកបាន ប្រសិនបើកូនអាចបន្តការសិក្សាដល់កម្រិតមធ្យមសិក្សា និងការអប់រំ និងការបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ។ បញ្ហានេះ អាចរារាំងគ្រួសារមួយចំនួនពីការឱ្យតម្លៃខ្ពស់លើការអប់រំសម្រាប់ការរកប្រាក់ចំណូលនាពេលអនាគតដែលបញ្ហានេះតែងតែកើតមានក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ការវាយតម្លៃជាក់ស្ដែងលើតម្លៃនៃការអប់រំក្នុងប្រទេសកម្ពុជា កំពុងបង្ហាញពីផលចំណេញផ្នែកសេដ្ឋកិច្ចដ៏ល្អសម្រាប់អ្នកដែលបន្តការសិក្សា។ បុព្វលាភប្រាក់ចំណូលប្រហែល ៣៨% សម្រាប់សិស្សមានការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិធៀបនឹងបឋមសិក្សា ហើយប្រហែល ២៤% សម្រាប់សិស្សមានការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិធៀបនឹងមធ្យមសិក្សាបឋមភូមិ (ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៩)។ ចំណូលហិរញ្ញវត្ថុសម្រាប់សិស្សមានការអប់រំកម្រិតមធ្យមសិក្សាទាំងអស់ មានកម្រិតប្រហាក់ប្រហែលនឹងប្រទេសហ្វីលីពីន ប៉ុន្តែមានកម្រិតទាបជាងប្រទេសឥណ្ឌូនេស៊ី ឬប្រទេសថៃ (ធនាគារពិភពលោក ២០១០ ខ)។

រូបភាពទី ៧ : ប្រាក់ឈ្នួលប្រចាំខែតាមកម្រិតនៃការអប់រំ និងក្រុមវិជ្ជាជីវៈ ឆ្នាំ ២០០៩ (គិតជារៀល)




**ប្រភព :** ការគណនាផ្អែកលើការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ ២០០៩

១៥ លទ្ធផលអង្កេតបានមកពី CSES ឆ្នាំ ២០០៩ និង HRINC ឆ្នាំ ២០១១

១៦ សម្រាប់ព័ត៌មានលម្អិត សូមអាន CAMFEBA (ឆ្នាំ ២០០៨)

ការប៉ាន់ស្មានខុសភាគច្រើន គឺទាក់ទងនឹងប្រាក់ចំណូលសម្រាប់សិស្សដែលបន្តការអប់រំ បណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ។ ចំណូលហិរញ្ញវត្ថុនឹងកើន ៦០% សម្រាប់សិស្សបន្តការអប់រំ បណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាប្រៀបធៀបទៅនឹងការអប់រំបឋមសិក្សា និងចំណូលកើន ១១២% សម្រាប់សិស្សបន្តការអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេសក្រោយបញ្ចប់កម្រិតមធ្យមសិក្សាប្រៀបធៀបទៅនឹងការអប់រំមធ្យមសិក្សាបឋមភូមិ។

ជាក់ស្ដែង ការអង្កេតតាមគ្រួសារ និងការអង្កេតប្រាក់បៀវត្សរ៍ និងផលប្រយោជន៍នៃវិស័យឯកជននាពេលថ្មីៗនេះ ព្រមទាំងរូបភាពទី ៦ បង្ហាញឱ្យឃើញថាប្រាក់ចំណូលសម្រាប់សិស្សដែលបន្តការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ បន្ទាប់ពីបញ្ចប់ការអប់រំមធ្យមសិក្សាស្ទើរតែស្មើនឹងប្រាក់ចំណូលរបស់សិស្សដែលបន្តការសិក្សាដល់ថ្នាក់ឧត្តមសិក្សា (ហើយទទួលបានប្រាក់ចំណូលច្រើនជាងនេះបីដងក្នុងចំណោមអ្នកបច្ចេកទេស និងការងារដែលផ្សារភ្ជាប់នឹងបុគ្គលិកជំនាញ)។ សិស្សដែលមានចំណាប់អារម្មណ៍ចុះឈ្មោះចូលរៀនវគ្គអប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈមានត្រឹមតែ ១៧% ប៉ុណ្ណោះ ធៀបនឹងសិស្ស ៣០% ដែលមានចំណាប់អារម្មណ៍ក្នុងការស្វែងរកការងារ ហើយធៀបនឹងសិស្ស ៥០% ទៀតដែលចង់បន្តការសិក្សានៅសាកលវិទ្យាល័យ បន្ទាប់ពីបញ្ចប់ការអប់រំនៅវិទ្យាល័យ។ ភាពខុសគ្នាបែបនេះបានបង្ហាញពីព័ត៌មានស្ដីពីទីផ្សារការងារ និងការបរាជ័យនៃការសម្របសម្រួល ហើយប្រហែលជាការយល់ខុសនៃសង្គម ដែលមិនគាំទ្រនឹងការអប់រំ បណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ក៏ថាបាន។

វគ្គមានសិក្សាទាបនៅកម្រិតមធ្យមសិក្សាអំពាវនាវឱ្យមានកម្មវិធីសម្រាប់ឱកាសលើកទី ២ និងការបណ្ដុះបណ្ដាលក្រៅប្រព័ន្ធ។ បទពិសោធន៍ជាអន្តរជាតិបានលើក ឡើងថា កម្មវិធីឱកាសជាលើកទីពីរ ជាពិសេសកម្មវិធីដែលផ្ដោតសំខាន់លើការគាំទ្រជំនាញសហគ្រិន និងការរួមបញ្ចូលការបណ្ដុះបណ្ដាលក្នុងថ្នាក់រៀន និងកន្លែងធ្វើការធ្វើឱ្យមានការចំណាយតិច ហើយមានផលវិជ្ជមានចំពោះទីផ្សារការងារទៀតផង។ ក្នុងប្រទេសកម្ពុជា ការកើនឡើងយ៉ាងច្រើននូវស្ថាប័នផ្ដល់ការបណ្ដុះបណ្ដាលចម្រុះ បានផ្ដល់ការបណ្ដុះបណ្ដាលក្រៅប្រព័ន្ធ ដើម្បីឱ្យយុវជនដែលបោះបង់ការសិក្សាត្រៀមខ្លួនសម្រាប់ធ្វើការងារជាលើកដំបូង ឬបង្កើនសមត្ថភាព និងផ្ដល់ការបណ្ដុះបណ្ដាលសាជាថ្មីសម្រាប់បុគ្គលិកវ័យចំណាស់។ ទោះជាយ៉ាងនេះក្ដី វគ្គមានអ្នកចូលរួមការបណ្ដុះបណ្ដាលក្រៅប្រព័ន្ធនៅមានកម្រិតនៅឡើយ។ ក្នុងចំណោមអ្នកដែលមានអាយុចាប់ពី ១៥-៥៩ ឆ្នាំ មានតែ ៦% ប៉ុណ្ណោះ ដែលរាយការណ៍ថា ធ្លាប់បានចូលរួមក្នុងថ្នាក់បណ្ដុះបណ្ដាលក្រៅប្រព័ន្ធ (ក្នុងចំណោមអ្នកដែលមានអាយុចាប់ពី ១៥-១៩ ឆ្នាំ មាន ១៣% ហើយពីអាយុ ២០-២៤ ឆ្នាំ មាន ៩%) (ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០០៩)។ សម្រាប់អ្នកដែលធ្លាប់ចូលរៀនថ្នាក់អប់រំក្រៅប្រព័ន្ធអ្នកឆ្លើយតបចំនួន ៨២% បានរៀនភាសាបរទេស ៦% រៀនជំនាញកុំព្យូទ័រ ៦% រៀនពីជំនាញវិជ្ជាជីវៈ និងប្រហែល ៣% រៀនពីអក្ខរកម្មមូលដ្ឋាន។ ក្នុងចំណោមអ្នកដែលមានអាយុចាប់ពី ១៥-១៩ ឆ្នាំ អ្នកធ្លាប់បានចូលរៀនថ្នាក់បណ្ដុះបណ្ដាលក្រៅប្រព័ន្ធចំនួន ៩០% បានរៀនភាសាបរទេស (ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៩)។

ទោះជាយ៉ាងណាក៏ការបណ្ដុះបណ្ដាលក្រៅប្រព័ន្ធ ព្រមទាំងការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈនៅមានដំណើរការយឺតយ៉ាវនៅឡើយ។ ជាក់ស្ដែងការបណ្ដុះបណ្ដាលក្រៅប្រព័ន្ធ និងការអប់រំបណ្ដុះ-

១៧ សម្រាប់ឧទាហរណ៍ និងការវិភាគនានា សូមអានកំណត់ត្រាការងារយុវជនរបស់ធនាគារពិភពលោក តាមរយៈគេហទំព័រ http://www.youth-employment-inventory.org/

បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមានការខ្វះខាតថវិកា ថែមទាំងមិនមានគុណភាពសមរម្យ និងមិនសមស្របទៅនឹងតម្រូវការទីផ្សារការងារនោះទេ (ធនាគារពិភពលោក ឆ្នាំ ២០១០ ខ)។ ភាពចម្រុះនៃកម្មវិធីបណ្តុះបណ្តាលទាមទារឱ្យមានទីផ្សារការងារមួយ ដែលសាកសមទៅនឹងអ្នកស្វែងរកការងារធ្វើ និងនិយោជិតដែលមានជំនាញសមស្របនឹងតម្រូវការទីផ្សារការងារ។ កម្មវិធីនេះផ្តល់ភាពសំខាន់ដល់ព័ត៌មានស្តីពីទីផ្សារការងារ និងគុណភាពនៃអ្នកស្វែងរកការងារធ្វើ។ទន្ទឹមនឹងនេះ កម្មវិធីបណ្តុះបណ្តាលសាធារណៈមួយចំនួនខ្វះខាតវិញ្ញាបនបត្រដែលទទួលស្គាល់ដោយនិយោជក។ បច្ចុប្បន្ននេះ ក្របខ័ណ្ឌគុណវុឌ្ឍិជាតិសម្រាប់កំណត់ស្តង់ដាសមត្ថភាពដែលបង្កើតឡើងដោយ MLVT នឹងជួយគាំទ្រដល់ប្រព័ន្ធវិញ្ញាបនបត្រដែលមានភាពចាំបាច់។ លើសពីនេះ គណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB) សហការជាមួយរដ្ឋាភិបាល តំណាងមកពីវិស័យឧស្សាហកម្ម និងអង្គការផ្សេងៗ ត្រូវបានបង្កើតឡើងសាជាថ្មីក្នុងឆ្នាំ២០០៦ ដើម្បីពិនិត្យមើលការបង្កើត និងការអនុវត្តគោលនយោបាយស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងផ្តល់ក្របខ័ណ្ឌអភិបាលកិច្ចមួយសម្រាប់ធ្វើសុខដុមនីយកម្មលើសហគមន៍ផ្តល់ការបណ្តុះបណ្តាលផ្សេងៗ។ ទោះជាយ៉ាងនេះក្តី ដំណើរការក្នុងការបង្កើតស្តង់ដា លក្ខណៈសម្បត្តិ និងការអនុវត្តការវាយតម្លៃមានភាពយឺតយ៉ាវ។

ការបង្រៀនបំណិនជីវិត។ ការបង្រៀនជំនាញអនុវត្ត និងបំណិនជីវិត តម្រូវឱ្យមានរួចជាស្រេចក្នុងកម្មវិធីសិក្សា (ហើយជាការទាមទាររបស់និយោជកដូចដែលបានបង្ហាញខាងលើ)។ ទោះជាយ៉ាងនេះក្តី សាលារៀនមួយចំនួនខ្វះគ្រូបង្រៀនដែលត្រូវបានបណ្តុះបណ្តាល ដើម្បីបង្រៀនបំណិនអនុវត្ត និងបំណិនជីវិត។ ភាគរយនៃគ្រូបង្រៀនមធ្យមសិក្សារួមជាមួយមធ្យមសិក្សាទុតិយភូមិ ឬឧត្តមសិក្សា បានកើនឡើងពី ៤០% ដល់ ៧១% ក្នុងទសវត្សរ៍កន្លងទៅ។ ស្របពេលមានការលើកកម្ពស់លក្ខណៈសម្បត្តិគ្រូបង្រៀនមួយចំនួននៅតែខ្វះខាតជំនាញក្នុងការបង្រៀនបំណិនជីវិត។ ជាក់ស្តែង គ្រូមួយចំនួនអាចត្រូវការជំនាញក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀនផ្សេងៗ ឧទាហរណ៍ ការសិក្សាជាក្រុម ការធ្វើបទបង្ហាញដោយសរសេរ និងផ្ទាល់មាត់ ការសម្តែងរឿង និងលំហាត់ដោះស្រាយបញ្ហាជាក្រុម ដើម្បីបង្កើតជំនាញអនុវត្ត និងបំណិនជីវិតរួមផ្សំនឹងកម្មវិធីសិក្សាដែលមានស្រាប់។

ឃ) ការបង្កើតបំណិនសម្រាប់កម្រិតឧត្តម ៖ មិនស្របតាមតម្រូវការកម្រិតឧត្តម ការអប់រំឧត្តមសិក្សាគឺដើម្បីបំពេញតម្រូវការសម្រាប់ឧស្សាហកម្មនាពេលបច្ចុប្បន្ន និងឧស្សាហកម្មថ្មីៗ។ ការអប់រំនេះអាចឱ្យនិយោជិតបង្កើនជំនាញរបស់ខ្លួន និងដើរទន្ទឹមនឹងការផ្លាស់ប្តូរបច្ចេកវិទ្យា។ គ្រឹះស្ថានឧត្តមសិក្សាមួយចំនួនមានសារៈសំខាន់សម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍព្រមទាំងជួយផ្ទេរ និងកែសម្រួលបច្ចេកវិទ្យានានា ដើម្បីបំពេញតម្រូវការឧស្សាហកម្មក្នុងស្រុក។ គ្រឹះស្ថានទាំងនោះ គឺមានសារៈសំខាន់សម្រាប់ការឆ្ពោះទៅកាន់សង្គមមួយដែលមានសេដ្ឋកិច្ចជឿនលឿន។

អត្រាចុះឈ្មោះចូលរៀនឧត្តមសិក្សាសរុបក្នុងគ្រឹះស្ថានសាធារណៈ និងឯកជនក្នុងប្រទេសកម្ពុជាបានកើនឡើងយ៉ាងឆាប់រហ័សក្នុងទសវត្សរ៍កន្លងមក បើទោះជា ចាប់ផ្តើមពីកម្រិតទាបបំផុតក៏ដោយ។ ពេលថ្មីៗនេះក្រុមអាយុចូលរៀនឧត្តមសិក្សាចំនួន ៥% បានចុះឈ្មោះចូលរៀនកម្រិតឧត្តមសិក្សាក្នុងនោះបុរសចំនួន ៧% និងស្ត្រីចំនួន ៤%។ អត្រាចុះឈ្មោះចូលរៀនទាំងនេះមានត្រឹមតែមួយភាគបីប៉ុណ្ណោះ ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងៗក្នុងតំបន់ (រូបភាពទី ៧) ប៉ុន្តែ អត្រានេះសមស្របទៅនឹងសេដ្ឋកិច្ចអតិពលកម្មនាពេលបច្ចុប្បន្ន និងភាពខុសគ្នានៃប្រាក់ឈ្នួល។

## រូបភាពទី ៨ : អត្រាចុះឈ្មោះចូលរៀនដុលក្នុងកម្រិតឧត្តមសិក្សា ដែលបែងចែកតាមយេនឌ័រ




**ប្រភព :** វិទ្យាស្ថានស្ថិតិអង្គការ UNESCO (ឆ្នាំ ២០០៩ ឬឆ្នាំចុងក្រោយបង្អស់)

បញ្ហាប្រឈមធ្ងន់ធ្ងរនឹងការសិក្សាមុខវិជ្ជា ដែលមិនទាក់ទងនឹងទីផ្សារការងារ ។ ស្ថាប័នឧត្តមសិក្សារបស់ប្រទេសកម្ពុជាផ្តល់ជំនាញដល់សិស្សបញ្ចប់ការសិក្សារួមមាន ជំនាញគណនេយ្យ ហិរញ្ញវត្ថុ និងគ្រប់គ្រង (សិស្សថ្នាក់បរិញ្ញាបត្រចំនួន ៤៦% ចុះឈ្មោះចូលរៀនមុខវិជ្ជាទាំងនេះនៅឆ្នាំសិក្សា ២០០៩/១០) ធៀបទៅនឹងមុខវិជ្ជាវិស្វកម្មស៊ីវិល (មានចំនួន ១,៥% ក្នុងចំណោមនិស្សិតដែលបានចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រ) និងមុខវិជ្ជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (មានចំនួន ០,១% ក្នុងចំណោមនិស្សិតចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រ) ។ លើសពីនេះ សមាមាត្រនិស្សិតជានារីក្នុងមុខវិជ្ជាវិស្វកម្ម វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាមានកម្រិតទាបបំផុត (សម្រាប់ព័ត៌មានលម្អិត សូមមើលតារាងទី ៤) ។ ទោះបីជាវិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទ ក្រៅពីផ្នែកកសិកម្មជាវិស័យសំខាន់សម្រាប់លើកកម្ពស់ក៏ដោយ ក៏មានសិស្សត្រឹមតែ ២,៣% ប៉ុណ្ណោះ ដែលសិក្សាមុខវិជ្ជាទាក់ទងនឹងចំណេះដឹងក្នុងវិស័យទាំងនេះ។ ភាគរយនៃនិស្សិតបញ្ចប់ការសិក្សាក្នុងមុខវិជ្ជាទាក់ទងនឹងវិស័យកសិកម្ម អប់រំ (រួមមាន គរុកោសល្យ) វិស្វកម្ម ផលិតកម្ម និងសំណង់នៅមានកម្រិតទាប បើប្រៀបធៀបនឹងបរទេស (រូបភាពទី ៨) ។ ភាពមិនសមស្របរវាងបំណិនកម្រិតឧត្តម និងតម្រូវការទីផ្សារ កាន់តែបង្ហាញឱ្យឃើញច្បាស់ (ធនាគារពិភពលោក ឆ្នាំ២០១០ គ) ។ភាពគ្មានការងារធ្វើ និងការខ្វះខាតការងារសម្រាប់និស្សិតបញ្ចប់ការសិក្សា គឺជាក្តីកង្វល់មួយដោយមាននិស្សិតបញ្ចប់ការសិក្សាចំនួន ១០% ត្រូវបានរាយការណ៍ថា ស្ថិតក្នុងស្ថានភាពធ្វើការងារដោយ "មិនមានប្រាក់កម្រៃ" និងនិស្សិតបញ្ចប់ការសិក្សាដែលមានអាយុ ២៩ ឆ្នាំ និងក្មេងជាងនេះចំនួន ៥% ត្រូវបានរាយការណ៍ថា គ្មានការងារធ្វើ (ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៩) ។

ចំនួននិស្សិតតិចតួចដែលបញ្ចប់ការសិក្សាផ្នែកវិស្វកម្ម និងវិទ្យាសាស្ត្រ ព្រមទាំងចំនួននិស្សិតភាគតិចដែលបញ្ចប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយមានការបណ្តុះបណ្តាលបន្ទាប់ពីមធ្យមសិក្សានឹងរារាំងសមត្ថភាពរបស់ប្រទេសកម្ពុជា ក្នុងការលើកកម្ពស់មូលដ្ឋានវិស័យកសិកម្ម និងឧស្សាហកម្មរបស់ខ្លួន។ ការសិក្សារបស់ធនាគារពិភពលោក (២០១០ ខ) បានប៉ាន់ស្មានថា ផ្អែកលើលំនាំនៃការអភិវឌ្ឍនាពេលបច្ចុប្បន្ន ប្រទេសកម្ពុជានឹងជួបប្រទះភាពលើសលុបនៃនិស្សិតបញ្ចប់ការសិក្សាថ្នាក់ឧត្តមផ្នែកពាណិជ្ជកម្ម និងច្បាប់ស្របពេលដែលនៅតែមានការខ្វះខាតនិស្សិតបញ្ចប់ការសិក្សាផ្នែកវិស្វកម្ម និងវិទ្យាសាស្ត្រ។ លើសពីនេះ ភាពខ្សោយឥតឈប់ឈរក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន និងការសិក្សាមុខវិជ្ជាដែលទាក់ទងនឹងវិស័យដែលជាតម្រូវការ នោះអាចធ្វើឱ្យរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់សមត្ថភាពនៃប្រព័ន្ធអប់រំ និងបណ្តុះបណ្តាល ។

## បញ្ហាទាក់ទងនឹងព័ត៌មាន និងការសម្របសម្រួល បានពន្យល់ពីអតុល្យភាពជារចនាសម្ព័ន្ធក្នុងការអប់រំឧត្ដមសិក្សា។

ការអង្កេតលើយុវជននាពេលថ្មីៗនេះ បានបង្ហាញឱ្យឃើញថា និស្សិតមួយចំនួនមិនបានយល់ច្បាស់ពីបំណិនដែលជាតម្រូវការរបស់និយោជកទេ។ ឧទាហរណ៍ មាននិស្សិតតែ ៧% ប៉ុណ្ណោះ ដែលជឿថា បញ្ហាប្រឈមធំបំផុតរបស់ខ្លួន គឺស្ថាប័នផ្ដល់ការអប់រំមិនបានបង្រៀនបំណិនដែលត្រឹមត្រូវ (ខណៈដែលយុវជនដែលមានការងារធ្វើចំនួន ១៦% ជឿថា បញ្ហានេះ គឺជាបញ្ហាប្រឈមដ៏ធំបំផុតរបស់ពួកគេ) (HRINC ឆ្នាំ២០១១)។ លើសពីនេះ ការអង្កេតមួយចំនួនទៀតបានបង្ហាញឱ្យ ឃើញថា នឹងមានឧបសគ្គក្នុងការទទួលព័ត៌មានដែលអាចទុកចិត្តបានស្ដីពីការសិក្សា និងឱកាសទទួលបានការងារ (រូបភាពទី ៩)។ ជាក់ស្ដែង យុវជនមិនទទួលបានព័ត៌មានដែលផ្ដល់ដោយរដ្ឋាភិបាល និងនិយោជកនោះទេ ហើយវិធីសាស្ត្រគាំទ្រផ្លូវការ ដូចជាការប្រឹក្សាយោបល់ស្ដីពីការងារ ហាក់ដូចជានៅមានភាពទន់ខ្សោយ (HRINC ឆ្នាំ២០១១ និង CAMFEBA ឆ្នាំ២០០៨)។ ការចែករំលែកព័ត៌មាន និងការសម្របសម្រួល ហាក់បីដូចជាមានភាពលំបាកដោយសារតែប្រតិបត្តិកររដ្ឋ និងឯកជនមួយចំនួន ត្រូវបានភ្ជាប់ទៅនឹងការអប់រំកម្រិតឧត្ដមសិក្សា រួមមាន ក្រសួងរបស់រដ្ឋាភិបាលចំនួនប្រាំបួន និងទីភ្នាក់ងារទាំងឡាយ ដែលផ្ដល់សេវាអប់រំកម្រិតឧត្ដមសិក្សា អមជាមួយគ្រឹះស្ថានឯកជន ដែលធ្វើប្រតិបត្តិការក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា។ លទ្ធភាពទទួលបានតិចតួចនូវព័ត៌មានដែលគួរឱ្យជឿជាក់ និងការគាំទ្រផ្លូវការ រួមផ្សំបន្ថែមលើការពឹងផ្អែកលើបណ្ដាញក្រៅប្រព័ន្ធក្នុងការធ្វើការសម្រេចចិត្តលើការសិក្សា និងការងារ គឺជាបញ្ហាដ៏សាមញ្ញ ដែលតែងតែកើតមានឡើងក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ រួមជាមួយផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើទីផ្សារការងារ។

### រូបភាពទី ៩ : ភាគរយនៃសិស្សបញ្ចប់ការអប់រំឧត្ដមសិក្សាតាមមុខវិជ្ជាជាអន្តរជាតិ




**ប្រភព :** EdStats (ឆ្នាំចុងក្រោយបង្អស់ ដែលអាចរកបានអំឡុងឆ្នាំ ២០០៥-២០០៩)

**កំណត់សម្គាល់ :** ក្រុមមុខវិជ្ជាដែលរួមបញ្ចូលគ្នា គឺផ្អែកលើចំណាត់ថ្នាក់មុខវិជ្ជាដែលបង្កើតឡើងក្នុងកម្រង សំណួរដែលបានប្រមូលពីវិទ្យាស្ថានស្ថិតិរបស់អង្គការ UNESCO (ឆ្នាំ២០០៩) : ការអប់រំ (ការបណ្ដុះបណ្ដាលគ្រូ បង្រៀន វិទ្យាសាស្ត្រអប់រំ) សិល្បៈ និងមនុស្សសាស្ត្រ (សិល្បៈ មនុស្សសាស្ត្រ) វិទ្យាសាស្ត្រសង្គម ពាណិជ្ជកម្ម និងច្បាប់ (វិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រសិក្សាពីអត្តចរិតមនុស្ស សារព័ត៌មាន និងព័ត៌មានវិទ្យា ពាណិជ្ជកម្ម និងរដ្ឋបាល ច្បាប់) វិទ្យាសាស្ត្រ (វិទ្យាសាស្ត្រពិត រូបវិទ្យា គណិតវិទ្យា និងស្ថិតិ ការគិតលេខ) វិស្វកម្ម ផលិតកម្ម និងសំណង់ (វិស្វកម្ម និងជំនួញវិស្វកម្ម ផលិតកម្ម និងការកែច្នៃ ស្ថាបត្យកម្ម និងសំណង់) កសិកម្ម (កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បសុព្យាបាល) សុខាភិបាល (សុខភាព សេវាសង្គម) និងសេវាកម្ម (សេវាកម្មផ្ទាល់ខ្លួនសេវា ដឹកជញ្ជូន ការពារបរិស្ថាន សេវាសន្តិសុខ)។

---

១៨ កំណត់ត្រាការងារយុវជនរបស់ធនាគារពិភពលោក មាននៅគេហទំព័រ http://www.youth-employment-inventory.org/

## តារាងទី ៣ : មុខវិជ្ជាដែលនិស្សិតបរិញ្ញាបត្រសិក្សាក្នុងឆ្នាំសិក្សា ២០០៩/២០១០

| មុខវិជ្ជាសិក្សា | ភាគរយ | ចំនួននិស្សិត | ភាគរយនៃនិស្សិតស្រី |
|---|---|---|---|
| គណនេយ្យ និងគណនេយ្យហិរញ្ញវត្ថុ | ១៣,០% | ២០.៩៧៨ | ៧៤,៧% |
| ហិរញ្ញវត្ថុ និងធនាគារ | ១១,០% | ១៧.៧៦០ | ៤១,១% |
| គ្រប់គ្រងពាណិជ្ជកម្ម និងពាណិជ្ជកម្ម រួមនឹងការគ្រប់គ្រងផ្សេងៗ | ១០,៣% | ១៦.៦៩៤ | ៣៦,៤% |
| ភាសា និងអក្សរសាស្ត្រអង់គ្លេស | ១១,៣% | ១៨.៣២៥ | ៥៤,៤% |
| គ្រប់គ្រង និងគ្រប់គ្រងទូទៅ | ៧,២% | ១១.៦៤០ | ២៨,២% |
| វិទ្យាសាស្ត្រកុំព្យូទ័រ និងវិទ្យាសាស្ត្រផ្សេងៗដែលទាក់ទងនឹងកុំព្យូទ័រ | ៦,៤% | ១០.៣២៣ | ៧,៤% |
| វេជ្ជសាស្ត្រ គិលានុបដ្ឋាក រោគសាស្ត្រកុមារ ទន្តសាស្ត្រ និងឱសថសាស្ត្រ | ៥,៨% | ៩.៤០៧ | ៤៦,៨% |
| ច្បាប់ និងនីតិសាស្ត្រ | ៥,៤% | ៨.៧៨៧ | ២២,៤% |
| សេដ្ឋកិច្ច និងមុខវិជ្ជាដែលជាប់ពាក់ព័ន្ធ | ៥,៣% | ៨.៤៨៥ | ៣៤,៩% |
| អប់រំ និងមុខវិជ្ជាដែលជាប់ពាក់ព័ន្ធ | ២,៤% | ៣.៨០៨ | ២៩,១% |
| កសិកម្ម រួមមាន នេសាទ និងរុក្ខាប្រមាញ់ ព្រមទាំងអភិវឌ្ឍន៍ជនបទ | ២,៣% | ៣.៧៥៣ | ២៩,១% |
| អក្សរសាស្ត្រខ្មែរ និងវិទ្យាសាស្ត្រ | ១,៧% | ២.៧៩៤ | ៤៣,៦% |
| ទីផ្សារ និងគ្រប់គ្រងទីផ្សារ | ១,៧% | ២.៦៩៤ | ២៦,៥% |
| ទេសចរណ៍ និងសណ្ឋាគារ និងបដិសណ្ឋារកិច្ច | ១,៧% | ២.៧៧១ | ៣៩,៣% |
| វិស្វកម្មសំណង់ស៊ីវិល | ១,៥% | ២.៣៧១ | ១,៧% |
| វិទ្យាសាស្ត្រសង្គមផ្សេងៗ (រដ្ឋបាលសាធារណៈ វិទ្យាសាស្ត្រនយោបាយ និងសង្គមវិទ្យា) | ១,៤% | ២.៣១០ | ៣៩,៥% |
| ស្ថាបត្យកម្ម និងរចនាប្លង់ | ១,៣% | ២.០៥៨ | ២១,៣% |
| គណិតវិទ្យា | ១,៣% | ២.០៧១ | ២១,៥% |
| ជីវវិទ្យា និងគីមីវិទ្យា | ០,៩% | ១.៣៨៦ | ៤០,៨% |
| វិស្វកម្ម និងមុខវិជ្ជាដែលជាប់ពាក់ព័ន្ធ | ០,៩% | ១.៣៩៩ | ៤,៥% |
| សិល្បៈ មនុស្សសាស្ត្រ និងភាសា ទស្សនៈវិជ្ជា និងសាសនា | ០,៨% | ១.៣០៦ | ៣០,៩% |
| គ្រប់គ្រងធនធានមនុស្ស | ០,៦% | ៩៩១ | ១៧,០% |
| រូបវិទ្យា | ០,៦% | ៩០៨ | ២៤,៣% |
| បសុព្យាបាល និងបសុពេទ្យ | ០,៥% | ៨៧៩ | ១៩,១% |
| ភាសាផ្សេងៗ (ភាសាកូរ៉េ ជប៉ុន បារាំង និងថៃ) | ០,៥% | ៨៧៣ | ៤៧,១% |
| ភូមិវិទ្យា | ០,៣% | ៤៧៦ | ៣៩,៩% |
| ប្រវត្តិវិទ្យា | ០,៣% | ៥៥៨ | ៣២,៨% |
| វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ០,១% | ២០១ | ៦,០% |
| មុខវិជ្ជាផ្សេងៗ (យោធា បណ្ឌិតសភានគរបាល ។ល។) | ៣,៤% | ៥.៥១០ | ៣៣,០% |
| សរុប | ១០០,០% | ១៦១.៥១៦ | ៣៩,៤% |

**ប្រភព :** គណនាដោយផ្អែកលើទិន្នន័យប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ

## រូបភាពទី ១០ : ប្រភពព័ត៌មានស្តីពីការសិក្សា និងការងារ




**ប្រភព :** ការអង្កេតលើយុវជនដែលបានអនុវត្តឡើងដោយ HRINC កម្ពុជា ក្នុងខែមីនា ឆ្នាំ២០១១។

ហិរញ្ញប្បទានសម្រាប់ការអប់រំឧត្តមសិក្សារួមចំណែកដល់ការផ្លាស់ប្តូរ។ ការចំណាយរបស់រដ្ឋាភិបាលលើការអប់រំឧត្តមសិក្សាមានកម្រិតទាបត្រឹមតែ ០,១%ប៉ុណ្ណោះ ហើយបានផ្តោតសំខាន់ទៅលើការពង្រីកការអប់រំជាជាងយុទ្ធសាស្ត្រ និងគុណភាពនៃការអប់រំ (ធនាគារពិភពលោក ឆ្នាំ២០១០ គ)។ ឧបត្ថម្ភធនសាធារណៈ អាចធ្វើឱ្យមានការកែប្រែផលចំណេញនៃវិស័យសេដ្ឋកិច្ចឯកជនសម្រាប់មុខវិជ្ជាទាក់ទងនឹងវិទ្យាសាស្ត្រសង្គម។ ក្នុងមុខវិជ្ជាដែលសម្បូរបែបទាំងនេះ ថ្លៃសិក្សាខ្ពស់អាចជួយសម្រួលដល់ផលប្រយោជន៍ទីផ្សារយ៉ាងមានប្រសិទ្ធភាពសម្រាប់ការវិនិយោគជាលក្ខណៈបុគ្គល។ ផ្ទុយមកវិញ មុខវិជ្ជាដូចជា វិស្វកម្ម វិទ្យាសាស្ត្រ និងគណិតវិទ្យា ដែលមិនសូវមានការពេញនិយមនោះ មិនទទួលបានការយកចិត្តទុកដាក់លើយុទ្ធសាស្ត្រ និងធនធានដែលចាំបាច់ក្នុងប្រព័ន្ធអប់រំទាំងមូលនោះទេ បើទោះជាមុខវិជ្ជាទាំងនេះ មានសារៈសំខាន់សម្រាប់ការរីកចម្រើននៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាក៏ដោយ។ ដោយសារតែការចំណាយតិចតួចរបស់រដ្ឋាភិបាលលើវិស័យអប់រំ រួមនឹងចំនួនយុវវ័យយ៉ាងច្រើនដែលមិនទទួលបាន សូម្បីតែការអប់រំកម្រិតមូលដ្ឋានផងនោះ លទ្ធផលរកឃើញទាំងនេះបានបង្ហាញពីតម្រូវការបន្ទាន់ដើម្បីពិនិត្យឡើងវិញនូវការបែងចែកការចំណាយលើវិស័យអប់រំក្នុងប្រទេសកម្ពុជា ព្រមទាំងរៀបចំសាជាថ្មីនូវអាទិភាពនានាសម្រាប់ការប្រើប្រាស់ធនធានរបស់រដ្ឋ។

១៩ ការយល់ដឹងពីមូលហេតុនៃការខ្វះខាត និងភាពមិនសមស្របនៃបំណិន ទាមទារឱ្យមានការពិនិត្យមើលទីផ្សារដែលមានសក្តានុពល និងការបរាជ័យនៃអភិបាលកិច្ចដែលបង្វៀងតម្រូវការ និងការផ្តល់បំណិនពី "កម្រិតល្អបំផុតនៃសង្គម" និងប៉ះពាល់ដល់ភាពសមស្របរវាងតម្រូវការបំណិន និងការផ្តល់បំណិនក្នុងទីផ្សារការងារ។ ការបរាជ័យមួយចំនួន ជាប់ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំ និងការបណ្តុះបណ្តាល ហើយមួយចំនួនទៀតទាក់ទងនឹងឧបសគ្គ ដែលបុគ្គលម្នាក់ៗជួបប្រទះក្នុងការទទួលបានព័ត៌មាន និងប្រាក់កម្ចីហើយមួយចំនួនទៀត ជាធម្មតាឆ្លុះបញ្ចាំងពីភាពខ្សោយនៃចំណេះដឹងក្នុងគ្រួសារ។ លក្ខណៈសម្បត្តិជាក់លាក់នៃទីផ្សារផលិតផល និងការងារ ក៏អាចជះឥទ្ធិពលដល់សហគ្រាសក្នុងការផ្តល់ប្រាក់លើកទឹកចិត្តសម្រាប់និយោជិតតាមជំនាញជាក់លាក់ ឬនិយោជិតដែលមានការបណ្តុះបណ្តាល និងនិយោជិតឱ្យមានជំនាញកាន់តែខ្ពស់។

## ២.៣ តើការខ្វះខាត និងភាពមិនសមស្របនៃបំណិនក្នុងប្រទេសកម្ពុជា បណ្តាលមកពីមូលហេតុអ្វីខ្លះ?

មូលហេតុនៃការខ្វះខាត និងភាពមិនសមស្របនៃបំណិនក្នុងប្រទេសកម្ពុជា បង្ហាញឱ្យឃើញនៅផ្នែកព័ត៌មាន និងការសម្របសម្រួល។ ការបរាជ័យនៃការផ្តល់ព័ត៌មាន និងការសម្របសម្រួល គឺជាបញ្ហាពិតក្នុងទីផ្សារការងារ (ផ្នែកតម្រូវការ) និងទីផ្សារជំនាញ។ ចំណែកផ្នែកផ្តល់តម្រូវការមូលហេតុមានភាពស្មុគស្មាញជាងនេះ។ រូបភាពទី ១០ បង្ហាញពីសេចក្តីសង្ខេបពីមូលហេតុចម្បងៗ ដែលបានកំណត់ក្នុងឯកសារគោលនយោបាយនេះ។

ក្នុងផ្នែកតម្រូវការ សហគ្រាសមួយចំនួនហាក់បីដូចជាខ្វះខាតមធ្យោបាយក្នុងការបំពេញតម្រូវការរបស់ខ្លួន។ ការបង្ហាញពីប្រាក់ឈ្នួល ហាក់បីដូចជាមិនទាន់គ្រប់គ្រាន់។ ម៉្យាងវិញទៀត សហគ្រាសមួយចំនួនហាក់ដូចជាមិនមានប្រសិទ្ធភាពក្នុងការបង្ហាញពីតម្រូវការរបស់ខ្លួនសម្រាប់បំណិនជាក់លាក់ និងឥទ្ធិពលលើគោលនយោបាយអភិវឌ្ឍន៍បំណិននោះទេ។ ដូចដែលបានបង្ហាញខាងលើផលលំបាករបស់សហគ្រាសទាំងនោះ ក្នុងការសម្របសម្រួលការបណ្តុះបណ្តាលសម្រាប់និយោជិតរបស់ខ្លួន ក៏បានគូសបញ្ជាក់ពីមូលហេតុដែលទាក់ទងនឹងបញ្ហាព័ត៌មានផងដែរ។ ការណែនាំរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB) ជាមួយសមាជិកភាពមកពីវិស័យឯកជន គឺការផ្តល់យន្តការមួយដែលអាចឱ្យសហគ្រាសនានាពន្យល់បង្ហាញពីតម្រូវការរបស់ខ្លួនសម្រាប់បំណិនជាក់លាក់ទាំងឡាយដល់រដ្ឋាភិបាល និងសហគមន៍ផ្តល់ការបណ្តុះបណ្តាល។ ក្នុងបណ្តាប្រទេសផ្សេងទៀត ជាញឹកញាប់គណៈកម្មាធិការជាតិបណ្តុះបណ្តាលតែងតែចូលរួមក្នុងការពិនិត្យឡើងវិញលើគោលនយោបាយរបស់រដ្ឋាភិបាលសម្រាប់ការអប់រំ និងការបណ្តុះបណ្តាលព្រមទាំងការបែងចែកហិរញ្ញវត្ថុសាធារណៈសម្រាប់គោលបំណងនេះផងដែរ។ ការពង្រឹងក្រុមគណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB) ដើម្បីផ្តល់លទ្ធភាពដល់ក្រុមហ៊ុន បញ្ជូនតម្រូវការរបស់ខ្លួនទៅរដ្ឋាភិបាល និងការបណ្តុះបណ្តាលដល់សហគមន៍ អាចមានតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងព័ត៌មាន។

ចំណែកផ្នែកផ្តល់តម្រូវការវិញ បណ្តុំនៃមូលហេតុ គឺទាក់ទងនឹងហិរញ្ញប្បទាន គុណភាព និងវិសាលភាពនៃការអប់រំ និងការបណ្តុះបណ្តាល។ បញ្ហាប្រឈមក្នុងការគ្រប់គ្រងធនធានតាមរបៀបមួយដែលលើកទឹកចិត្តដល់អ្នកបំពេញការងារល្អ និងមានការទទួលខុសត្រូវលើលទ្ធផល បញ្ហាប្រឈមក្នុងការបង្រៀនបំណិនជីវិត និងជំនាញបច្ចេកទេស (និងលក្ខណៈសម្បត្តិគ្រូបង្រៀន និងការបណ្តុះបណ្តាលទូទៅ) និងភ្ជាប់ទំនាក់ទំនងរវាងសាលារៀន និងឧស្សាហកម្មឱ្យកាន់តែជិតស្និទ្ធដើម្បីលើកកម្ពស់គុណភាព និងទំនាក់ទំនងតម្រូវការទីផ្សារ។ លើសពីនេះ បុព្វហេតុទាំងនេះរាប់បញ្ចូលទាំងបញ្ហាប្រឈមក្នុងការបន្តផ្តល់ជំនួយដល់គ្រួសារដើម្បីរៀបចំឱ្យកុមារបានចូលរៀន។ បញ្ហាប្រឈមទាំងនេះ ទាមទារឱ្យមានការផ្តោតការយកចិត្តទុកដាក់ឱ្យបានម៉ត់ចត់ ហើយបញ្ហាទាំងនេះអាចមានការឆ្លើយតបផ្សេងៗគ្នាក្នុងគ្រប់ដំណាក់កាលនីមួយៗនៃវដ្តជីវិត។ គោលនយោបាយនឹងតម្រូវឱ្យកំណត់ពីតួនាទីទាំងវិស័យសាធារណៈ និងឯកជនក្នុងការបែងចែកការផ្តល់ហិរញ្ញប្បទាន គុណភាព និងវិសាលភាពនៃការអប់រំ និងការបណ្តុះបណ្តាល។ ភាពខ្សោយដែលមានស្រាប់ក្នុងទីផ្សារបំណិនបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីស្ថាប័នទីផ្សារដែលទន់ខ្សោយ។ ដើម្បីភ្ជាប់តម្រូវការ និងការផ្តល់តម្រូវការនៃបំណិននានា ស្ថាប័នទីផ្សារទាំងឡាយមានមុខងារសំខាន់ៗប្រាំយ៉ាង គឺ ៖

- ការសម្របសម្រួលដើម្បីដាក់បញ្ចូលផ្នែកទាំងពីរនៃទីផ្សារការងារ (តួនាទីរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល)
- សេវាស្វែងរកការងារ ដើម្បីផ្តល់យោបល់ដល់អ្នកស្វែងរកការងារធ្វើ ស្តីពីឱកាសការងារ និងទីកន្លែងដែលអាចបណ្តុះបណ្តាលបំណិន (តួនាទីរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារដែលទើបនឹងបង្កើតថ្មី – NEA)
- ការធានាគុណភាព ដើម្បីកំណត់ពីស្តង់ដាបំណិន និងធ្វើតេស្តព្រមទាំងធ្វើការបញ្ជាក់ពីបំណិនទាំងនោះ (តួនាទីរបស់ក្របខ័ណ្ឌគុណវុឌ្ឍិជាតិដែលស្ថិតក្រោមការអភិវឌ្ឍ)
- ការផ្តល់អាជ្ញាប័ណ្ណ និងបទបញ្ជា ដើម្បីកំណត់ស្តង់ដាអប្បបរមាសម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលបំណិនឯកជនទាំងឡាយ និងសម្រួលដល់កិច្ចការពារអ្នកប្រើប្រាស់ និង
- ការទទួលស្គាល់គុណភាព ដើម្បីផ្តល់ព័ត៌មានស្តីពីគុណភាពនៃការអប់រំ និងការបណ្តុះបណ្តាលដែលផ្តល់ដោយសាលា និងមជ្ឈមណ្ឌលបណ្តុះបណ្តាល ។
- ស្ថាប័នទាំងនេះ សម្របសម្រួលប្រតិបត្តិការនៃទីផ្សារបំណិនដែលមានប្រសិទ្ធភាព ហើយស្ថាប័នទីផ្សារមិនអាច រួមបញ្ចូលក្នុងវិស័យឯកជនបានទេ ដោយសារតែលក្ខណៈគុណភាពអប់រំរបស់ស្ថាប័នសាធារណៈទាំងនោះ ។ រដ្ឋាភិបាលអាចបំពេញចន្លោះខ្វះខាតនេះបាន និងដើរតួនាទីចម្បងក្នុងការត្រួតពិនិត្យលទ្ធផលនៃទីផ្សារការងារ និងបង្កើតគោលនយោបាយឱ្យបានសមរម្យ ។

រូបភាពទី ១១ : ការកំណត់ពីមូលហេតុនៃការខ្វះខាត និងភាពមិនសមស្របនៃបំណិនក្នុងប្រទេសកម្ពុជា




**ប្រភព :** អ្នកនិពន្ធ

# ៣

# សកម្មភាព និងយុទ្ធសាស្ត្រ សម្រាប់បំណិន ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា

មូលដ្ឋានធនធានមនុស្សរបស់ប្រទេសកម្ពុជា ចង្អុលបង្ហាញពីភាពខ្លាំងមួយចំនួនដែលកម្ពុជាអាចពង្រឹងបាន ។ ក្នុងដំណាក់កាលអតិពលកម្មនៃការអភិវឌ្ឍនាពេលថ្មីៗ រួមនឹងការបង្កើតមូលដ្ឋានគ្រឹះនៃបំណិន ដើម្បីស្វែងយល់ពីយុទ្ធសាស្ត្រនៃកំណើនសេដ្ឋកិច្ចរបស់ខ្លួន កម្ពុជាត្រូវធានាឱ្យមានការអភិវឌ្ឍកុមារតូចឱ្យបានសមរម្យ រួមនឹងការបញ្ចប់ការអប់រំមូលដ្ឋានឱ្យបានត្រឹមថ្នាក់ទី ៩ ប្រកបដោយគុណភាពសម្រាប់យុវជនទាំងអស់ ។ ការកសាងមូលដ្ឋានគ្រឹះ ដើម្បីការអភិវឌ្ឍបំណិននាពេលអនាគតចាំបាច់ត្រូវផ្អែកលើប្រសិទ្ធភាព និងសមធម៌ ។ ប្រសិនបើមិនមានការបណ្តុះបណ្តាលមូលដ្ឋានគ្រឹះប្រកបដោយគុណភាពល្អនោះទេ នោះការបណ្តុះបណ្តាលនិយោជិតនៅក្នុងដំណាក់កាលវដ្តជីវិត បន្ទាប់មិនអាចទទួលបានជោគជ័យឡើយ ។ នេះ គឺជាយុទ្ធវិធីមួយដែលប្រទេសចិនធ្លាប់យកមកអនុវត្ត នៅពេលប្រទេសចិនពឹងផ្អែកលើសេដ្ឋកិច្ចក្នុងប្រទេសក្នុងឆ្នាំ១៩៧៩ ហើយមានប្រទេសមួយចំនួនទៀតអនុវត្តយុទ្ធវិធីនេះដែរ ដូចជា ប្រទេសឈីលី មិកស៊ិកូ សិង្ហបូរី និងកូរ៉េខាងត្បូង ។ ប្រទេសទាំងនេះចាប់ផ្តើមផ្តល់ការអប់រំកម្រិតមូលដ្ឋានប្រកបដោយគុណភាពល្អដើម្បីអភិវឌ្ឍជំនាញនិយោជិតនាពេលអនាគត ។

កម្ពុជាគួរផ្តល់អាទិភាពបំណិនមូលដ្ឋានប្រកបដោយគុណភាព និងបំណិនមុនចូលបំពេញការងារ ពិសេសបំណិនទាក់ទងនឹងគណិតវិទ្យា វិទ្យាសាស្ត្រ និងវិស្វកម្ម ។ ការធ្វើបែបនេះតម្រូវឱ្យរដ្ឋាភិបាលធ្វើការងារជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងការផ្តល់ និងគាំទ្រហិរញ្ញប្បទានសម្រាប់បំណិនទាំងនេះ រួមមានបំណិនក្នុងការអប់រំកម្រិតឧត្តមផងដែរ ។ ដោយការពង្រឹងស្ថាប័នទីផ្សារដែលលើកកម្ពស់គុណភាព និងទំនាក់ទំនងនៃការវិនិយោគលើការអប់រំ និងបណ្តុះបណ្តាលកម្ពុជាអាចបង្កើនលទ្ធផលការងារក្នុងការចំណាយជាសាធារណៈ និងឯកជនបាន ។ យោងទៅតាមការបែងចែកជាថ្មីក្នុងការចំណាយផ្ទាល់លើការអប់រំការបណ្តុះបណ្តាល ព្រមទាំងការធ្វើការងារជាដៃគូជាមួយស្ថានប័នបណ្តុះបណ្តាលបំណិនមិនមែនរដ្ឋាភិបាលដើម្បីបំពេញតាមតម្រូវការសង្គមនូវបំណិនមួយចំនួន ដូចជា ការបណ្តុះបណ្តាលពាណិជ្ជកម្ម រដ្ឋាភិបាលអាចប្រើប្រាស់ធនធានរបស់ខ្លួនទៅតាមយុទ្ធសាស្ត្របានប្រសើរជាងមុនក្នុងការបំពេញតម្រូវការទីផ្សារ និងគាំទ្រដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច ។

គណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB) អនុវត្តនូវគំនិតផ្តួចផ្តើមដ៏ល្អទាក់ទងនឹងការបង្កើតបំណិនមុនទទួលបានការងារ និងការប្រើប្រាស់បំណិនទាំងនេះ ។ គណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB) មាន

ការយកចិត្តទុកដាក់ក្នុងការបង្កើតគោលនយោបាយ និងអភិបាលកិច្ចជាប្រព័ន្ធតាមរយៈការអនុវត្តការងារជាក់ស្តែងដោយការបង្កើតស្តង់ដា គុណវុឌ្ឍិ និងការអនុវត្តការវាយតម្លៃ។ នៅឆ្នាំ២០០៩ ក្នុងការទទួលស្គាល់ពីតម្រូវការទទួលបានព័ត៌មានឱ្យកាន់តែប្រសើរនោះ គណៈកម្មាធិការជាតិបណ្តុះបណ្តាលបានបង្កើតទីភ្នាក់ងារជាតិមុខរបរ និងការងារ (NTB) ដើម្បីផ្តល់សេវាការងារ និងសេវាព័ត៌មានទីផ្សារការងារដល់អ្នកស្វែងរកការងារធ្វើ និយោជិត និយោជក ស្ថាប័នបណ្តុះបណ្តាល និងសាធារណជនទូទៅ។ ចុងបញ្ចប់ គណៈកម្មាធិការជាតិបណ្តុះបណ្តាលបាន និងកំពុងសម្របសម្រួលគម្រោងពង្រឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (ផ្តល់មូលនិធិដោយធនាគារពិភពលោក)។ គម្រោងនេះបង្កើតឡើងក្នុងគោលបំណងបង្កើតប្រព័ន្ធពង្រីកការបណ្តុះបណ្តាលចម្រុះទៅតាមតម្រូវការឧស្សាហកម្ម និងស្របទៅតាមតម្រូវការបំណិនមូលដ្ឋាន និងបំណិនកម្រិតមធ្យមនៅក្នុងវិស័យសំខាន់ៗ។

## ៣.១ ការបង្កើតផែនការសកម្មភាពបំណិន

ការបំពេញគំនិតផ្តួចផ្តើមផ្នែកគោលនយោបាយកំពុងដំណើរការ ដូចនេះ ផែនការសកម្មភាពបំណិនរបស់ប្រទេសកម្ពុជាចាំបាច់ត្រូវដោះស្រាយឧបសគ្គចម្បងសម្រាប់បំណិន ដើម្បីឈានទៅសម្រេចបំណងប្រាថ្នារបស់ខ្លួន។ ដោយសកម្មភាពនេះជាសកម្មភាពអាទិភាពបន្ទាន់ រដ្ឋាភិបាលអាចសម្របសម្រួលលទ្ធភាព

តារាងលេខ ៤ : ផែនការសកម្មភាពអភិវឌ្ឍន៍បំណិន ជម្រើសសម្រាប់កម្ពុជា

| គោលបំណង | សកម្មភាពត្រូវអនុវត្តបន្ទាន់ | ការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ពេលអនាគត |
|---|---|---|
| ១ ការទទួលបានព័ត៌មាន | • លើកកម្ពស់សមត្ថភាពក្នុងការប្រឹក្សាការងារ និងសេវាស្វែងរកការងារ<br>• ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដើម្បីបង្ហាញពីឱកាសសិក្សា និងការងារ និងការលើកកម្ពស់ការអប់រំ បណ្តុះបណ្តាល វិជ្ជាជីវៈ | • លើកកម្ពស់សមត្ថភាពរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងភាពជាដៃគូជាមួយវិស័យឯកជន |
| ២ វិសាលភាព "ភាពចន្លោះនៅកម្រិតកណ្តាល" | • បញ្ជ្រាបកម្មវិធីអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានគុណភាពល្អ | • ពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាលក្នុងកំណែទម្រង់ការអប់រំ និងបណ្តុះបណ្តាលនិយោជក<br>• ពិចារណាលើមធ្យោបាយជំរុញឱ្យនិយោជកចំណាយលើការបណ្តុះបណ្តាលកម្លាំងពលកម្មរបស់ខ្លួន |
| ៣ គុណភាព និងភាពពាក់ព័ន្ធទីផ្សារ | • ចាប់ផ្តើមបង្កើនចំនួនស្ថាប័នបណ្តុះបណ្តាលបំណិន រួមមាន មជ្ឈមណ្ឌលបណ្តុះបណ្តាលក្រៅប្រព័ន្ធដោយសហការជាមួយឧស្សាហកម្មក្នុងស្រុក | • កំណែទម្រង់កម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សា ដើម្បីលើកកម្ពស់ការបង្រៀនវិទ្យាសាស្ត្រ គណិតវិទ្យា វិស្វកម្ម និងមុខវិជ្ជាបច្ចេកទេសផ្សេងទៀត ភាពជាសហគ្រិន និងបំណិនជីវិត<br>• ពង្រឹងការទទួលខុសត្រូវរបស់សហគមន៍ និងសាលារៀន ដែលជាផ្នែកមួយនៃដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ |
| ៤ ប្រសិទ្ធភាពហិរញ្ញប្បទាន | • ពង្រីកវិធីសាស្ត្រផ្តល់ហិរញ្ញប្បទានតម្រង់ទិសគ្រួសារ ដើម្បីរក្សាអត្រាគង់វង្សនៃការសិក្សា | • បង្កើនការចំណាយទៅលើបទអន្តរាគមន៍ ដែលមានការចំណាយតិចតួចនៅដំណាក់កាលដំបូងនៃវដ្តជីវិត<br>• ស្វែងរកវិធីសាស្ត្រហិរញ្ញប្បទាននានា ដើម្បីជំរុញឱ្យមានការលើកទឹកចិត្តចំពោះស្ថាប័នដែលមានលទ្ធផលបណ្តុះបណ្តាលល្អក្នុងចំណោមស្ថាប័នបណ្តុះបណ្តាលបំណិន និងគ្រឹះស្ថានឧត្តមសិក្សា |

ទទួលបានព័ត៌មានក្នុងទីផ្សារបំណិន ពង្រីកអន្តរាគមន៍ តម្រង់ទិសគ្រូសារ ដើម្បីលើកកម្ពស់អត្រាគង់វង្ស នៃការសិក្សា និងពង្រឹងឱកាសសិក្សាលើកទី២ ព្រមទាំងការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ។ ដើម្បីរៀបចំមូលដ្ឋានគ្រឹះសម្រាប់ពេលអនាគត រដ្ឋាភិបាលគួរពង្រីកហិរញ្ញប្បទានសម្រាប់ការ អភិវឌ្ឍកុមារតូច ពង្រឹងការអភិវឌ្ឍស្ថាប័ន និងជំរុញឱ្យមានការលើកទឹកចិត្តចំពោះស្ថាប័នបណ្តុះបណ្តាល ដែលមានគុណភាពល្អ រួមមាន គ្រឹះស្ថានឧត្តមសិក្សាជាដើម។ តារាងលេខ ៥ សង្ខេបពីសកម្មភាពដែល បានលើកឡើងសម្រាប់ការពិចារណា និងផ្នែកនៅសល់នៃចំណុចនេះផ្តល់ព័ត៌មានបន្ថែមទៀត។

## (១) ការសម្របសម្រួលឱ្យមានលទ្ធភាពទទួលបានព័ត៌មានស្តីពីទីផ្សារបំណិន

លទ្ធភាពទទួលបានព័ត៌មានគ្រប់គ្រាន់បង្កើតឱ្យមានប្រសិទ្ធភាពនៅលើទីផ្សារការងារ និងផ្តល់ផលចំណេញ ដល់និយោជិតក៏ដូចជានិយោជក។ ការទទួលបានព័ត៌មានគ្រប់គ្រាន់តម្រូវឱ្យមានការពង្រឹងស្ថាប័នទីផ្សារ ដែលបានលើកឡើងនៅចំណុច ២.៣ ដែលនឹងចំណាយពេលច្រើន។ ទោះជាយ៉ាងណា សកម្មភាពគោលដៅ អាចជួយរុញច្រានឧបសគ្គចម្បងចេញបានឱ្យកាន់តែរហ័ស។ ឧទាហរណ៍ ការចាត់វិធានការលើកកម្ពស់ សេវាការងារ និងព័ត៌មានទីផ្សារការងារសម្រាប់ការងារក្នុងសេដ្ឋកិច្ចអន្តរកាលនៅអឺរ៉ុបកណ្តាលនៅទសវត្សរ៍ ឆ្នាំ១៩៩០ បានផ្តល់ឱ្យមានភាគលាភយ៉ាងច្រើនសម្រាប់ការលើកកម្ពស់ចល័តភាពនៃពលកម្ម និងប្រសិទ្ធភាព នៃការប្រើប្រាស់កម្លាំងការងារ។

### ក) សកម្មភាពដែលត្រូវអនុវត្តបន្ទាន់ ដើម្បីសម្របសម្រួលដល់ការទទួលបានព័ត៌មាននៅលើទីផ្សារ ការងារ

ដោយសារសកម្មភាពនេះជាសកម្មភាពអាទិភាពបន្ទាន់ កម្ពុជាគួរពិចារណាលើវិធានការនានាដើម្បី ពង្រឹងសមត្ថភាពក្នុងការប្រឹក្សាការងារ និងសេវាស្វែងរកការងារ ហើយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីផ្តល់ព័ត៌មានស្តីពីការសិក្សា និងឱកាសការងារ និងលើកកម្ពស់ការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ :

**សកម្មភាពទី១ :** លើកកម្ពស់សមត្ថភាពក្នុងការប្រឹក្សាការងារ និងសេវាស្វែងរកការងារ

សាកលវិទ្យាល័យ និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមួយចំនួនបង្កើតឱ្យ មានអង្គភាពប្រឹក្សាការងារ ដើម្បីផ្តល់ព័ត៌មាន ស្តីពីការងារ ការប្រឹក្សាការងារ និងជំនួយ ដល់សិស្សក្នុងការស្វែងរកការងារ។ តែទោះជាយ៉ាងណា ការលើកកម្ពស់គុណភាពព័ត៌មាន និងសេវាដែលផ្តល់ដោយអង្គភាពទាំងនេះ គឺត្រូវការចំណាយពេលវេលាច្រើនផងដែរ។ ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡា អាចជួយពង្រឹង សមត្ថភាពរបស់អង្គភាពទាំងនេះ ក៏ដូចជាបុគ្គលពាក់ព័ន្ធនៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈផងដែរ បានតាមរយៈការសម្របសម្រួលឱ្យមានការបង្កើតកម្មវិធី បណ្តុះបណ្តាលសម្រាប់បុគ្គលិកផ្តល់ប្រឹក្សា ហើយក៏គួរមានការផ្តល់ការងារ សេវាការងារ និង សិក្ខាសាលាស្តីពីការងារនៅកម្រិតមធ្យមសិក្សាផងដែរ។ ទីភ្នាក់ងារជាតិ មុខរបរ និងការងារ

---

២០ សមាគមនិយោជកឯកជន ដូចជា CAMFEBA ឬទីភ្នាក់ងារស្រាវជ្រាវក្នុងស្រុក អាចជួយក្នុងការអង្កេតនេះបាន ដែលអាចបង្កើតឱកាស ការងារកាន់តែច្រើនក្នុងការបណ្តុះបណ្តាល និងការកសាងសមត្ថភាពរបស់យុវជន។

២១ ដូចដែលបានបញ្ជាក់តាមរយៈប្រសាសន៍របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន នាយករដ្ឋមន្ត្រីប្រទេសកម្ពុជានៅព្រឹត្តិការណ៍ទាំងពីរ។

គួរបង្កើតទំនាក់ទំនងឱ្យបានរឹងមាំងជាមួយអង្គភាពផ្តល់ប្រឹក្សាការងារបែបនេះ និងធ្វើការសម្របសម្រួលយ៉ាងសកម្មដើម្បីទទួលបានព័ត៌មានពាក់ព័ន្ធទីផ្សារផ្សេងទៀត។

**សកម្មភាពទី ២ :** ប្រើប្រាស់ទូរទស្សន៍ និងវិទ្យុ ដើម្បីផ្សព្វផ្សាយព័ត៌មានសិក្សា ឱកាសការងារ និងការលើកកម្ពស់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

រដ្ឋាភិបាលអាចលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងកម្មវិធីវិទ្យុ និងទូរទស្សន៍ផ្សព្វផ្សាយជាសាធារណៈស្តីពីការអប់រំ និងឱកាសការងារដោយផ្តោតលើឧស្សាហកម្ម និងការងារដែលប្រឈមនឹងការខ្វះខាតកម្លាំង ការងារឥតឈប់ឈរ ហើយតួនាទីរបស់ TVET ជាជម្រើសមួយដ៏ល្អបំផុតសម្រាប់ការអប់រំនៅសាកលវិទ្យាល័យ។ កម្មវិធីនានា ក៏អាចទាញយកពីអ៊ីនធើណេតចែកចាយជា DVDs/CDs នៅឯវេទិកាការងារប្រចាំឆ្នាំ មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្ត សហគមន៍ វេទិកាតាមភូមិ និងនៅកន្លែងផ្សេងទៀត ដែលមានយុវជនប្រមូលផ្តុំគ្នា។ ប្រទេសសិង្ហបុរីទទួលបានជោគជ័យយ៉ាងខ្លាំង ក្នុងការលើកកម្ពស់ការទទួលស្គាល់របស់គ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈមធ្យោបាយជាច្រើន និងដោយការវិនិយោគយ៉ាងច្រើនលើការលើកកម្ពស់គុណភាពសេវាផ្តល់ឱ្យ។ ការវិនិយោគទុនមានការគាំទ្រពីវិស័យឯកជនតាមរយៈដៃគូឯកជនសាធារណៈ។

### ៩) ការបង្កើតមូលដ្ឋានគ្រឹះសម្រាប់លទ្ធភាពទទួលបានព័ត៌មាននៅលើទីផ្សារការងារពេលអនាគត

ដើម្បីបង្កើតមូលដ្ឋានគ្រឹះសម្រាប់អនាគត រដ្ឋាភិបាលគួរពិចារណាមធ្យោបាយល្អបំផុតក្នុងការពង្រឹងសមត្ថភាព និងភាពជាដៃគូជាមួយវិស័យឯកជន។

សម្រាប់អនាគតៈ លើកកម្ពស់សមត្ថភាពរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងភាពជាដៃគូជាមួយវិស័យឯកជន ទីភ្នាក់ងារជាតិ មុខរបរ និងការងារ ត្រូវការកសាងសមត្ថភាព និងភាពជាដៃគូជាមួយវិស័យឯកជននៅក្នុងវិស័យ ៣សំខាន់ ទាក់ទងនឹងការទទួលខុសត្រូវសំខាន់ៗរបស់ខ្លួនដូចតទៅនេះ : (១) ការប្រមូល និងការវិភាគព័ត៌មានទីផ្សារការងារ (២) ការបង្កើតប្រព័ន្ធព័ត៌មានទីផ្សារការងារ និង (៣) ការផ្តល់ព័ត៌មានស្តីពីសេវាអប់រំ និងការងារ។ ទីមួយ ដោយគោរពទៅតាមការប្រមូលវិភាគ និងផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ ទីភ្នាក់ងារជាតិមុខរបរ និងការងារអាចទំនាក់ទំនងស្ថាប័នបណ្តុះបណ្តាលមូលដ្ឋាននៅក្នុងគំរូ និងការអង្កេតទីផ្សារការងារ ការបណ្តុះបណ្តាលមូលដ្ឋាន និងកម្រិតខ្ពស់ក្នុងការវិភាគទិន្នន័យ និងការបណ្តុះបណ្តាលរបៀបធ្វើបទបង្ហាញ ការទំនាក់ទំនង និងការផ្សព្វផ្សាយព័ត៌មាន។

ទីពីរ ដើម្បីកែសម្រួល និងពង្រឹងប្រព័ន្ធព័ត៌មានទីផ្សារការងាររបស់ខ្លួន ទីភ្នាក់ងារជាតិមុខរបរ និងការងារអាចស្វែងរកការសហការជាមួយសមាគមនិយោជក និងស្ថាប័នស្រាវជ្រាវវិស័យឯកជន។ ជាពិសេស ទីភ្នាក់ងារជាតិ មុខរបរ និងការងារអាចត្រួតពិនិត្យគំរូទីផ្សារដែលមាននៅកម្ពុជា ហើយអាចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងវិស័យឯកជនក្នុងការធ្វើបច្ចុប្បន្នភាព និងកែសម្រួលគំរូផ្គត់ផ្គង់ និងតម្រូវការក្នុងការប្រើប្រាស់។ ស្ថាប័នអន្តរជាតិ ដូចជា អង្គការពលកម្មអន្តរជាតិផ្តល់ជំនួយបច្ចេកទេសដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីសម្រេចបានគោលបំណងនេះតាមរយៈការប្រតិបត្តិល្អជាលក្ខណៈអន្តរជាតិ ទីភ្នាក់ងារជាតិមុខរបរ និងការងារអាចសហការ

ជាមួយសាលារៀន និងស្ថាប័នបណ្តុះបណ្តាល ដើម្បីអនុវត្តការអង្កេតតាមដានស្តីពីលទ្ធផលទីផ្សារការងាររបស់សិស្សនិសិត្សបញ្ចប់ការសិក្សា ដោយអាចចាប់ផ្តើមជាគម្រោងសាកល្បង ដែលមានសកលវិទ្យាល័យធំៗមួយ ឬពីរចូលរួម។

ដោយបន្ថែមលើវិធីសាស្ត្រដែលមានទាំងនេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារអាចធ្វើការអង្កេតតាមរយៈ ទូរស័ព្ទជាប្រចាំជាមួយនិយោជក ដែលបានផ្សព្វផ្សាយជ្រើសរើសបុគ្គលិកតាមតួនាទីក្នុងគោលបំណងកំណត់តួនាទីពិបាករក។ ចុងបញ្ចប់ ទីភ្នាក់ងារជាតិមុខរបរ និងការងារអាចចេញផ្សាយស្ថិតិសង្ខេបស្តីពីការងារប្រចាំឆ្នាំតាមមុខវិជ្ជា ការងារតាមមុខវិជ្ជា និងតាមស្ថាប័ន ដើម្បីឱ្យសិស្សនិស្សិតទើបប្រឡងជាប់អាចជ្រើសរើសស្ថាប័នសម្រាប់ទទួលការអប់រំ និងបណ្តុះបណ្តាល និងមុខវិជ្ជាដែលត្រូវរៀនបន្ត។ កិច្ចខិតខំផ្សព្វផ្សាយព័ត៌មានបែបនេះ សំដៅទៅលើក្រុមបីខុសៗគ្នា : គ្រឹះស្ថានអប់រំ និងស្ថាប័នបណ្តុះបណ្តាលបំណិន និយោជក អ្នកផ្តល់ការប្រឹក្សា និងសិស្សនិសិត្សដែលមានសក្តានុពល។

ចុងក្រោយនេះ ដើម្បីផ្តល់ព័ត៌មានស្តីពីសេវាអប់រំ និងការងារ ទីភ្នាក់ងារជាតិមុខរបរ និងការងារគួរពង្រឹង និងពង្រីកការផ្តល់ព័ត៌មានស្តីពីការអប់រំ និងឱកាសការងារ ដែលពេលបច្ចុប្បន្ននេះមិនទាន់មានភាពទូលំទូលាយនៅឡើយ។ កិច្ចខិតខំប្រឹងប្រែងនេះជាប់ទាក់ទងនឹងភាពជាដៃគូជាមួយស្ថាប័នផ្តល់សេវាការងារក្នុងវិស័យឯកជន ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលផងដែរដែលផ្តល់ព័ត៌មានទាំងនេះ។ គោលបំណងនៃការផ្សព្វផ្សាយនេះ គឺដើម្បីបង្កើតគេហទំព័រការងារតាមប្រព័ន្ធអេឡិចត្រូនិចដើម្បីឱ្យសិស្សនិស្សិត និងអ្នកផ្តល់ប្រឹក្សាប្រើប្រាស់នៅសាលាមធ្យមសិក្សាក៏ដូចជានិយោជកផងដែរ។ គេហទំព័រនេះ មានព័ត៌មានស្តីពីគ្រឹះស្ថានអប់រំឧត្តមសិក្សា វគ្គសិក្សានានា និងការងារដែលភ្ជាប់ទៅប្រព័ន្ធព័ត៌មានទីផ្សារការងាររបស់ទីភ្នាក់ងារជាតិ មុខរបរ និងការងារ។

## (២) ការពង្រីកវិសាលភាព "ភាពចន្លោះនៅកម្រិតកណ្តាល"

វេទិកាសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០១១ និងសិន្និសីទចក្ខុវិស័យកម្ពុជាមានអាទិភាពពង្រឹង "ភាពចន្លោះនៅកម្រិតកណ្តាល" នៃបំណិន។ ការសម្រេចឱ្យមានការចុះឈ្មោះនៅកម្រិតមធ្យមសិក្សាបឋមភូមិ រួមមានអត្រាចុះឈ្មោះទាបខ្លាំងក្នុងការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយមានការសហការជាមួយនិយោជក គឺត្រូវការជាចាំបាច់ដើម្បីរៀបចំចំនួនសិស្សជាច្រើនឱ្យទទួលបានការងារ និងបង្កើនជំនាញនាពេលអនាគត។

### ក) ***សកម្មភាពត្រូវអនុវត្តបន្ទាន់ក្នុងការពង្រីកវិសាលភាព "ភាពចន្លោះនៅកម្រិតកណ្តាល"***

ដោយសារសកម្មភាពនេះ ជាសកម្មភាពអាទិភាពបន្ទាន់ រដ្ឋាភិបាលគួរបញ្ជ្រាបកម្មវិធីអប់រំបណ្តុះ-បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យបានល្អ (ហើយពង្រីក ការផ្តល់ហិរញ្ញប្បទាន តម្រង់ទិសគ្រួសារដូចដែលបានលើកឡើងនៅក្នុងប្រសិទ្ធភាពហិរញ្ញប្បទាន)។

---

២២ ការផ្តួចផ្តើមនេះបានយកមកធ្វើការសាកល្បង និងវាយតម្លៃក្រោមគម្រោងទ្រទ្រង់វិស័យអប់រំនៅកម្ពុជា ឧបត្ថម្ភដោយធនាគារពិភពលោក ដើម្បីប្រមូល និងវិភាគបទពិសោធន៍មាតាបិតា និងសហគមន៍ និងជំរុញឱ្យមាតាបិតាមានការយកចិត្តទុកដាក់កាន់តែខ្លាំង និងតម្រូវឱ្យមានការកែលម្អពីសាលារៀន។

**សកម្មភាពទី ១ :** ការបញ្ជ្រាបកម្មវិធីអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈឱ្យបានល្អកម្ពុជាបានផ្ដល់កម្មវិធីអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈល្អមួយចំនួនរួចមកហើយ មានដូចជាវគ្គសិក្សាកុំព្យូទ័រនៅ CIST ដែលអាចធ្វើជាគំរូសម្រាប់ការបញ្ជ្រាប និងពង្រីកកម្មវិធីបាន។ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ អាចកំណត់កម្មវិធីបណ្ដុះបណ្ដាលជំនាញដែលមានការទទួលស្គាល់ច្រើនពីនិយោជក និងព្យាយាមដាក់បញ្ចូលកម្មវិធីបណ្ដុះបណ្ដាលនេះ នៅសាលាអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈរដ្ឋ ឬក្នុងស្ថាប័នបណ្ដុះបណ្ដាលធំៗ ដែលមានសិស្សចូលរៀនច្រើន។ ដោយមានការសហការជាមួយឧស្សាហកម្មឯកជន ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈអាចវិនិយោគលើមជ្ឈមណ្ឌលមួយ ឬច្រើន ដែលអនុវត្តបានល្អក្នុងតំបន់មួយចំនួនសម្រាប់ការអប់រំ បច្ចេកទេស និងវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សា។ សកម្មភាពវិនិយោគបែបនេះ អាចបង្កើនការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍជំនាញបច្ចេកទេស និងវិជ្ជាជីវៈបានល្អ ទៅតាមតម្រូវការរបស់សហគ្រាសឧស្សាហកម្ម។ សាលាវិជ្ជាជីវៈបច្ចេកទេសជាតិ (CONALEP) របស់ប្រទេសម៉ិកស៊ិកូ ផ្ដល់គំរូដ៏ជោគជ័យមួយ សម្រាប់ការណែនាំភាពជាដៃគូរវាងសាលា និងសហគ្រាសឧស្សាហកម្ម។

## ៩) ការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ "ភាពចន្លោះនៅកម្រិតកណ្ដាល" នៅថ្ងៃខាងមុខ

នៅថ្ងៃខាងមុខ រដ្ឋាភិបាលនឹងពិចារណាលើមធ្យោបាយថ្មី ដើម្បីពង្រឹងសមត្ថភាពរបស់គណៈ-កម្មាធិការជាតិ បណ្ដុះបណ្ដាល និងជំរុញឱ្យនិយោជកចំណាយលើការងារបណ្ដុះបណ្ដាលនិយោជិត។

**ផែនការទី១ :** ពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការជាតិបណ្ដុះបណ្ដាល ដើម្បីធ្វើកំណែទម្រង់ការអប់រំ និងការបណ្ដុះបណ្ដាល ផ្ដោតលើនិយោជក

ការពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការជាតិបណ្ដុះបណ្ដាល ត្រូវមានការរៀបចំសមាជិកភាពរបស់គណៈកម្មាធិការជាតិ បង្កើនតំណាង និងឥទ្ធិពលនិយោជក ព្រមទាំងអភិវឌ្ឍន៍សមត្ថភាពរបស់លេខាធិការរបស់គណៈកម្មាធិការជាតិបណ្ដុះបណ្ដាលផងដែរ។ ការពង្រឹងនេះ ក៏តម្រូវឱ្យគណៈកម្មាធិការជាតិបណ្ដុះបណ្ដាលដើរតួនាទីយ៉ាងសកម្មលើការងារជាក់ស្ដែង ក្នុងការបង្កើតស្តង់ដា គុណវុឌ្ឍិ និងការអនុវត្តការវាយតម្លៃបន្ថែមលើការលើកកម្ពស់ការបង្កើតគោលនយោបាយ និងប្រព័ន្ធគ្រប់គ្រងឱ្យកាន់តែទូលំទូលាយ។ ដើម្បីលើកកម្ពស់ការងាររបស់គណៈកម្មាធិការជាតិបណ្ដុះបណ្ដាល រដ្ឋាភិបាលអាចបង្ហាញពីសូចនាករការងារសំខាន់ដល់គណៈកម្មាធិការជាតិបណ្ដុះបណ្ដាល និងត្រួតពិនិត្យវឌ្ឍនភាពសមិទ្ធផលការងាររបស់ខ្លួន។ គណៈកម្មាធិការជាតិបណ្ដុះបណ្ដាលក្នុងប្រទេសជាច្រើនជុំវិញពិភពលោកមានឈ្មោះខុសៗគ្នា ចំណែកតួនាទី និងការទទួលខុសត្រូវក៏ខុសគ្នាដែរ។លេខាធិការដែលមានគោលជំហររឹងមាំគឺជាតួអង្គដ៏សំខាន់ក្នុងការផ្ដល់អំណាចដល់គណៈកម្មាធិការទាំងនេះឱ្យអនុវត្តតួនាទីដែលបានចាត់តាំង។ គណៈកម្មាធិការជាតិបណ្ដុះបណ្ដាលអាចផ្ដល់ឱ្យមានការរៀបចំរួមមួយ ដើម្បីត្រួតពិនិត្យស្ថាប័នទីផ្សារផ្សេងទៀតក្នុងការទទួលបានព័ត៌មានទីផ្សារការងារ សេវាការងារ ការធានាគុណភាព បទបញ្ជាការត្រួតពិនិត្យ និងការបង្កើតគោលនយោបាយ។

---

២៣ យុទ្ធសាស្ត្រគាំពារសង្គមជាតិកម្ពុជា ទទួលបានការអនុម័តពីសម្ដេចនាយករដ្ឋមន្ត្រី និងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីពេញអង្គ ក្នុងខែមីនា ឆ្នាំ២០១១។

**ផែនការទី២ :** ពិចារណាវិធីសាស្ត្រថ្មី ក្នុងការជំរុញនិយោជកឱ្យធ្វើការចំណាយលើការបណ្តុះបណ្តាលនិយោជិត

កម្ពុជាមិនមានការរំពឹងទុកក្នុងការផ្តល់ថវិកាសម្រាប់ការបណ្តុះបណ្តាល តាមតម្រូវការពីប្រភពសាធារណៈនោះទេ។ កម្ពុជាត្រូវការបែងចែកថវិកា និងលើកកម្ពស់ការចំណាយឯកជនតាមសហគ្រាស។ សហគ្រាសធំៗភាគច្រើន បានផ្តល់ការបណ្តុះបណ្តាលដល់និយោជិតរបស់ខ្លួនរួចរាល់ហើយ ហើយសហគ្រាសជាច្រើនទៀត ក៏មានការជំរុញឱ្យផ្តល់ការបណ្តុះបណ្តាលដល់និយោជិតផងដែរ។ ឧទាហរណ៍ ប្រទេសម៉ាឡេស៊ី និងសិង្ហបុរី ទទួលបានជោគជ័យក្នុងការជំរុញឱ្យសហគ្រាសផ្តល់ការបណ្តុះបណ្តាល តាមរយៈប្រព័ន្ធលើកលែងពន្ធលើប្រាក់ចំណូលរបស់និយោជក ដែលមានប្រសិទ្ធភាពសម្រាប់សហគ្រាសខ្នាតមធ្យម។ បទពិសោធន៍បង្ហាញថាប្រព័ន្ធលើកលែងពន្ធលើប្រាក់ចំណូលរបស់និយោជកអនុវត្ត ដោយមូលនិធិសម្រាប់ការបណ្តុះ-បណ្តាលថ្នាក់ជាតិ មានប្រសិទ្ធភាពដែលនិយោជកមានតួនាទីសំខាន់ក្នុងការគ្រប់គ្រង និងគោលនយោបាយរបស់ខ្លួន។ ផ្ទុយទៅវិញ ឥណទានពន្ធដារលើការអប់រំ និងការបណ្តុះបណ្តាលអាចមានប្រសិទ្ធភាពសម្រាប់ក្រុមហ៊ុនតូចៗ ដែលទទួលបានពីការលើកលែងពន្ធ ដោយសារការចំណាយទៅតាមលក្ខខណ្ឌច្បាប់។

## (៣) ការបង្កើនគុណភាព និងទំនាក់ទំនងទីផ្សារក្នុងការអភិវឌ្ឍបំណិន

ដើម្បីលើកកម្ពស់ទំនាក់ទំនង និងគុណភាពក្នុងការអភិវឌ្ឍបំណិន កម្ពុជាត្រូវធ្វើកំណែទម្រង់សាលារៀន និងមជ្ឈមណ្ឌលបណ្តុះបណ្តាល ព្រមទាំងការផ្សារភ្ជាប់ទៅនឹងឧស្សាហកម្មផងដែរ។ កំណែទម្រង់សាលាតម្រូវឱ្យ (១) កែប្រែកម្មវិធីសិក្សាឱ្យទៅជាកម្មវិធីសិក្សាផ្អែកលើការកសាងសមត្ថភាព និងផ្តោតការយកចិត្តទុកដាក់លើលទ្ធផលបណ្តុះបណ្តាលឱ្យបានច្រើនជាងធនធានសម្រាប់បង្កើនប្រសិទ្ធភាព និងការទទួលខុសត្រូវ (២) កែប្រែវិធីសាស្ត្រនៃការបង្រៀនពីគ្រូមជ្ឈមណ្ឌលទៅជាសិស្សមជ្ឈមណ្ឌល ដោយជួយសិស្ស និងកម្មសិក្សាការី ឱ្យក្លាយជាអ្នកបង្ហាត់បង្រៀនយូរអង្វែង (៣) ប្រើប្រាស់វិធីសាស្ត្រនៃការបង្រៀន ដែលអភិវឌ្ឍបំណិនជីវិត ដែលជាតម្រូវការរបស់ឧស្សាហកម្ម និងសហគ្រិន ដើម្បីអភិវឌ្ឍវិស័យឯកជន និងកាត់បន្ថយភាពក្រីក្រ និង (៤) ពង្រឹងការគ្រប់គ្រងសាលារៀន និងមជ្ឈមណ្ឌលបណ្តុះបណ្តាល ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងការឆ្លើយតបទៅនឹងការប្រែប្រួលទីផ្សារនៅតាមមូលដ្ឋាន។ ឧទាហរណ៍ ប្រទេសអូស្ត្រាលី និងសិង្ហបុរី មានបទពិសោធន៍យ៉ាងច្រើនទាក់ទងនឹងកំណែទម្រង់ទាំងនេះ។ ប្រទេសចិនក៏កំពុងសាកល្បងប្រើប្រាស់កញ្ចប់ថវិកាយ៉ាងច្រើនសម្រាប់កំណែទម្រង់ក្នុងសាលារៀន នៅតាមបណ្តោយឆ្នេរខាងកើត។ លើសពីនេះទៅទៀត មានប្រទេសជាច្រើនបានផ្តល់បទពិសោធន៍ល្អៗ ស្តីពីការផ្សារភ្ជាប់សាលារៀនជាមួយឧស្សាហកម្ម។ យុទ្ធសាស្ត្រទទួលបានជោគជ័យ រួមបញ្ចូលគំរូប្រទេសជប៉ុនជាមួយសាលារៀន ដែលដាក់បញ្ចូលសិស្សក្នុងវិស័យឧស្សាហកម្មនៅពេលបញ្ចប់ការសិក្សា ហើយគំរូប្រទេសសិង្ហបុរី ប្រើប្រាស់បញ្ហាផលិតកម្មឧស្សាហកម្មសម្រាប់ការបណ្តុះបណ្តាល។ គំរូសាលារៀន និងឧស្សាហកម្មរបស់ប្រទេសអាល្លឺម៉ង់វិញ មានកំណែទម្រង់ការបណ្តុះបណ្តាលពីរផ្នែក យុទ្ធសាស្ត្រប្រើប្រាស់ក្នុងសហរដ្ឋអាមេរិកជាមួយស្ថាប័នការងារ ដែលផ្តល់ការសិក្សាផ្អែកលើការងារភាពជាដៃគូរបស់សាលា CONALEP ជាមួយឧស្សាហកម្មសម្រាប់ម៉ូឌុលនៅប្រទេសម៉ិកស៊ិក្ស ការអប់រំនៅមធ្យមសិក្សាផ្អែកលើការកសាងសមត្ថភាព ឬ Senai និង Senac នៅប្រទេសប្រេស៊ីល មជ្ឈមណ្ឌលបណ្តុះបណ្តាលដឹកនាំដោយនិយោជក។

**ក) សកម្មភាពត្រូវអនុវត្តបន្ទាន់ ដើម្បីលើកកម្ពស់គុណភាព និងភាពពាក់ព័ន្ធនឹងទីផ្សារ**

នៅពេលមានការបន្តកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជននិងកីឡានិងក្រសួងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបង្កើតកំណែទម្រង់ឱ្យបានទូលំទូលាយ និងការកសាងសមត្ថភាពនោះ រដ្ឋាភិបាលអាចចាប់ផ្តើមបង្កើនចំនួនមជ្ឈមណ្ឌលបណ្តុះបណ្តាលក្រៅប្រព័ន្ធឱ្យបានឆាប់ ដោយមានសហការជាមួយឧស្សាហកម្មក្នុងស្រុក ។

**សកម្មភាពទី១ :** ចាប់ផ្តើមបង្កើនចំនួនស្ថាប័នបណ្តុះបណ្តាលក្រៅប្រព័ន្ធ ដោយការសហការជាមួយឧស្សាហកម្មក្នុងស្រុក

ការផ្តោតលើតំបន់អភិវឌ្ឍន៍ និងវិស័យលូតលាស់សំខាន់ៗខាងផ្នែកសេដ្ឋកិច្ច រដ្ឋាភិបាលអាចបង្កើតឱ្យមានដៃគូក្នុងតំបន់ រវាងឧស្សាហកម្ម និងស្ថាប័នបណ្តុះបណ្តាលបំណិន រួមមានមជ្ឈមណ្ឌលបណ្តុះបណ្តាលក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ព្រមទាំងសាលារៀនផងដែរ ។ ភាពជាដៃគូទាំងនេះ អាចចូលរួមចំណែកផ្តល់តួនាទីដល់ឧស្សាហកម្មក្នុងការគ្រប់គ្រងស្ថាប័នបណ្តុះ-បណ្តាល និងការគ្រប់គ្រងសេវាបណ្តុះបណ្តាលរបស់ខ្លួន ។ តាមសាលារៀន ក៏ដូចជាមជ្ឈមណ្ឌលបណ្តុះបណ្តាលហិរញ្ញប្បទានសាធារណៈ និងឯកជន អាចជួយកែលម្អការគ្រប់គ្រង ការបង្រៀន គ្រឿងបរិក្ខារ និងសម្ភារៈសិក្សា ។ បទពិសោធន៍ការងារ និងការបណ្តុះបណ្តាល អាចរួមបញ្ចូលគ្នា ដើម្បីលើកកម្ពស់គុណភាព និងភាពជាប់ទាក់ទងក្នុងការផ្តល់ការបណ្តុះបណ្តាល ។ ប្រទេសម៉ូរីស ទទួលបានជោគជ័យក្នុងការប្រើប្រាស់យុទ្ធសាស្ត្រនេះ ដើម្បីបម្រើដល់តំបន់សេដ្ឋកិច្ចសំខាន់ៗ ។ លើសពីនេះទៀត ការបង្កើត និងអនុវត្តយុទ្ធសាស្ត្របំណិនតាមតំបន់របស់រដ្ឋាភិបាលក្នុងតំបន់ ដោយមានការសហការជាមួយនិយោជក និងស្ថាប័នបណ្តុះបណ្តាលបំណិនក្នុងតំបន់ អាចផ្តល់អត្ថប្រយោជន៍តាមរយៈការស្នាក់នៅក្នុងសាលារៀន និងការទទួលបានការយល់ដឹងបច្ចេកទេស ដើម្បីឱ្យក្លាយជាកម្មករជំនាញ ។

**ខ) ការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការលើកកម្ពស់គុណភាព និងភាពពាក់ព័ន្ធនឹងទីផ្សារនៅថ្ងៃខាងមុខ**

នៅថ្ងៃខាងមុខ កម្ពុជានឹងត្រូវធ្វើកំណែទម្រង់កម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សា និងពង្រឹងការទទួលខុសត្រូវរបស់សហគមន៍ និងសាលារៀនផងដែរ ។

**ផែនការទី១ :** កំណែទម្រង់កម្មវិធីសិក្សាមធ្យមសិក្សា ដើម្បីលើកកម្ពស់ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ គណិតវិទ្យា វិស្វកម្ម និងមុខវិជ្ជាបច្ចេកទេសផ្សេងទៀត ភាពជាសហគ្រិន និងបំណិនជីវិត

តាមរយៈការត្រួតពិនិត្យលើយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ក្រសួងអប់រំខិតខំប្រឹងប្រែងជាថ្មី ដើម្បីកែសម្រួលកម្មវិធីសិក្សា ជាពិសេសការផ្តោតការយកចិត្តទុកដាក់លើមុខវិជ្ជាបច្ចេកទេសវិញនិងកែប្រែវិធីសាស្ត្របង្រៀនឱ្យកាន់តែទំនើបជាងមុន ។ការខិតខំប្រឹងប្រែងនេះផ្តោតការយកចិត្តទុកដាក់លើការបណ្តុះបណ្តាលគ្រូបង្រៀន ដែលអាចបំពេញបន្ថែមលើការលើកកម្ពស់កម្មវិធីបង្រៀនគណិតវិទ្យានៅថ្នាក់ដំបូងរបស់ក្រសួងអប់រំ យុវជន និងកីឡា នៅកម្រិតបឋមសិក្សា ។ នៅកម្រិតឧត្តមសិក្សា ក៏មានការពង្រឹងកម្មវិធីសិក្សា យ៉ាងហោចណាស់នៅគ្រឹះស្ថាន ឧត្តមសិក្សាមួយដែរខាងផ្នែកវិទ្យាសាស្ត្រ គណិតវិទ្យា វិស្វកម្ម និងបច្ចេកវិទ្យាព័ត៌មាន ដែលអាចសាកល្បង និងលើកយកយុទ្ធសាស្ត្រមកពិចារណាក្នុងការធ្វើកំណែទម្រង់

នៅឧត្តមសិក្សានាពេលខាងមុខ ។ បទពិសោធន៍ក្នុងការលើកកម្ពស់វិធីសាស្ត្របង្រៀនគណិតវិទ្យា និងវិទ្យាសាស្ត្រឱ្យកាន់តែប្រសើរឡើង ទទួលបានពីប្រទេសមួយចំនួន ដូចជា ហ្វាំងឡង់ និង សិង្ហបុរី ហើយថ្មីៗនេះពីទីក្រុងសៀងហៃនៅប្រទេសចិន ។

ករណីសិក្សាជាក់ស្តែង និងការងារគម្រោងអាចយកមកប្រើប្រាស់សម្រាប់ជាមូលដ្ឋានក្នុងការសាកល្បង ដើម្បីជាជំនួយក្នុងការអភិវឌ្ឍបំណិន សហគ្រិន ។ ផ្ទុយទៅវិញកម្មវិធីសិក្សាបែបនេះក៏អាចយកមកដាក់បញ្ចូលនៅថ្នាក់មធ្យមសិក្សា និងឧត្តមសិក្សា ប៉ុន្តែតាមរយៈបទពិសោធន៍អន្តរជាតិ កម្មវិធីសិក្សានេះជាប់ទាក់ទងយ៉ាងខ្លាំងពេលដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៅស្ថាប័នបណ្តុះបណ្តាលក្រៅប្រព័ន្ធ ដែលឱ្យមនុស្សពេញវ័យសព្វថ្ងៃកំពុងមានការងារធ្វើ និងធ្វើការឱ្យអ្នកផ្សេងសម្រេចបំណងក្នុងការបើកជំនួញដោយខ្លួនឯងនោះ ។ កម្មវិធីទាំងនេះអាចផ្តល់ជាវិធីសាស្ត្រដ៏មានសារៈប្រយោជន៍ដល់អ្នក ដែលចង់ក្លាយជាសហគ្រិនក្នុងការលើកកម្ពស់លទ្ធផលធ្វើជំនួញ ។ទាក់ទងនឹងបំណិនជីវិតកម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាអាចសាកល្បងបង្រៀនមេរៀនស្តីពីបំណិនជីវិតតូចៗផ្សេងទៀត ហើយក៏គួរមានការត្រួតពិនិត្យ និងវាយតម្លៃលើការសាកល្បងនេះ មុនពេលយកមកដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សានោះ ។

**ផែនការទី២ :** ពង្រឹងការទទួលខុសត្រូវរបស់សហគមន៍ និងសាលារៀន ដែលជាផ្នែកមួយនៃដំណើរវិមជ្ឈការ និងវិសហមជ្ឈការ

ដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ ដែលកំពុងតែបន្តអនុវត្តនៅកម្ពុជានោះ ផ្តល់ឱកាសក្នុងការលើកកម្ពស់ឯករាជ្យភាព និងការទទួលខុសត្រូវរាល់លទ្ធផលនៃការអប់រំនៅកម្រិតមូលដ្ឋាន ។ ក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការ និងកំណែទម្រង់រដ្ឋបាលថ្នាក់ជាតិ ក្រសួងអប់រំ យុវជន និងកីឡា អាចសហការជាមួយក្រសួងផ្សេងទៀតក្នុងការកំណត់ពីតួនាទី និងមុខងារសម្រាប់ការគ្រប់គ្រងថ្នាក់ក្រោមជាតិ ។ ផ្នែកជាច្រើនដូចជា ការត្រួតពិនិត្យ ការវាយតម្លៃ ការគ្រប់គ្រងការងារ ការបែងចែកមុខងារឱ្យបានសមរម្យនៅថ្នាក់គ្រប់គ្រងផ្សេងៗ ទាក់ទងនឹងការអប់រំ សុខាភិបាល និងវិស័យសង្គមផ្សេងទៀត អាចជួយសម្រួលឱ្យការគ្រប់គ្រងមានលទ្ធផលកាន់តែប្រសើរឡើងក្នុងបរិបទវិមជ្ឈការ ។ យុទ្ធសាស្ត្ររួមនៅគ្រប់វិស័យ អាចជួយសម្រួលដល់ការកសាងសមត្ថភាព ដែលចាំបាច់សម្រាប់មន្ត្រីគ្រប់គ្រងថ្នាក់ក្រោមជាតិ និងបុគ្គលិកសិក្សា ។ ពិសេសជាងនេះទៀត គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសាលា រួមបញ្ចូលទាំងគំនិតផ្តួចផ្តើមការសាកល្បងផងនោះ ដូចជា គំនិតផ្តួចផ្តើមបង្កើតប័ណ្ណរបាយការណ៍សាលារៀនអាចជំរុញឱ្យសហគមន៍ និងក្រុមប្រឹក្សាឃុំ ចូលរួមក្នុងការត្រួតពិនិត្យការងារសាលា និងបង្កើតផែនការសកម្មភាព ដើម្បីលើកកម្ពស់ការគ្រប់គ្រងការបង្រៀនរបស់គ្រូ ។

## (៤) ការពង្រឹងប្រសិទ្ធភាពហិរញ្ញប្បទានក្នុងការអភិវឌ្ឍបំណិន

មានបញ្ហាពីរកើតឡើងនៅពេលបែងចែកការចំណាយទៅលើការអភិវឌ្ឍបំណិន ។បញ្ហាទីមួយ គឺស្តីពីរបៀបកៀរគរធនធានក្នុងវិស័យសាធារណៈ និងឯកជននៅដំណាក់កាលនីមួយៗនៃវដ្តជីវិត ហើយទីពីរ គឺស្តីពីរបៀបចំណាយធនធាន ដែលអាចបង្កើតឱ្យមានប្រាក់លើកទឹកចិត្តសម្រាប់ការបំពេញការងារបានល្អ និងគណនេយ្យភាពសម្រាប់លទ្ធផលការងារ ។ បញ្ហាទាំងនេះ ក៏កើតមាននៅក្នុងវិស័យឯកជនផ្សេងទៀតផងដែរ ហើយមិនត្រឹមតែការអភិវឌ្ឍបំណិនប៉ុណ្ណោះទេ ការឆ្លើយតបក៏តម្រូវឱ្យមានការផ្សារភ្ជាប់ជាមួយទៅនឹងគោលការណ៍ហិរញ្ញប្បទានសាធារណៈឱ្យបានល្អផងដែរ ដូចជាអ្នកដែលទទួលបានប្រយោជន៍ច្រើន

ជាងគេគួរទទួលខុសត្រូវលើការចំណាយ ។ ជាពិសេស ក្នុងការអភិវឌ្ឍបំណិនទាក់ទងនឹងការងារដែលគ្រួសារ និងអ្នកធ្វើជំនួញអាចដឹងដោយផ្ទាល់ពីប្រយោជន៍នៃការអភិវឌ្ឍបំណិន និងចែករំលែកបន្ទុកហិរញ្ញវត្ថុ ។

**ក) សកម្មភាពត្រូវអនុវត្តបន្ទាន់ក្នុងការពង្រឹងប្រសិទ្ធភាពហិរញ្ញប្បទាន ដើម្បីការអភិវឌ្ឍបំណិន**

ដោយសារសកម្មភាពនេះជាសកម្មភាពអាទិភាពបន្ទាន់ រដ្ឋាភិបាលគួរបង្កើនការចំណាយលើវិធីសាស្ត្របែងចែកថវិកា តម្រង់ទិសគ្រួសារឱ្យមានប្រសិទ្ធភាព ដើម្បីរក្សាអត្រាសិក្សាគង់វង្ស ។

**សកម្មភាពទី១ :** ពង្រីកវិធីសាស្ត្រផ្តល់ហិរញ្ញប្បទានតម្រង់ទិសគ្រួសារ ដើម្បីអត្រាគង់វង្សនៃការសិក្សា

បទពិសោធន៍ដ៏ល្អរបស់កម្ពុជាក្នុងការអនុវត្តកម្មវិធីអាហារូបករណ៍ ដើម្បីបង្កើនការចុះឈ្មោះចូលរៀននៅមធ្យមសិក្សាផ្តល់នូវមេរៀនមានសារៈសំខាន់បន្ថែមទៀត ។បទពិសោធន៍ទាំងនេះបង្ហាញថា កម្មវិធីជំនួយហិរញ្ញវត្ថុ ជាកម្មវិធីមានប្រសិទ្ធភាព ដែលអាចឱ្យកុមារនៅបន្តការសិក្សាទៀតបាន ។ កម្មវិធីស្រដៀងគ្នានេះអាចយកមកពិចារណាសម្រាប់ការអប់រំ បណ្តុះ-បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយមានការសហការជាមួយវិស័យឯកជនផ្សេងទៀតផងដែរ ។ បទពិសោធន៍នៅប្រទេសមួយចំនួន ដូចជា អាមេរិកឡាទីន ឥណ្ឌូនេស៊ី និងបង់ក្លាដេសបានបង្ហាញពីភាពជោគជ័យនៃកម្មវិធីទាំងនេះ ក្នុងការជំរុញឱ្យមានអត្រាសិក្សាគង់វង្ស និងបញ្ចប់កម្មវិធីសិក្សា ។

**ខ) ការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ប្រសិទ្ធភាពហិរញ្ញប្បទាននៅពេលអនាគត**

នៅថ្ងៃខាងមុខ រដ្ឋាភិបាលត្រូវបង្កើនការចំណាយលើការអន្តរាគមដែលចំណាយតិចក្នុងដំណាក់កាលដំបូងនៃជីវិតរបស់កុមារតូច និងរកវិធីសាស្ត្របែងចែកថវិកាផ្សេងៗ ដើម្បីបង្កើនប្រាក់លើកទឹកចិត្តចំពោះលទ្ធផលការងារល្អក្នុងចំណោមស្ថាប័នបណ្តុះបណ្តាលជំនាញ រួមទាំងគ្រឹះស្ថានឧត្តមសិក្សាផងដែរ ។

**ផែនការទី១ :** បង្កើនការចំណាយលើបទអន្តរាគមន៍ដែលមានការចំណាយតិចតួចនៅដំណាក់កាលដំបូងនៃវដ្តជីវិត

ដោយការបន្តនិន្នាការនៃការបង្កើនចំណាយសាធារណៈលើការអប់រំ ដែលជាចំណែកមួយនៃផលិតផលក្នុងស្រុកសរុប កម្ពុជាត្រូវប្រើប្រាស់ធនធានដែលមានស្រាប់ ដើម្បីកែលម្អលើការរៀបចំឱ្យកុមារឱ្យទទួលបានបំណិនសម្រាប់ធ្វើការងារ និងទទួលបានជំនាញសម្រាប់ការងារដំបូងហើយក៏នឹងតម្រូវឱ្យមានថវិកាបន្ថែមផងដែរ ឧទាហរណ៍ ដើម្បីទទួលបានសូចនាករនៃការវិវត្តសំខាន់របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានគោលបំណង (១) ពង្រីកវិសាលភាពនៃការអប់រំដោយចាប់ផ្តើមកម្មវិធីអប់រំកុមារតូច និងការបញ្ចប់ថ្នាក់នៅកម្រិតបឋមសិក្សាលើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ រួមមាន ការកាត់បន្ថយអត្រាត្រួតថ្នាក់ក្នុងសាលា និងការបង្កើនការវាយតម្លៃស្តង់ដាថ្នាក់ជាតិលើលទ្ធផលសិក្សារបស់សិស្ស ។ គោលដៅចម្បងពីរខាងលើនេះ នឹងគាំទ្រដល់ការបណ្តុះបណ្តាលគ្រូបង្រៀន និងប្រព័ន្ធវាយតម្លៃថ្នាក់ជាតិក៏ដូចជាសមត្ថភាពរបស់គ្រួសារក្រីក្រក្នុងការឱ្យកូនរបស់ពួកគេចូលរៀនផងដែរ ។

ក្នុងន័យនេះ ការបែងចែកហិរញ្ញវត្ថុរបស់រដ្ឋាភិបាល គួរផ្តោតលើសារៈសំខាន់នៃការអប់រំកុមារតូចសម្រាប់ការអភិវឌ្ឍមូលធនមនុស្ស ដើម្បីទទួលបានសង្គមមានអ្នកចេះដឹង និងសេដ្ឋកិច្ច

រីកចម្រើន និងបង្កើនជំនួយក្នុងការវិនិយោគឱ្យមានប្រសិទ្ធភាពចំណាយលើកុមារតូច។ បទ-ពិសោធន៍អន្តរជាតិបានបង្ហាញថា ការធ្វើបែបនេះអាចមានប្រសិទ្ធភាពតាមរយៈកម្មវិធីផ្តោតលើការគាំពារសង្គម ដូចជា ការផ្ទេរសាច់ប្រាក់ដោយមានការទទួលខុសត្រូវទៅវិញទៅមកលើការអភិវឌ្ឍកុមារក្រោមយុទ្ធសាស្ត្រគាំពារសង្គមជាតិកម្ពុជា។ ការផ្ទេរសាច់ប្រាក់ទាំងនេះអាចធ្វើទៅបានអាស្រ័យលើការចូលរួមក្នុងអន្តរាគមន៍នៃប្រសិទ្ធភាពចំណាយ រួមមាន អាហាររូបត្ថម្ភ សុខភាព មាតា និងទារក ព្រមទាំងការអប់រំមាតាបិតា និងកុមារតូច ហើយដូចគ្នានេះដែរ គ្រួសារក៏ទទួលបានកម្មវិធីអាហារូបករណ៍ក្រោមលក្ខខណ្ឌឱ្យកូនបន្តការសិក្សានៅសាលាផងដែរ។

**ផែនការទី២ :** ស្វែងរកវិធីសាស្ត្របែងចែកហិរញ្ញប្បទាននានាដើម្បីជំរុញឱ្យមានការលើកទឹកចិត្តចំពោះ

ស្ថាប័នដែលមានលទ្ធផលបណ្តុះបណ្តាលល្អ ក្នុងចំណោមស្ថាប័នបណ្តុះបណ្តាលបំណិន រួមទាំងគ្រឹះស្ថានឧត្តមសិក្សា។ កំណែទម្រង់ដែលមានជោគជ័យនៅថ្នាក់អន្តរជាតិមានគោលដៅ (១) ការបែងចែកថវិកាតាមការងារ (២) ការប្រើប្រាស់មូលនិធិសម្រាប់អភិវឌ្ឍន៍បំណិន ដែលមានការប្រកួតប្រជែង និង (៣) ការផ្តល់អំណាចដល់អ្នកទទួលផលតាមរយៈការប្រើប្រាស់សក្ខីប័ត្រ និងព្រឹត្តបត្រសិក្សាសម្រាប់ការអភិវឌ្ឍបំណិន ដែលចំណាយពេលវេលាច្រើន។ តាមរយៈភ្នាក់ងារជំនាញជាតិ SENCE ប្រទេសឈីលី បានជំរុញឱ្យមានសេវាប្រសើរជាងមុនពីស្ថាប័នបណ្តុះបណ្តាលបំណិនសាធារណៈ និងឯកជនតាមរយៈការទទួលបានសេវាទាំងនេះ ដោយមានការប្រកួតប្រជែង។ ប្រទេសអូស្ត្រាលី កំពុងចាត់វិធានក្នុងការបង្កើនការប្រកួតប្រជែង និងធានាឱ្យមានវគ្គបណ្តុះបណ្តាលពាក់ព័ន្ធ ដោយប្រើប្រាស់សក្ខីប័ត្រជាក់លាក់។

យុទ្ធសាស្ត្រផ្តល់ហិរញ្ញប្បទានតាមតម្រូវការ បានផ្លាស់ប្តូរក្របខ័ណ្ឌការផ្តល់ប្រាក់លើកទឹកចិត្តដល់ការងារ ដោយការផ្តល់អំណាចដល់អ្នកទទួលផលនៃការអភិវឌ្ឍបំណិន។ សម្រាប់វិស័យសាធារណៈ វិធីសាស្ត្រទាំងនេះជំរុញឱ្យមានការផ្តោតលើលទ្ធផលនៃការបណ្តុះបណ្តាល ដើម្បីកែសម្រួលការចំណាយលើវិស័យសាធារណៈ។ ដោយសារថា កម្ពុជាបានអនុវត្តកន្លងមកក្នុងកម្មវិធីសក្ខីប័ត្រក្រោមគម្រោង ADB TVET ឬកម្មវិធីអាហារូបករណ៍ ទើបមានការបង្កើត និងធ្វើតេស្តលើកម្មវិធីសាកល្បងក្នុងរយៈពេលមួយខ្លី ដោយមានការត្រួតពិនិត្យ និងវាយតម្លៃយ៉ាងហ្មត់ចត់លើប្រសិទ្ធភាពនៃកម្មវិធីទាំងនេះ ដើម្បីសម្រេចបានការបង្កើតគោលនយោបាយនាពេលខាងមុខ។

យន្តការហិរញ្ញប្បទានសម្រាប់ការអប់រំឧត្តមសិក្សា តម្រូវឱ្យមានការពង្រឹងប្រសិទ្ធភាព និងតម្លាភាព។ ដោយហេតុថាការកើនឡើងយ៉ាងឆាប់រហ័សនៃការអប់រំកម្រិតឧត្តមសិក្សា និងជំនួយហិរញ្ញវត្ថុសាធារណៈតិចតួចនៅតាមគ្រឹះស្ថានឧត្តមសិក្សា ថវិកាប្រមូលបានពីគ្រឹះស្ថានសាធារណៈ និងឯកជន អាចគាំទ្រឱ្យមាននិរន្តរភាពហិរញ្ញប្បទានយូរអង្វែង។ ក្រសួងអប់រំ យុវជននិងកីឡានឹងត្រូវវាយតម្លៃពីការប្រើប្រាស់ធនធានសម្រាប់ការអប់រំឧត្តមសិក្សានិងការកែប្រែអាចធ្វើបានតាមរយៈយន្តការហិរញ្ញប្បទានដែលមានស្រាប់ក្នុងគ្រឹះស្ថានឧត្តមសិក្សា។

## ៣.២ ការអនុវត្តផែនការសកម្មភាព និងការពិចារណាលើយុទ្ធសាស្ត្រឱ្យបានទូលំទូលាយ

បទពិសោធន៍ទទួលបានពីប្រទេសកម្ពុជា និងប្រទេសផ្សេងទៀតបង្ហាញថា ផែនការសកម្មភាពគួរមានរយៈពេលកំណត់រួម និងទស្សនៈត្រឹមត្រូវ ការត្រួតពិនិត្យនិងបង្ហាញពីលទ្ធផល។ សូចនាករការងារសំខាន់ៗ

គួរយកមកកំណត់ ដើម្បីធ្វើការត្រួតពិនិត្យ ។ សូចនាករទាំងនេះ គួរបញ្ចូលចំណុចដៅសម្រាប់ត្រួតពិនិត្យ និងសូចនាករនៃផលប៉ះពាល់ចុងក្រោយតាមការវាយតម្លៃយ៉ាងហ្មត់ចត់ ។ ការបែងចែកការទទួលខុសត្រូវច្បាស់លាស់ក្នុងការអនុវត្ត និងការត្រួតពិនិត្យហ្មត់ចត់ នឹងមានសារប្រយោជន៍ដល់ការអនុវត្តសកម្មភាពតាមពេលវេលាកំណត់ ។ សកម្មភាពគ្រោងខាងលើផ្តល់ឱ្យមានជម្រើសជាក់លាក់ ដែលអាចធ្វើជាធនធានសម្រាប់កិច្ចពិភាក្សារវាងរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងទៀតក្នុងការបង្កើតផែនការសកម្មភាព ។

ដើម្បីសម្រួលដល់ការពិភាក្សា និងការអនុវត្ត រដ្ឋាភិបាលគួរបង្កើត "សហគមន៍បំណិន" មួយ ។ សហគមន៍អាចបញ្ចូលមន្ត្រីថ្នាក់កណ្តាលក្នុងក្រសួង និងវិស័យឯកជន ព្រមទាំងទីភ្នាក់ងាររដ្ឋាភិបាលផងដែរ ។ បទ-ពិសោធន៍អន្តរជាតិបានបង្ហាញឱ្យដឹងថា សហគមន៍បែបនេះ អាចមានប្រសិទ្ធភាពក្នុងការលើកកម្ពស់កិច្ចពិភាក្សាគោលនយោបាយ និងអាចធ្វើជាតំណាងក្នុងការធ្វើកំណែទម្រង់នៅពេលអនុវត្ត ។ សហគមន៍ទាំងនេះ មានគោលដៅបង្កើតឡើងទៅតាមពេលវេលាកំណត់ណាមួយ ដើម្បីបំពេញតាមតម្រូវការក្នុងពេលជាក់លាក់ ចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងចែករំលែកការយល់ដឹង និងផ្សព្វផ្សាយសំណើកំណែទម្រង់ក្នុងវិស័យដែលពួកគេយកចិត្តទុកដាក់ ។

ចុងក្រោយនេះ ដោយមានការពិចារណាលើរបៀបវារៈនៃការអភិវឌ្ឍបំណិនសម្រាប់រយៈពេលមធ្យម កម្ពុជាអាចអនុម័តយុទ្ធសាស្ត្ររួមដូចបានលើកឡើងនៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍បំណិនវដ្តជីវិត (រូបភាពទី ១១) ។ ក្របខ័ណ្ឌខាងទស្សនៈសាមញ្ញមួយឈ្មោះថា បំណិនដើម្បីទទួលបានការងារ និងផលិតភាព (STEP) អាចជួយអ្នករៀបចំគោលនយោបាយបង្កើតប្រព័ន្ធ ដែលផ្តល់បំណិននាំទៅរកផលិតភាពខ្ពស់ និងការរីកចម្រើនខ្លាំង ។ ស្របពេលកម្ពុជាទំនងជាទទួលបានលទ្ធផលខ្ពស់បំផុត ដោយការផ្តោតលើជំហានទាំងបីដំបូងខាងលើ នោះការបណ្តុះបណ្តាលភាពជាសហគ្រិន (ក្រោមជំហានទី ៤) និងការសម្របសម្រួលឱ្យទទួលបានព័ត៌មាន (ក្រោមជំហានទី ៥) ដែលបានពិភាក្សាខាងលើ ចាំបាច់ត្រូវកែប្រែជំនាញទៅជាផលិតភាពការងារឱ្យមានប្រសិទ្ធភាពវិញ ។ យុទ្ធសាស្ត្ររួម គួរផ្អែកលើការវិភាគ ដោយហ្មត់ចត់ពីមូលហេតុនៃការខ្វះខាត និងភាពមិនសមស្របនៃបំណិន និងផ្អែកលើការវាយតម្លៃពីប្រសិទ្ធភាពនៃគោលនយោបាយ និងសកម្មភាពដែលបានអនុវត្តកន្លងមក ។

រូបភាព ១២ : ប្រព័ន្ធគាំទ្រដល់ការអភិវឌ្ឍបំណិនក្នុងវដ្តជីវិត




**ប្រភព :** ធនាគារពិភពលោក (២០១០ ឃ)

# ឯកសារយោង

កំណត់សម្គាល់នេះ រៀបចំឡើងបន្ទាប់ពីរបាយការណ៍របស់ធនាគារពិភពលោកឆ្នាំ២០១០ ស្តីពីការផ្តល់បំណិនសម្រាប់សមធម៌និងភាពរីកចម្រើន និងបន្ថែមពីលើកំណត់សម្គាល់ ឆ្នាំ២០១០ របស់ធនាគារពិភពលោកស្តីពីការអនុវត្តយុទ្ធសាស្ត្រកំណើនរបស់ប្រទេសកម្ពុជាក្រោយពេលមានវិបត្តិ។ កំណត់សម្គាល់នេះ ផ្អែកលើកិច្ចពិភាក្សាក្នុងបេសកកម្មគាំពារសង្គមរបស់ធនាគារពិភពលោកកាលពីខែវិច្ឆិកា ឆ្នាំ២០១០និងផ្អែកលើការជជែកពិភាក្សាគោលនយោបាយនៅវេទិកាសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០១១។កំណត់សម្គាល់នេះមានគោលបំណងគាំទ្ររដ្ឋាភិបាលក្នុងការកំណត់សកម្មភាព ដើម្បីដោះស្រាយឧបសគ្គជាកាតព្វកិច្ច និងការព្រាងយុទ្ធសាស្ត្របំណិនរបស់ប្រទេសកម្ពុជាសម្រាប់ពេលអនាគត។ សូមធ្វើការណែនាំដោយសួរជាសំនួរ និងផ្តល់យោបល់ទៅ Hana Brixi ដែលជាប្រធានក្រុមសម្រាប់កម្មវិធីគាំពារសង្គមរបស់ធនាគារពិភពលោកក្នុងប្រទេសកម្ពុជា (hbrixi@worldbank.org)។

សម្រាប់ការពិភាក្សា សូមមើលឯកសាររបស់ធនាគារពិភពលោក (ឆ្នាំ២០១០)

យុទ្ធសាស្ត្រចតុកោណរបស់ប្រទេសកម្ពុជា ដើម្បីភាពរីកចម្រើនការងារ សមធម៌ និងប្រសិទ្ធភាព ផ្តោតលើវិស័យមួយចំនួន ដូចជា: កសិកម្ម ប្រព័ន្ធទឹក និងធារាសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ អគ្គិសនី ការអភិវឌ្ឍធនធានមនុស្ស ឧស្សាហកម្មអតិពលកម្ម និងឧស្សាហកម្មផលិតអាហារសម្រាប់នាំចេញ ទេសចរណ៍ ប្រេង ឧស្ម័ន ធម្មជាតិ និងរ៉ែផ្សេងៗទៀត បច្ចេកវិទ្យាព័ត៌មាន/គមនាគមន៍ និងជំនួញ។

រដ្ឋាភិបាលបានកំណត់វិស័យអាទិភាពចំនួន ១៩ ដែលចាត់ទុកជាផ្នែកនៃយុទ្ធសាស្ត្រសមាហរណកម្មជំនួញរបស់ខ្លួនៈ ស្រាបៀរ គ្រាប់ស្វាយចន្ទី ដំឡូងឈើ ពោត ជលផល ស្បែកជើង កាត់ដេរ ការចិញ្ចឹមសត្វ អង្ករ កៅស៊ូ សូត្រ សណ្តែកសៀង ផ្លែឈើ និងបន្លែ ផលិតផលឈើ សមាគមបាត្តកម្មធុនស្រាល ទេសចរណ៍ សេវាពលកម្ម (រួមទាំងការសាងសង់) សេវាទាក់ទងនឹងការដឹកជញ្ជូន ដំណើរការអាជីវកម្ម/សេវាតាមប្រព័ន្ធអ៊ីនធើណេត។

បញ្ហាប្រឈមផ្នែកសម្របសម្រួល និងព័ត៌មាន ស្ថិតក្នុងឧបសគ្គបីសំខាន់ៗ ទន្ទឹមនឹងបញ្ហាប្រឈមនៃធនបម្រុង និងតម្លៃអគ្គិសនី និងភស្តុភារដែលរារាំងភាពរីកចម្រើនរបស់ប្រទេសកម្ពុជា (ធនាគារពិភពលោក ឆ្នាំ២០១០ A)។ បញ្ហាប្រឈមផ្នែកធនបម្រុងសំដៅលើប្រព័ន្ធអន់ខ្សោយរបស់ប្រទេសកម្ពុជាក្នុងការដោះស្រាយជម្លោះ និងការប្រឆាំងអំពើពុករលួយ។ តម្លៃអគ្គិសនីខ្ពស់ និងថ្លៃដើម និងភស្តុភារដែលមិនអាចទុកចិត្តបាន (រួមទាំងជំនួញ) រារាំងសហគ្រិនពីការចូលរួមក្នុងគម្រោង ដែលអាចដំណើរការបាន។

វិសមភាពប្រាក់ចំណូលក្នុងប្រទេសកម្ពុជាមានកម្រិតខ្ពស់ទៅតាមស្តង់ដាតំបន់ ដោយមានមេគុណ Gini ឈានដល់ ៤៥%។ សម្រាប់ទិន្នន័យ សូមមើលទិន្នន័យមូលដ្ឋានតាមដានភាពក្រីក្រនៅតំបន់អាស៊ីបូព៌ា។

ស្រដៀងនឹងទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិផងដែរ (ឆ្នាំ២០១០) ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (ឆ្នាំ២០១១) បង្ហាញពីការធ្លាក់ចុះនៃអត្រាផ្តល់កំណើតសរុបពី ៤.០ ក្នុងឆ្នាំ២០០០ ដល់ ៣.០ ក្នុងឆ្នាំ២០១០។

សម្រាប់ការវិភាគ សូមមើល Di Gropello និង Sakellariou (ឆ្នាំ២០១០)។ ប្រទេសដែលបានធ្វើការអង្កេត រួមមាន ប្រទេសកម្ពុជា ចិន ឥណ្ឌូនេស៊ី ម៉ុងហ្គោលី ហ្វីលីពីន ថៃ និងវៀតណាម។ ការសិក្សាកំណត់និយោជិតដែលមានជំនាញថាជានិយោជិតដែលមានការអប់រំមធ្យមសិក្សាទុតិយភូមិ និងការអប់រំខ្ពស់ជាងនេះ។

ធនាគារពិភពលោកឆ្នាំ២០១០ ខ និង HRINC ឆ្នាំ២០១១។ ការអង្កេតដោយប្រុងប្រយ័ត្នស្តីពីនិយោជក និងនិយោជិត ចាំបាច់ត្រូវផ្តល់ភស្តុតាងដែលអាចទុកចិត្តបានទាក់ទងនឹងវិសាលភាព និងប្រភេទជាក់លាក់នៃការខ្វះខាត និងភាពមិនសមស្របនៃបំណិន។

នាពេលថ្មីៗនេះ មជ្ឈមណ្ឌលអភិវឌ្ឍន៍បំណិនកម្ពុជា បានកំណត់ពីអាទិភាពលើការបណ្តុះបណ្តាលរបស់និយោជកយ៉ាងល្អិតល្អន់ថាជាផ្នែកនៃការសិក្សាមួយ ដែលត្រូវរក្សាការសម្ងាត់ដោយលើកឡើងពីចំណុចសំខាន់ៗនៃបំណិនទំនាក់ទំនងរវាងបុគ្គល បំណិនធនធានមនុស្ស និងទំនាក់ទំនងវិជ្ជាជីវៈ បំណិនផ្នែកលក់ និងទីផ្សារ បំណិនធុរកិច្ច និងគិតលេខ និងបំណិនគ្រប់គ្រងហិរញ្ញវត្ថុ។

ឧទាហរណ៍ សូមមើលការលើកឡើងរបស់ Heckman, Stixrud និង Urzua (ឆ្នាំ២០០៥)។ ជាទូទៅ ការអភិវឌ្ឍកុមារតូចចាប់ផ្តើមពីពេលដែលកុមារមានអាយុចាប់ពីប្រាំមួយដល់ប្រាំបីឆ្នាំ។

សម្រាប់ទិន្នន័យរបស់ប្រទេសជាច្រើនទៀត សូមមើលសូចនាករអភិវឌ្ឍន៍ពិភពលោក (ឆ្នាំ២០១០)។

អាយុចូលរៀនផ្លូវការរបស់ប្រទេសកម្ពុជានៅកម្រិតបឋមសិក្សា គឺស្របទៅតាមការអនុវត្តរបស់អន្តរជាតិ

EMIS ឆ្នាំ២០០៩

ឧទាហរណ៍ សូមមើល Bishop និង Mane (ឆ្នាំ២០០៥) និង OECD (ឆ្នាំ២០១០)

លទ្ធផលអង្កេតបានមកពី CSES ឆ្នាំ ២០០៩ និង HRINC ឆ្នាំ ២០១១

សម្រាប់ព័ត៌មានលម្អិត សូមអាន CAMFEBA (ឆ្នាំ ២០០៨)

សម្រាប់ឧទាហរណ៍ និងការវិភាគនានា សូមអានកំណត់ត្រាការងារយុវជនរបស់ធនាគារពិភពលោក
តាមរយៈគេហទំព័រ www.youth-employment-inventory.org/

កំណត់ត្រាការងារយុវជនរបស់ធនាគារពិភពលោក មាននៅគេហទំព័រ www.youth-employment-inventory.org/

ការយល់ដឹងពីមូលហេតុនៃការខ្វះខាត និងភាពមិនសមស្របនៃបំណិន ទាមទារឱ្យមានការពិនិត្យមើលទីផ្សារដែលមានសក្តានុពល និងការបរាជ័យនៃអភិបាលកិច្ចដែលបង្វៀងតម្រូវការ និងការផ្តល់បំណិនពី "កម្រិតល្អបំផុតនៃសង្គម" និងប៉ះពាល់ដល់ភាពសមស្របរវាងតម្រូវការបំណិន និងការផ្តល់បំណិនក្នុងទីផ្សារការងារ។ ការបរាជ័យមួយចំនួន ជាប់ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំ និងការបណ្តុះបណ្តាល ហើយមួយចំនួនទៀតទាក់ទងនឹងឧបសគ្គដែលបុគ្គលម្នាក់ៗ ជួបប្រទះក្នុងការទទួលបានព័ត៌មាន និងប្រាក់កម្ចី ហើយមួយចំនួនទៀត ជាធម្មតាឆ្លុះបញ្ចាំងពីភាពខ្សោយនៃចំណេះដឹងក្នុងគ្រួសារ។ លក្ខណៈសម្បត្តិជាក់លាក់នៃទីផ្សារផលិតផល និងការងារ ក៏អាចជះឥទ្ធិពលដល់សហគ្រាសក្នុងការផ្តល់ប្រាក់លើកទឹកចិត្តសម្រាប់និយោជិតតាមជំនាញជាក់លាក់ ឬនិយោជិតដែលមានការបណ្តុះបណ្តាល និងនិយោជិតឱ្យមានជំនាញកាន់តែខ្ពស់។

សមាគមនិយោជកឯកជន ដូចជា CAMFEBA ឬទីភ្នាក់ងារស្រាវជ្រាវក្នុងស្រុក អាចជួយក្នុងការអង្កេតនេះបាន ដែលអាចបង្កើតឱកាសការងារកាន់តែច្រើនក្នុងការបណ្តុះបណ្តាល និងការកសាងសមត្ថភាពរបស់យុវជន។

ដូចដែលបានបញ្ជាក់តាមរយៈប្រសាសន៍របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន នាយករដ្ឋមន្ត្រីប្រទេសកម្ពុជានៅព្រឹត្តិការណ៍ទាំងពីរការផ្តួចផ្តើមនេះបានយកមកធ្វើការសាកល្បង និងវាយតម្លៃក្រោមគម្រោងទ្រទ្រង់វិស័យអប់រំនៅកម្ពុជា ឧបត្ថម្ភដោយធនាគារពិភពលោក ដើម្បីប្រមូល និងវិភាគបទពិសោធន៍មាតាបិតា និងសហគមន៍ និងជំរុញឱ្យមាតាបិតាមានការយកចិត្តទុកដាក់កាន់តែខ្លាំង និងតម្រូវឱ្យមានការកែលម្អពីសាលារៀន។

យុទ្ធសាស្ត្រគាំពារសង្គមជាតិកម្ពុជាទទួលបានការអនុម័តពីសម្តេចនាយករដ្ឋមន្ត្រី និងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីពេញអង្គ ក្នុងខែមីនា ឆ្នាំ២០១១។

**THE WORLD BANK**
ធនាគារពិភពលោក
១១៣ មហាវិថីព្រះនរោត្តម
រាជធានីភ្នំពេញ
ទូរស័ព្ទលេខ : +៨៥៥ (០)២៣ ២១៧ ៣០៤
គេហទំព័រ : www.worldbank.org/kh